# របាយការណ៍វិភាគ

## សេចក្តីព្រាងច្បាប់លទ្ធកម្មសាធារណៈ (២០២២) និងលិខិតបទដ្ឋានពាក់ព័ន្ធកម្ពុជា

# LEGAL ANALYSIS REPORT

## THE DRAFT LAW ON PUBLIC PROCUREMENT (VERSION 2022) AND RELATED REGULATIONS

# មាតិកា


បញ្ជីអក្សរកាត់ ..... 3

សេចក្តីសង្ខេបខ្លឹមសាររួម ..... 4

ផ្នែកទី១៖ សេចក្តីផ្តើម ..... 8

ផ្នែកទី២៖ ការវាយតម្លៃ និងលទ្ធផល ..... 13

ក. តម្លាភាព ..... 13

ខ. ការគ្រប់គ្រងល្អ ..... 19

គ. គណនេយ្យភាព និងសុចរិតភាព ..... 21

ឃ. ការគ្រប់គ្រង និងការត្រួតពិនិត្យ ..... 26

ង. សិទ្ធិតវ៉ានិងឧបាស្រ័យ ..... 29

ច. ការចូលរួមពីសាធារណៈជន..... 34

ឆ. ការបើកចំហ និងបរិយាបន្ន ..... 35

ផ្នែកទី៣៖ អនុសាសន៍ណែនាំ ..... 40

ក. តម្លាភាព ..... 40

ខ. ការគ្រប់គ្រងល្អ ..... 41

គ. គណនេយ្យភាព និងសុចរិតភាព ..... 42

ឃ. ការគ្រប់គ្រង និង ការត្រួតពិនិត្យ ..... 43

ង. សិទ្ធិតវ៉ានិងឧបាស្រ័យ ..... 44

ច. ការចូលរួមពីសាធារណៈជន..... 45

ឆ. ការបើកចំហ និងបរិយាបន្ន ..... 46

ផ្នែកទី៤៖ សេចក្តីសន្និដ្ឋាន..... 47

ឯកសារយោង..... 48

# បញ្ជីអក្សរកាត់

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| ក.ស.ហ.វ. | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ | សេចក្តីព្រាងលើកទីមួយរបស់ ក.ស.ហ.វ. អំពីច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២ |

# ការសិក្សានិងវិភាគក្របខណ្ឌច្បាប់និងការអនុវត្តលទ្ធកម្មសាធារណៈ
# នៅព្រះរាជាណាចក្រកម្ពុជា
# ដោយផ្ដោតសំខាន់លើតម្លាភាព

## សេចក្តីសង្ខេបខ្លឹមសាររួម


របាយការណ៍នេះត្រូវបានរៀបចំឡើងក្រោមកិច្ចសន្យានៃការផ្តល់សេវាកម្មដល់វិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ និងអង្គការតម្លាភាពកម្ពុជា សម្រាប់ការស្រាវជ្រាវនិងវិភាគក្របខណ្ឌច្បាប់និងបទប្បញ្ញត្តិគ្រប់គ្រងលទ្ធកម្មសាធារណៈ និងការអនុវត្តនៅកម្ពុជា។ ជាលទ្ធផលនៃការធ្វើលទ្ធកម្មគម្រោង ការិយាល័យមេធាវី សិង្ហាល័យ បានធ្វើការសិក្សាស្រាវជ្រាវនិងវិភាគលើឯកសារនិងព័ត៌មានដែលមានស្រាប់ អំពីក្របខណ្ឌច្បាប់និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈនៅព្រះរាជាណាចក្រកម្ពុជា។ ដោយសារតែក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់លទ្ធកម្មសាធារណៈ ដែលកំពុងស្ថិតនៅដំណាក់កាលពិភាក្សាជាសាធារណៈ របាយការណ៍នេះនឹងយកសេចក្តីព្រាងច្បាប់លទ្ធកម្មសាធារណៈជាឯកសារគោល ក្នុងការសិក្សានិងវិភាគ។ ដើម្បីផ្តល់មតិយោបល់ ការសិក្សានិងវិភាគត្រូវបានធ្វើឡើងតាមការវិភាគបែបប្រៀបធៀបច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (ទាំងច្បាប់នាពេលបច្ចុប្បន្ននិងសេចក្តីព្រាងច្បាប់) ជាមួយនឹងក្របខណ្ឌច្បាប់លទ្ធកម្មសាធារណៈ ដែលប្រទេសកម្ពុជាកំពុងអនុវត្តនាពេលបច្ចុប្បន្ន និងឧត្តមានុវត្តអន្តរជាតិ រួមមាន ច្បាប់លទ្ធកម្មសាធារណៈគម្រូរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ និងច្បាប់លទ្ធកម្មសាធារណៈរបស់ប្រទេសដទៃ។

របាយការណ៍នេះផ្តោតសំខាន់ទៅលើបញ្ហាបច្ចេកទេសចំនួនប្រាំពីររួមមាន ១) តម្លាភាព ២) ការគ្រប់គ្រង ៣) សុចរិតភាព ៤) ការត្រួតពិនិត្យ ៥) សិទ្ធិប្តឹងទាមទារ ៦) គណនេយ្យភាពសង្គម និង ៧) បរិយាបន្ន។ របាយការណ៍ នេះបានផ្តល់ជាយោបល់មួយចំនួនដូចខាងក្រោម៖

**១. តម្លាភាព**

ដើម្បីបំពេញចំណុចខ្វះខាតក្នុងច្បាប់ដែលមិនបានទាមទារឱ្យមានការផ្សព្វផ្សាយជាសាធារណៈអំពីនីតិវិធីចរចានិងលទ្ធកម្មសាធារណៈពីប្រភពតែមួយ របាយការណ៍ស្នើឱ្យសេចក្តីព្រាងច្បាប់លទ្ធកម្មសាធារណៈតម្រូវឱ្យមានការផ្សព្វផ្សាយជាសាធារណៈអំពីវិធីទាំងនេះ។ ជាងនេះទៅទៀត ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគួរត្រូវបានយកមកប្រើប្រាស់ ដើម្បីបង្កើនតម្លាភាពនៃការធ្វើលទ្ធកម្មសាធារណៈ។ ដូចនេះ សេចក្តីព្រាងច្បាប់លទ្ធកម្មសាធារណៈគួរមានបញ្ញត្តិបង្កើតនិងទទួលស្គាល់ឱ្យមានថ្នាលព័ត៌មានលើបណ្តាញអ៊ីនធើណេត ដើម្បីបង្ហាញព័ត៌មានសាធារណៈពាក់ព័ន្ធនឹងនីតិវិធីលទ្ធកម្មទាំងមូល រួមមាន ការអញ្ជើញ ឱ្យចូលរួមដេញថ្លៃ អត្តសញ្ញាណរបស់អ្នកដេញថ្លៃ អ្នកដេញថ្លៃដែលត្រូវបានជ្រើសរើស និងព័ត៌មានសំខាន់ៗអំពីកិច្ចសន្យាដែលត្រូវបានចុះហត្ថលេខាឬផ្តល់ជូនអ្នកដេញថ្លៃដែលទទួលបានគម្រោង។

**២. ការគ្រប់គ្រង**

របាយការណ៍បានស្នើឱ្យសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈគួរបញ្ចូលនូវវិធាននិងនីតិវិធីគោលៗឬចម្បងពាក់ព័ន្ធនឹងការរៀបចំថវិកាសម្រាប់ចំណាយទៅលើគម្រោងដែលទទួលបានពីលទ្ធកម្មសាធារណៈ ដែលមានតម្រូវការចំណាយរយៈពេលមធ្យម។ ដូចនេះ សេចក្តីព្រាងច្បាប់និងបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈគួរ ១) ពង្រឹងក្របខណ្ឌចំណាយរយៈពេលមធ្យម សម្រាប់រៀបចំផែនការចំណាយលទ្ធកម្មសាធារណៈ ២) ទាមទារឱ្យមាន

សង្ខេបអំពីគម្រោងលទ្ធកម្មសាធារណៈនិងការចំណាយភ្ជាប់ជាមួយឯកសារថវិកាប្រចាំឆ្នាំ សម្រាប់ដាក់ជូនសភាពិនិត្យនិងផ្សព្វផ្សាយជាសាធារណៈ និង ៣) មានរបាយការណ៍អនុវត្តគម្រោងលទ្ធកម្មសាធារណៈ ភ្ជាប់ជាមួយនឹងរបាយការណ៍អនុវត្តថវិកា ដើម្បីដាក់ជូនសភាពិនិត្យនិងផ្សព្វផ្សាយជាសាធារណៈ។ ជាងនេះទៅទៀត របាយការណ៍នេះក៏បានស្នើឱ្យរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាពិនិត្យលទ្ធភាពបង្កើតឱ្យមានការការពារផ្លូវច្បាប់ដល់គណៈកម្មការឬគណៈកម្មាធិការលទ្ធកម្មនិងអ្នករាយការណ៍អំពីបញ្ហាអនុលោមភាពក្នុងលទ្ធកម្មសាធារណៈ។

### ៣. សុចរិតភាព

របាយការណ៍នេះបានស្នើឱ្យសេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈចាត់ទុកវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែង ជាសាធារណៈ ជាវិធីសាស្ត្រលទ្ធកម្មទូទៅនិងស្វ័យប្រវត្តិ ជាជាងការកំណត់ថា វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងនេះគឺជាវិធីសាស្ត្រលទ្ធកម្មដែលមានកម្រិតតម្លាភាពខ្ពស់ និងដែលត្រូវជម្រុញឱ្យប្រើក្នុងលទ្ធកម្មសាធារណៈ។ ដូចនេះ ប្រសិនបើវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ ត្រូវបានកំណត់ជាវិធីសាស្ត្រលទ្ធកម្មទូទៅនិងស្វ័យប្រវត្តិ នោះវិធីសាស្ត្រ ដេញថ្លៃផ្សេងៗទៀត នឹងត្រូវយកមកពិចារណានិងប្រើប្រាស់នៅកាលៈទេសៈពិសេសតែប៉ុណ្ណោះ។

ដោយសារតែគណនេយ្យភាពនិងសុចរិតភាពទាមទារឱ្យមានវិធាននៃការបង្គាប់បញ្ជាច្បាស់លាស់ ដូចនេះ របាយការណ៍ នេះបានស្នើឱ្យសេចក្ដីព្រាងច្បាប់លទ្ធកម្មសាធារណៈចែងអំពីកាតព្វកិច្ចក្នុងការរក្សាកំណត់ត្រានៃការសម្រេចចិត្តក្នុងលទ្ធកម្ម ដើម្បីផ្ដល់ជាកំណត់ហេតុជាលាយលក្ខណ៍ អក្សរបញ្ជាក់អំពីនីតិវិធីនៃការសម្រេចចិត្ត នៅក្នុងដំណាក់កាលនៃស្ថាប័នអនុវត្តលទ្ធកម្ម និងស្ថាប័នគ្រប់គ្រងលទ្ធកម្មសាធារណៈ គឺក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ម្យ៉ាងវិញទៀត ក្របខណ្ឌច្បាប់នាពេលបច្ចុប្បន្ននៅមិនទាន់កំណត់អំពីលទ្ធភាពតាមផ្លូវច្បាប់ក្នុងការលុបចោលការអនុវត្តលទ្ធកម្មសាធារណៈ។ ដូចនេះ សេចក្ដីព្រាងច្បាប់លទ្ធកម្មសាធារណៈគួរចែងបញ្ញត្តិគ្រប់គ្រងលទ្ធភាព នៃការលុបចោលការអនុវត្តលទ្ធកម្មសាធារណៈ រួមមានកាតព្វកិច្ចក្នុងការកត់ត្រាហេតុផលដែលបណ្ដាលឱ្យមានការលុបចោល ការអនុវត្តលទ្ធកម្មសាធារណៈនោះ។

ចំពោះមុខងារ របាយការណ៍នេះបានស្នើការពិចារណាទៅលើការផ្ទេរមុខងារត្រួតពិនិត្យលទ្ធកម្មទៅស្ថាប័នដោយឡែកក្រៅពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានមុខងារគ្រប់គ្រងលទ្ធកម្មសាធារណៈរួចទៅហើយ ដើម្បីធានាឱ្យបាននូវតុល្យភាព នៃអំណាចនិងជៀសវាងបញ្ហាទំនាស់ផលប្រយោជន៍។

ជាមួយគ្នានេះ របាយការណ៍នេះក៏បានស្នើឱ្យសេចក្ដីព្រាងច្បាប់លទ្ធកម្មសាធារណៈចែងនូវបញ្ញត្តិសារធាតុ ជាបញ្ញត្តិពិសេសលុបលើបញ្ញត្តិទូទៅនៃច្បាប់កិច្ចសន្យា ដើម្បីមោឃៈរាល់កិច្ចសន្យាលទ្ធកម្ម ដែលត្រូវបានធ្វើឡើងដោយមិនស្របច្បាប់។ ប្រការនេះអាចជួយកាត់បន្ថយបញ្ហាពុករលួយដែលផ្ដើមឡើងដោយវិស័យឯកជន ដើម្បីទទួលបានកិច្ចសន្យាលទ្ធកម្មសាធារណៈ។

### ៤. ការត្រួតពិនិត្យ

របាយការណ៍នេះបានស្នើឱ្យមានការបង្កើតបទប្បញ្ញត្តិជាក់លាក់ដើម្បីកំណត់អំពីនីតិវិធីអនុវត្ត រួមមានប្រកាសស្ដីពីវិធាននិងនីតិវិធីនៃការទទួលយកទំនិញនិងសេវា ដែលជាលទ្ធផលនៃការអនុវត្តកិច្ចសន្យាដែលបានមកពីការធ្វើលទ្ធកម្មសាធារណៈ។ រាល់គម្រោងលទ្ធកម្មសាធារណៈដែលត្រូវបានបញ្ចប់ហើយ គួរត្រូវបានពិនិត្យនិងទទួលយកដោយស្ថាប័នមានសមត្ថកិច្ច តាម

ច្បាប់ បទប្បញ្ញត្តិ និងកិច្ចសន្យាជាធរមាន។ រាល់ទ្រព្យដែលជាលទ្ធផលនៃការធ្វើលទ្ធកម្មសាធារណៈនោះត្រូវបានចាត់ទុកជាទ្រព្យរដ្ឋ ដែលត្រូវកត់ត្រាទុកក្នុងតារាងតុល្យការរបស់រដ្ឋ និងគ្រប់គ្រងដោយស្ថាប័នដែលមានសមត្ថកិច្ចគ្រប់គ្រងទ្រព្យរដ្ឋ។

ដើម្បីចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រងហានិភ័យ របាយការណ៍នេះបានផ្តល់ជាយោបល់ឱ្យសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈផ្តល់មុខងារជូនស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងហានិភ័យ ក្នុងលទ្ធកម្មសាធារណៈ និងដាក់កាតព្វកិច្ចឱ្យស្ថាប័នអនុវត្តលទ្ធកម្មវិភាគអំពីហានិភ័យនៃភាពមិនអនុលោមនិងអំពើពុករលួយ នៅក្នុងការអនុវត្តលទ្ធកម្មសាធារណៈជាទូទៅ។ ការតាមដាននិងត្រួតពិនិត្យគណនេយ្យភាពនិងសុចរិតភាពនៃការអនុវត្តលទ្ធកម្ម តម្រូវឱ្យមានការផ្តល់ជាការការពារផ្នែកច្បាប់ដល់អ្នករាយការណ៍អំពីបញ្ហាអនុលោមភាពក្នុងលទ្ធកម្មសាធារណៈផងដែរ។ ដូចនេះ របាយការណ៍នេះបានស្នើឱ្យបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មនូវវិធីសាស្ត្រដែលអនុញ្ញាតឱ្យភាគីពាក់ព័ន្ធអាចរាយការណ៍អំពីរាល់ភាពមិនអនុលោមនៅក្នុងគម្រោងលទ្ធកម្មសាធារណៈ និងផ្តល់ការការពារនៅពេលមានហេតុការនៃការរាយការណ៍កើតឡើង។

**៥. សិទ្ធិប្តឹងទាមទារ**

គោលការណ៍ទូទៅនៃច្បាប់ គឺការកំណត់ឬបែងចែកមុខងារក្នុងការសម្រេចនិងដោះស្រាយបញ្ហាមួយ។ ភ្ជាប់ជាមួយនឹងការបង្កើតឬបែងចែកមុខងារត្រួតពិនិត្យទៅស្ថាប័នឯករាជ្យក្រៅពីស្ថាប័នដែលគ្រប់គ្រងលទ្ធកម្មសាធារណៈ របាយការណ៍នេះក៏បានផ្តល់អនុសាសន៍បន្ថែមឱ្យប្រគល់មុខងារនៃការដោះស្រាយវិវាទជូនស្ថាប័នមួយដោយឡែកផ្សេងទៀត ក្រៅពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជៀសវាងបញ្ហាទំនាស់ផលប្រយោជន៍។ ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងអនុលោមភាពក្នុងការអនុវត្តលទ្ធកម្មសាធារណៈ របាយការណ៍នេះបានស្នើឱ្យមានការបង្កើតនូវនីតិវិធីដើម្បីដោះស្រាយបញ្ហាឬផ្តល់បដិទានតាមផ្លូវច្បាប់ជូនដល់ភាគីដែលមានប្រយោជន៍រួមមានសាធារណជនជាដើម ដែលបុគ្គលទាំងនោះគួរមានសិទ្ធិទាមទារឬតវ៉ា លើបញ្ហាមួយចំនួនពាក់ព័ន្ធនឹងការអនុវត្តលទ្ធកម្ម រួមទាំងវិធីសាស្ត្រនៃការធ្វើលទ្ធកម្មជាដើម។ ដើម្បីភាពប្រាកដប្រជានៃច្បាប់ របាយការណ៍នេះបានស្នើឱ្យមានការកំណត់អាជ្ញាយុកាលសម្រាប់អ្នកដេញថ្លៃអាចដាក់បណ្តឹងទាមទារ ដើម្បីទទួលបានការដោះស្រាយដោយស្ថាប័នមានសមត្ថកិច្ច មុនត្រូវបានតវ៉ាបន្តទៅតុលាការ ដោយបូករួមទាំងនីតិវិធីតវ៉ានៅពេលដែលនីតិវិធីត្រូវបានផ្អាកជាដើម។

ម្យ៉ាងវិញទៀត សេចក្តីព្រាងច្បាប់លទ្ធកម្មសាធារណៈ ក៏គួរតែពិចារណាកំណត់មជ្ឈតកម្មជាជម្រើសនៃការដោះស្រាយជម្លោះក្នុងលទ្ធកម្មសាធារណៈផងដែរ។

**៦. ការចូលរួមពីសាធារណជន**

របាយការណ៍នេះបានផ្តល់ជាមតិយោបល់ឱ្យមានការបង្កើតប្រព័ន្ធមួយដែលអនុញ្ញាតឱ្យប្រជាជននិងភាគីពាក់ព័ន្ធអាចផ្តល់យោបល់ទៅលើផែនការលទ្ធកម្មនិងគម្រោងលទ្ធកម្ម ដោយយកគណនេយ្យភាពសង្គមដែលបង្កើតឡើងដោយរដ្ឋបាលថ្នាក់ក្រោមជាតិជាគម្រូ។ ដើម្បីជម្រុញឱ្យមានការចូលរួមពីសាធារណជនឱ្យមានប្រសិទ្ធភាព ព័ត៌មានអំពីគម្រោងលទ្ធកម្មសាធារណៈរួមមានព័ត៌មានអំពីតម្លៃ គុណភាព និងការអនុវត្ត គួរត្រូវបានបោះផ្សាយជូនសាធារណជន ជាទម្រង់សង្ខេបនិងងាយយល់។ ជាងនេះទៅទៀត សាធារណជនអាចត្រូវបានតំណាងដោយសមាជិកសភាឬក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដើម្បីពិនិត្យនិងសម្រេចលើការចំណាយទៅលើគម្រោងលទ្ធកម្មសាធារណៈ។ ដូចនេះ រាល់ថវិកាដែលត្រូវចំណាយទៅលើគម្រោងលទ្ធកម្មសាធារណៈនិងផែនការគម្រោងលទ្ធកម្មសាធារណៈ គួរត្រូវបានរាយការណ៍ជាសង្ខេបជូនសភានិងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិភ្ជាប់ជាមួយនឹងឯកសារថវិកាប្រចាំឆ្នាំ សម្រាប់ឱ្យសភានិងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិពិនិត្យនិងសម្រេច។ នារាល់ចុងឆ្នាំ

ហិរញ្ញវត្ថុ    របាយការណ៍សង្ខេបនៃការអនុវត្តគម្រោងលទ្ធកម្មសាធារណៈត្រូវរៀបចំឡើងនិងដាក់ជូនសភានិងរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីពិនិត្យនិងសួរនាំ ប្រសិនបើមានជាចម្ងល់។

**៧. ការបើកចំហរនិងបរិយាបន្ន**

របាយការណ៍នេះបានស្នើឱ្យសេចក្តីព្រាងច្បាប់ដោះស្រាយបញ្ហានៅចំពោះមុខបីធំៗគឺ ១) ការលុបចោលនូវរនាំងការិយាធិបតេយ្យនៃការចុះបញ្ជីនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីអាចចូលរួមដេញថ្លៃ ២) ការពិចារណាទៅលើការជម្រុញឱ្យមានការចូលរួមពីសហគ្រាសធុនតូចនិងមធ្យម និង ៣) ការបង្កើតឱ្យមានបទដ្ឋាននៃនីតិវិធី ដែលអាចឆ្លើយតបទៅនឹងគោលនយោបាយសេដ្ឋកិច្ចនិងសង្គម សម្រាប់ប្រើប្រាស់វិធីសាស្ត្រ“កិច្ចសន្យាជាមួយនឹងសហគមន៍”ឱ្យមានប្រសិទ្ធភាព ដូចដែលបានកំណត់ក្នុងច្បាប់និងសេចក្តីព្រាងច្បាប់លទ្ធកម្មសាធារណៈ។

## ផ្នែកទី១៖ សេចក្ដីផ្ដើម

លទ្ធកម្មសាធារណៈដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសនៅក្នុងវដ្ដថវិកាពោលគឺក្នុងអំឡុងពេលនៃដំណើរការរៀបចំថវិកា និងការអនុវត្តថវិកា។ ក្របខណ្ឌច្បាប់ពាក់ព័ន្ធលទ្ធកម្មសាធារណៈបានចាប់ផ្ដើមវិវឌ្ឍន៍ចាប់តាំងពីអនុក្រឹត្យលេខ១០៥ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ រហូតក្លាយជាច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១២។[1]

ច្បាប់ស្ដីពីលទ្ធកម្មសាធារណៈនេះ ត្រូវបានអនុម័តឡើងដើម្បីធានាថា នីតិវិធីលទ្ធកម្មសាធារណៈត្រូវបានអនុវត្តដោយបើកចំហ ប្រកបដោយគណនេយ្យភាព យុត្តិធម៌ ប្រសិទ្ធភាព គុណភាព សមភាព/សមធម៌ ប្រសិទ្ធភាពសេដ្ឋកិច្ច និងទាន់ពេលវេលា ព្រមទាំងដើម្បីធានាថា ប្រព័ន្ធលទ្ធកម្មសាធារណៈមានភាពស៊ីសង្វាក់គ្នានៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ច្បាប់ស្ដីពីលទ្ធកម្មសាធារណៈមានគោលបំណងបង្កើតគោលការណ៍ណែនាំការអនុវត្ត និងក្របខ័ណ្ឌរបស់ស្ថាប័នសម្រាប់ ក្នុងការរៀបចំនិងអនុវត្តរាល់សកម្មភាពលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ តែយ៉ាងណាមិញ បញ្ហានៃច្បាប់ស្ដីពីលទ្ធកម្មសាធារណៈនាពេលបច្ចុប្បន្នគឺ ១) ការបែងចែកមិនច្បាស់លាស់រវាងនិយ័តករលទ្ធកម្មសាធារណៈ និងស្ថាប័នអនុវត្តលទ្ធកម្ម និង ២) ការមិនទាន់បញ្ចូលគោលការណ៍នៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈនិងលទ្ធកម្មសាធារណៈ។

ដោយសារច្បាប់ស្ដីពីលទ្ធកម្មសាធារណៈផ្ដល់ត្រឹមគោលការណ៍នៃការអនុវត្ត បទប្បញ្ញត្តិផ្សេងៗទៀតក៏ត្រូវបានអនុម័តដាក់ឱ្យប្រើប្រាស់ដើម្បីផ្ដល់សេចក្ដីលម្អិតបន្ថែមអំពីនីតិវិធីអនុវត្តជាក់ស្ដែង រួមមាន អនុក្រឹត្យដែលចេញដោយរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាប្រកាសនិងសារាចរណែនាំដែលអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (“**ក.ស.ហ.វ.**”) ដើម្បីគ្រប់គ្រងនិងអនុវត្តលទ្ធកម្មសាធារណៈនៅកម្ពុជា។

ជាទិសដៅនៃយោបាយនិងកែទម្រង់ ការកែទម្រង់លទ្ធកម្មសាធារណៈត្រូវបានចាត់ជាផ្នែកមួយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ដំបូងឡើយ ការកែទម្រង់លទ្ធកម្មសាធារណៈ ត្រូវបានបញ្ចូលជាផ្នែកមួយនៃកម្មវិធីកែទម្រង់ថវិកជាតិឆ្នាំ ២០១៨ ដល់ឆ្នាំ ២០២៥។ យោងសារសំខាន់ជាចាំបាច់នៃការកែទម្រង់លទ្ធកម្មសាធារណៈនៅក្នុងដំណាក់កាលរៀបចំថវិកានិងអនុវត្តថវិកា រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តយុទ្ធសាស្ត្រកែទម្រង់សម្រាប់លទ្ធកម្មសាធារណៈចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ ២០២៥។ ក្រោមយុទ្ធសាស្ត្រកំណែទម្រង់ដែលត្រូវបានអនុម័តនេះ រាជរដ្ឋាភិបាល

[1] សូមធ្វើការកត់សម្គាល់ថាលទ្ធកម្មសាធារណៈ ត្រូវបានគ្រប់គ្រងដោយបទប្បញ្ញត្តិកាលពីមុន។សូមមើលអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្ដីពីលទ្ធកម្មសាធារណៈ។

កម្ពុជាមានគោលបំណង ១) ធ្វើវិមជ្ឈការនៃដំណើរការនិងនីតិវិធីលទ្ធកម្មសាធារណៈ លើកលែងចំពោះប្រភេទលទ្ធកម្មមួយចំនួនដែលតម្រូវឱ្យធ្វើតាមក្របខណ្ឌមជ្ឈការដើម្បីកាត់បន្ថយការចំណាយ និងបង្កើនប្រសិទ្ធភាពនៃការដេញថ្លៃ ២) លើកកម្ពស់ប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃនីតិវិធីលទ្ធកម្ម តាមរយៈការប្រើប្រាស់បច្ចេកវិទ្យានិងគោលការណ៍ណែនាំច្បាស់លាស់ និង ៣) សម្របសម្រួលនីតិវិធីលទ្ធកម្មជាមួយវដ្តនៃការគ្រប់គ្រងលទ្ធកម្មសាធារណៈ។

ស្របតាមកំណែទម្រង់និងដោះស្រាយបញ្ហានៃការបែងចែកមុខងារមិនច្បាស់លាស់ **ក.ស.ហ.វ.** បាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ថ្មីស្តីពីលទ្ធកម្មសាធារណៈ។ រហូតមកដល់ពេលនេះ សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ត្រូវបានផ្សព្វផ្សាយសម្រាប់ការស្នើសុំមតិយោបល់ កែសម្រួល និងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីប្រជុំនិងកែសម្រួលបន្ត។ ជាការកត់សម្គាល់ សេចក្តីព្រាងច្បាប់នេះបានរក្សាបទប្បញ្ញត្តិមួយចំនួននៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈបច្ចុប្បន្ន ដោយមានការកែសម្រួលមួយចំនួន។ ដូចគ្នាផងដែរ សេចក្តីព្រាងច្បាប់ថ្មីនេះក៏បានដាក់ចេញនូវបទប្បញ្ញត្តិថ្មីៗជាច្រើនដើម្បីកំណត់អំពី ១) ការធ្វើវិមជ្ឈការនៃលទ្ធកម្មសាធារណៈ ២) គុណវុឌ្ឍិរបស់អ្នកដេញថ្លៃឈ្នះ ៣) ការភ្ជាប់កិច្ចលទ្ធកម្មជាមួយនឹងនិរន្តរភាពនៃសេដ្ឋកិច្ច សង្គម និងបរិស្ថាន ៤) ការដោះស្រាយវិវាទស្របតាមកិច្ចព្រមព្រៀង និង ៥) ការត្រួតពិនិត្យការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។ នៅខណៈពេលដែលសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈបាននិងកំពុងស្ថិតក្រោមការពិភាក្សានិងកែសម្រួល វាមានភាពចាំបាច់ណាស់ ដែលរបាយការណ៍នេះនឹងធ្វើការវិភាគទៅលើក្របខណ្ឌច្បាប់នៃលទ្ធកម្មសាធារណៈក្នុងប្រទេសកម្ពុជា ដើម្បីកំណត់បញ្ហាប្រឈម ដើម្បីផ្តល់ជាមតិយោបល់កែតម្រូវលើសេចក្តីព្រាងច្បាប់ថ្មីនេះ។

មុននឹងឈានទៅដល់ការវាយតម្លៃលើក្របខណ្ឌច្បាប់ស្តីពីលទ្ធកម្មសាធារណៈនៅកម្ពុជា ដែលត្រូវបានលើកឡើងនៅក្នុងផ្នែកបន្ទាប់ ជាបឋមផ្នែកនេះនឹងរៀបរាប់ពីសារតាសង្ខេបរបស់គោលការណ៍ទូទៅនៃលទ្ធកម្មសាធារណៈនៅក្នុងផ្នែករង (ក) និងទិដ្ឋភាពទូទៅនៃលទ្ធកម្មសាធារណៈនៅកម្ពុជានៅក្នុងផ្នែករង ( ខ)។

## ក. សារតារបស់គោលការណ៍ទូទៅនៃលទ្ធកម្មសាធារណៈ

ជាទូទៅ លទ្ធកម្មសាធារណៈត្រូវបានគេស្គាល់ថាជានីតិវិធីនៃការទិញទំនិញ និង/ឬសេវាកម្មពីក្រុមហ៊ុនឯកជន ឬអ្នកទទួលការដោយស្ថាប័នអនុវត្តលទ្ធកម្មសាធារណៈ។ វាក៏អាចត្រូវបានកំណត់ថាជា *"ដំណើរការកំណត់អត្តសញ្ញាណនូវតម្រូវការ កំណត់លើបុគ្គលឬស្ថាប័នណាមួយដែលសាកសមបំផុតដើម្បីផ្គត់ផ្គង់តម្រូវការនេះ និងធានាថាតម្រូវការនេះត្រូវបានប្រគល់ទៅកាន់ទីតាំងដែលត្រឹមត្រូវ ទាន់ពេលវេលា ក្នុងតម្លៃដ៏សមរម្យ ហើយការណ៍ទាំងអស់នេះត្រូវ*

*បានធ្វើដោយស្មើភាពនិងក្នុងលក្ខណៈបើកចំហ"*។[2] គោលការណ៍លទ្ធកម្មសាធារណៈដែលបានកំណត់ខាងលើ បានដើរតួជាមូលដ្ឋានគ្រឹះសម្រាប់នីតិវិធីលទ្ធកម្មសាធារណៈ។

ដើម្បីផ្តល់ជាឧត្តមានុវត្តន៍នៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ គណៈកម្មការអង្គការសហប្រជាជាតិសម្រាប់ច្បាប់ពាណិជ្ជកម្មអន្តរជាតិ ("UNCITRAL") បានរៀបចំច្បាប់លទ្ធកម្មសាធារណៈគម្រូ សម្រាប់ឱ្យរដ្ឋនានាយកទៅប្រើប្រាស់ជាគម្រូក្នុងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មក្នុងប្រទេសនីមួយៗរបស់ខ្លួន[3]។ លើសពីនេះទៅទៀតអង្គការសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការសេដ្ឋកិច្ច ("OECD") បានអនុម័តអនុសាសន៍ណែនាំមួយដែលចែងនូវគោលការណ៍ណែនាំចំនួនដប់ពីរ (១២) សម្រាប់ប្រទេសនានាដើម្បីអនុម័តក្នុងគោលបំណង "លើកកម្ពស់យុទ្ធសាស្រ្ត និង ការប្រើប្រាស់លទ្ធកម្មសាធារណៈ[4]។

គោលការណ៍គន្លឹះទូទៅនៃលទ្ធកម្មសាធារណៈរួមមាន៖ ១) តម្លាភាព, ២) សុចរិតភាព, ៣) ប្រសិទ្ធភាពនិងភាពសន្សំសំចៃ ៤) ភាពបើកចំហ ៥) សមភាពនិងការប្រកួតប្រជែង និង ៦) គណនេយ្យភាព។ គោលការណ៍នីមួយៗទាំងអស់នេះនឹងត្រូវបានពិពណ៌នាបន្ថែមទៀតនៅខាងផ្នែកក្រោម។

**១). តម្លាភាព៖** តម្លាភាពគឺជាគោលការណ៍គន្លឹះមួយក្នុងចំណោមគោលការណ៍ទាំងអស់នៅក្នុងលទ្ធកម្មសាធារណៈ។ ដើម្បីឱ្យមានភាពកាន់តែប្រសើរ វដ្តនៃលទ្ធកម្មទាំងមូលគួរតែមានតម្លាភាព។ ជាទូទៅតម្លាភាពពាក់ព័ន្ធនឹង៖ "*(ក) ការផ្សព្វផ្សាយជាសាធារណៈអំពីឱកាសលទ្ធកម្ម និងការបង្ហាញពីវិធាន (ខ) ការធានាឱ្យមានការផ្សព្វផ្សាយអំពីនីតិវិធីលទ្ធកម្មជាសាធារណៈ និង (គ) ការផ្តល់ប្រព័ន្ធសម្រាប់ការត្រួតពិនិត្យ និងការអនុវត្តបទប្បញ្ញត្តិជាធរមាន*"។[5]

---

[2] អង្គការសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការសេដ្ឋកិច្ច, គោលការណ៍ណែនាំរបស់ក្រុមប្រឹក្សាលទ្ធកម្មសាធារណៈ, ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ ២០១៥ ហើយឯកសារនេះមាននៅ: https://legalinstruments.oecd.org/en/instruments/OECD-LEGAL-0411#dates

[3] អង្គការសហប្រជាជាតិ, *គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈដែលរៀបចំឡើងដោយគណៈកម្មការអង្គការសហប្រជាជាតិសម្រាប់ច្បាប់ពាណិជ្ជកម្មអន្តរជាតិ*, ខែមិថុនា ឆ្នាំ២០១៤ ហើយឯកសារនេះមាននៅក្នុង: https://www.un-ilibrary.org/content/books/9789210541947#:~:text=The%20Model%20Law%20is%20a,and%20equitable%20treatment%20and%20transparency).

[4] អង្គការសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការសេដ្ឋកិច្ច ("**OECD**"), *អនុសាសន៍អំពីឧត្តមានុវត្តន៍នៃកិច្ចលទ្ធកម្មសាធារណៈ*, *ឆ្នាំ២០១៥*, ហើយឯកសារនេះមាននៅក្នុង: https://www.oecd.org/gov/public-procurement/OECD-Recommendation-on-Public-Procurement.pdf

[5] ការិយាល័យប្រឆាំងបទល្មើសនិងថ្នាំរបស់អង្គការសហប្រជាជាតិ ("**UNODC**"), *សៀវភៅណែនាំប្រឆាំងអំពើពុករលួយក្នុងកិច្ចលទ្ធកម្មសាធារណៈ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៖ ឧត្តមានុវត្តន៍ ក្នុងអនុលោមភាពនៃមាត្រា ៩ របស់អង្គការសហប្រជាជាតិ*

**២). សុចរិតភាព៖** សុចរិតភាពនៃលទ្ធកម្មសាធារណៈ រួមមានសុចរិតភាពនៃនីតិវិធីលទ្ធកម្មសាធារណៈ និងភាពសុចរិតរបស់អ្នកអនុវត្ត។ សុចរិតភាពនៃនីតិវិធីលទ្ធកម្មសាធារណៈតម្រូវឱ្យរាល់ព័ត៌មានដែលត្រូវបានផ្សព្វផ្សាយក្នុងអំឡុងពេលនីតិវិធីលទ្ធកម្មត្រូវតែជាព័ត៌មានដែលអាចជឿទុកចិត្តបាន និងសុក្រឹត្យ។ សុចរិតភាពរបស់អ្នកអនុវត្ត សំដៅលើសុចរិតភាពវិជ្ជាជីវៈ ដែលរាល់អង្គភាពពាក់ព័ន្ធក្នុងនីតិវិធីលទ្ធកម្មគួរតែប្រកាន់ខ្ជាប់។ ជាព័ត៌មានបន្ថែមស្តីពីគោលការណ៍នេះ អង្គការសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការសេដ្ឋកិច្ចបានអនុម័ត "គោលការណ៍សុចរិតភាព របស់អង្គការសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងលទ្ធកម្មសាធារណៈ" ក្នុងគោលបំណងផ្តល់ការណែនាំអំពីគោលការណ៍ដែលអាចពង្រឹងអភិបាលកិច្ចល្អក្នុងលទ្ធកម្មសាធារណៈ ក៏ដូចជាជួយរដ្ឋាភិបាលដើម្បី"ទប់ស្កាត់ការខ្ជះខ្ជាយថវិកា ការលួចបន្លំ និងអំពើពុករលួយ" នៅក្នុងវដ្តនៃលទ្ធកម្មសាធារណៈ។[6]

**៣). ប្រសិទ្ធភាពនិងភាពសន្សំសំចៃ៖** គោលការណ៍ទាំងនេះបានណែនាំឱ្យមានការគ្រប់គ្រងដោយយកចិត្តទុកដាក់និងប្រុងប្រយ័ត្នទៅលើមូលនិធិសាធារណៈ ជាពិសេសចំពោះថ្លៃចំណាយរដ្ឋបាលដែលមិនសូវសំខាន់ ដើម្បីធានាថា ចំនួនទឹកប្រាក់ដែលបានចំណាយលើថ្លៃទំនិញនិងសេវាដែលបានមកពីការធ្វើកិច្ចលទ្ធកម្មមានប្រសិទ្ធភាពនិងមិនខ្ជះខ្ជាយ។

**៤). ការបើកចំហ៖** ការអញ្ជើញឱ្យដាក់ពាក្យចូលរួមការដេញថ្លៃគួរតែត្រូវបានបើកចំហចំពោះអ្នកដេញថ្លៃទាំងអស់មិនថាក្នុងដេញថ្លៃក្នុងស្រុកឬក្រៅស្រុក ដោយគ្មានការរឹតត្បិតណាមួយឡើយ។

**៥). សមភាព៖** នីតិវិធីលទ្ធកម្មសាធារណៈត្រូវតែធ្វើឡើងប្រកបដោយសមភាព។ ការណ៍នេះរួមបញ្ចូលនូវសកម្មភាពដែលថា ការធ្វើសេចក្តីសម្រេចចិត្តត្រូវធ្វើឡើងដោយគ្មានភាពលម្អៀងឬការអនុគ្រោះ ប៉ុន្តែត្រូវធ្វើដោយពិនិត្យលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់ និងដោយមានយន្តការសម្រាប់ធ្វើការតវ៉ាពាក់ព័ន្ធនឹងសេចក្តីសម្រេចនោះ។ រាជរដ្ឋាភិបាលអាចធានាបាននូវគោលការណ៍នេះដោយផ្តល់ឱកាសស្មើៗគ្នាទៅឱ្យអ្នកដេញថ្លៃទាំងអស់ធ្វើការប្រកួតប្រជែងដេញថ្លៃ។

**៦). គណនេយ្យភាព៖** រាល់បុគ្គលដែលចូលរួមក្នុងគម្រោងលទ្ធកម្ម ត្រូវទទួលខុសត្រូវចំពោះរាល់សកម្មភាពនិងសេចក្តីសម្រេចរបស់ខ្លួន។ ក្នុងន័យនេះ ការបង្កើតខ្សែសង្វាក់នៃការទទួលខុសត្រូវដែល

---

[6] អង្គការសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងលទ្ធកម្មសាធារណៈ("OECD"), *គោលការណ៍សុចរិតភាពរបស់អង្គការសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងលទ្ធកម្មសាធារណៈ* ឆ្នាំ២០០៩ ដែលឯកសារនេះមាននៅ https://www.oecd.org/gov/ethics/48994520.pdf

ច្បាស់លាស់មួយ ដោយកំណត់នូវសិទ្ធិអំណាចក្នុងការឯកភាពយល់ព្រម ដោយផ្អែកលើការបែងចែកភារកិច្ចដ៏សមស្រប ត្រូវបានមើលឃើញជាទូទៅថា ជាការសំខាន់។ យន្តការត្រួតពិនិត្យអាចត្រូវបានចាត់ទុកជាផ្នែកម្ខាងទៀតដ៏សំខាន់ដែលផ្តល់នូវក្របខណ្ឌមួយសម្រាប់វាយតម្លៃថា តើសកម្មភាពដែលត្រូវបានធ្វើឡើងស្របតាមនីតិវិធីលទ្ធកម្មដែរឬយ៉ាងណា។[7]

## ខ.និដ្ឋភាពទូទៅនៃលទ្ធកម្មសាធារណៈនៅកម្ពុជា

នៅក្រោមច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ដែលកំពុងត្រូវបានអនុវត្តនាពេលបច្ចុប្បន្ននេះ លទ្ធកម្មសាធារណៈនៅកម្ពុជាមានបួនប្រភេទគឺ លទ្ធកម្មលើទំនិញ លទ្ធកម្មលើសំណង់ លទ្ធកម្មលើសេវាកម្ម និងលទ្ធកម្មសម្រាប់សេវាប្រឹក្សាយោបល់។ វិធីសាស្រ្តដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈទាំងពីរ ដែលត្រូវបានចែងនៅក្រោមច្បាប់ស្តីពីលទ្ធកម្មសាធារណៈបច្ចុប្បន្ន និងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ គឺលទ្ធកម្មលក្ខណៈអន្តរជាតិ និងលទ្ធកម្មក្នុងស្រុក។[8] វិធីសាស្រ្តដេញថ្លៃផ្សេងទៀតរួមមាន៖ ១) ការដេញថ្លៃមានកម្រិត; ២) ការពិគ្រោះថ្លៃ និង ៣) ការស្ទង់តម្លៃ។[9] ក្នុងករណីពិសេស ច្បាប់ស្តីពីលទ្ធកម្មសាធារណៈនិងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈក៏បានចែងផងដែរអំពីវិធីសាស្រ្តលទ្ធកម្មដោយឡែក ដែលវិធីសាស្រ្តទាំងនេះអាចអនុវត្តបាន លុះត្រាតែមានអនុញ្ញាតជាមុនពី **ក.ស.ហ.វ.**។

ចំពោះស្ថាប័នមានសមត្ថកិច្ច ស្ថាប័នសំខាន់ៗដែលចូលរួមនៅក្នុងលទ្ធកម្មសាធារណៈរួមមាន៖១) ស្ថាប័នអនុវត្តលទ្ធកម្ម ២) ស្ថាប័នគ្រប់គ្រងលទ្ធកម្មសាធារណៈឬអាចហៅបានថាជា "និយ័តករ" ៣) ស្ថាប័នផ្តល់ជំនួយហិរញ្ញវត្ថុ និង ៤) ស្ថាប័នប្រើប្រាស់លទ្ធកម្មសាធារណៈ។ ស្ថាប័នអនុវត្តលទ្ធកម្មសាធារណៈត្រូវបង្កើតគណៈកម្មាធិការលទ្ធកម្មសាធារណៈ និងអង្គភាពលទ្ធកម្មសាធារណៈ ដែលទទួលខុសត្រូវផ្ទាល់ក្នុងវដ្តនៃនីតិវិធីលទ្ធកម្មសាធារណៈទាំងមូល ជាពិសេសនោះគឺការអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ។

វដ្តលទ្ធកម្មសាធារណៈមានបីដំណាក់កាលដូចជា៖ ដំណាក់កាលមុនការដេញថ្លៃ ដំណាក់កាលដេញថ្លៃ និងដំណាក់កាលក្រោយការដេញថ្លៃ។ វដ្តឬនីតិវិធីនៃលទ្ធកម្មសាធារណៈ ត្រូវបានចាប់ផ្តើមពីការរៀបចំនិងអនុម័តផែនការលទ្ធកម្មដោយស្ថាប័នថវិកានីមួយ សម្រាប់អនុវត្ត។ នៅក្នុងអំឡុងពេលនៃការអនុវត្តផែនការលទ្ធកម្មសាធារណៈ ជាបឋម ស្ថាប័នអនុវត្តលទ្ធកម្មសាធារណៈនឹងកំណត់បុរេលក្ខណៈសម្បត្តិសម្រាប់ជ្រើសរើសអ្នកដេញថ្លៃ ដើម្បីរៀបចំ

---

[7] អង្គការសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងលទ្ធកម្មសាធារណៈ("**OECD**"), *គោលការណ៍សុចរិតភាពរបស់អង្គការសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងលទ្ធកម្មសាធារណៈ:* ឆ្នាំ២០០៩ ដែលឯកសារនេះមាននៅ https://www.oecd.org/gov/ethics/48994520.pdf

[8] ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ១១; សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ១១

[9] ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ១២; សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ១២

សេចក្តីប្រកាសស្តីពីការដេញថ្លៃ ដើម្បីអញ្ជើញអ្នកដេញថ្លៃឱ្យដាក់ឯកសារដេញថ្លៃ របស់ពួកគេ។ នៅពេលដែលបានទទួលឯកសារដេញថ្លៃពីអ្នកដេញថ្លៃ គណៈកម្មាធិការលទ្ធកម្មនឹងវាយតម្លៃលើឯកសារដេញថ្លៃ ដើម្បីធ្វើការសម្រេចចិត្តជ្រើសរើសអ្នកដេញថ្លៃដែលមានបុរេលក្ខណៈសម្បត្តិនិងសំណើល្អប្រសើ ហើយឈ្មោះអ្នកដេញថ្លៃឈ្នះនោះនឹងត្រូវប្រកាសប្រាប់សាធារណជន។ ក្នុងករណីដែលមិនមានពាក្យបណ្តឹងពីអ្នកដេញថ្លៃដទៃទៀត ប្រឆាំងនឹងសេចក្តីសម្រេចលើការដេញថ្លៃនោះ អង្គភាពអនុវត្តលទ្ធកម្មនឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយអ្នកដេញថ្លៃឈ្នះ។

ដំណាក់កាលបន្ទាប់គឺជាការគ្រប់គ្រងលើការអនុវត្តកិច្ចសន្យា ដែលបានសម្រេចចុះ យោងលទ្ធផលនៃកិច្ចលទ្ធកម្ម។ មិនថាលទ្ធកម្មប្រភេទណាក៏ដោយ ការអនុវត្តកិច្ចសន្យាលទ្ធកម្មនឹងត្រូវបានវាយតម្លៃ ដើម្បីបញ្ជាក់ពីអនុលោមភាពជាមួយនឹងខចែងនិងលក្ខខណ្ឌដែលមាននៅក្នុងកិច្ចព្រមព្រៀង ក៏ដូចជាដើម្បីធានាគុណភាព។ ការទូទាត់ត្រូវធ្វើទៅតាមដំណាក់កាលនៃការបំពេញការងារឬប្រគល់វត្ថុដែលមាននៅក្នុងកិច្ចព្រមព្រៀង ដែលដំណាក់បញ្ចប់ គឺជាការទូទាត់ប្រាក់សរុបទៅឱ្យក្រុមហ៊ុនដែលបំពេញកិច្ចការបានចប់សព្វគ្រប់ឬប្រគល់ទទួលវត្ថុឬសេវាចុងក្រោយ ក្នុងគុណភាពដែលអាចទទួលយកបាន តាមកិច្ចព្រមព្រៀង។

បើទោះបីជានីតិវិធីលទ្ធកម្មសាធារណៈនៅកម្ពុជាមានលក្ខណៈធម្មតានិងទូទៅ ដូចនីតិវិធីលទ្ធកម្មសាធារណៈនៃប្រទេសដ៏ទៃ នីតិវិធីលទ្ធកម្មសាធារណៈនិងការអនុវត្តនោះក៏នៅតែមានបញ្ហាខ្លះដែលត្រូវយកចិត្តទុកដាក់ទៅលើការអនុវត្ត ដើម្បីធានាឱ្យបាននូវការអនុវត្តដ៏ប្រសើរតាមឧត្តមានុវត្តន៍អន្តរជាតិនិងគោលការណ៍ដែលមាននៅក្នុងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។

នៅផ្នែកខាងក្រោមនេះ របាយការណ៍នេះនឹងវាយតម្លៃលើក្របខណ្ឌច្បាប់បច្ចុប្បន្ននៃលទ្ធកម្មសាធារណៈ និងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ដើម្បីកំណត់អំពីចំណុចខ្វះខាតនិងបញ្ហាប្រឈម។ របាយការណ៍សិក្សានេះនឹងផ្តល់នូវអនុសាសន៍ ដើម្បីដោះស្រាយបញ្ហាឬបំពេញចំណុចខ្វះខាតដែលបានរកឃើញ។

## ផ្នែកទី២៖ ការវាយតម្លៃ និងលទ្ធផល

ការស្រាវជ្រាវនេះនឹងវាយតម្លៃលើលទ្ធកម្មសាធារណៈនៅកម្ពុជា ដោយបែងចែកការបកស្រាយជាប្រាំពីរចំណុចសំខាន់ៗដូចខាងក្រោម៖ ក).តម្លាភាព ខ). ការគ្រប់គ្រងល្អ គ). គណនេយ្យភាពនិងសុចរិតភាព ឃ). ការគ្រប់គ្រងនិងការត្រួតពិនិត្យ ង). សិទ្ធិប្តឹងតវ៉ាឬធ្វើឧបាស្រ័យ ច). ការចូលរួមពីសាធារណជន និង ឆ). ការបើកចំហនិងបរិយាបន្ន។

### ក. តម្លាភាព

ជាការអនុវត្តដ៏ល្អ តម្លាភាពគឺជាគន្លឹះដើម្បីលើកកម្ពស់សុចរិតភាពនិងកាត់បន្ថយហានិភ័យនៃអំពើពុករលួយ។ អាស្រ័យលើការជឿនលឿននៃបច្ចេកវិទ្យាឌីជីថលឬព័ត៌មានបច្ចេកវិទ្យា ប្រទេសជាច្រើនបានអនុវត្តគោលការណ៍តម្លាភាពតាមរយៈ ១). ការផ្សព្វផ្សាយព័ត៌មានតាមរយៈគេហទំព័របន្ថែមពីលើព័ត៌មានតាមប៉ុស្តិ៍ទូរទស្សន៍ ២). ការ

បង្កើតថ្នាលអនឡាញ ដើម្បីផ្សព្វផ្សាយរាល់ព័ត៌មានពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ ចាប់ពីនីតិវិធីដេញថ្លៃរហូតដល់នីតិវិធី អនុវត្ត និង ៣). នីតិវិធីផ្តល់ព័ត៌មានទៅកាន់អ្នកដេញថ្លៃលើសេចក្តីសម្រេចផ្តល់កិច្ចសន្យា និងពន្យល់ពីរបៀបនៃការសម្រេចចិត្ត។[10]

### ១. ការផ្សព្វផ្សាយព័ត៌មាន

នៅក្នុងវដ្តនៃលទ្ធកម្មសាធារណៈ មាត្រា៤០ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ បានតម្រូវឱ្យមានការផ្សព្វផ្សាយអំពីបុរេលក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃ សំរាប់ជ្រើសរើសអ្នកដេញថ្លៃ។ នៅដំណាក់កាលដេញថ្លៃ ច្បាប់និងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ បានតម្រូវឱ្យផ្សព្វផ្សាយជាសាធារណៈ នូវសេចក្តីជូនដំណឹងនៃឯកសារដេញថ្លៃនិងសេចក្តីកែសម្រួលនានា[11] ដោយបានបញ្ញត្តិថា ឱកាសចូលរួមការដេញថ្លៃត្រូវតែធ្វើការផ្សព្វផ្សាយដំណាលគ្នានឹងការបើកឯកសារដេញថ្លៃ។ ក៏ប៉ុន្តែ ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ រួមទាំងសេចក្តីព្រាងច្បាប់ថ្មី មិនបានចែងអំពីសេចក្តីតម្រូវនៃការផ្សព្វផ្សាយពាក់ព័ន្ធនឹងនីតិវិធីចរចានិងលទ្ធកម្មមានប្រភពតែមួយនោះទេ។

ពាក់ព័ន្ធនឹងវិធីសាស្រ្តផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃអាចធ្វើការផ្សព្វផ្សាយបានតាមរយៈ ១) គេហទំព័ររបស់ **ក.ស.ហ.វ.** ២) គេហទំព័រនិងក្តារបិតផ្សាយព័ត៌មានរបស់ស្ថាប័នអនុវត្តលទ្ធកម្ម និង ៣) សារព័ត៌មាន។[12] សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃត្រូវរួមបញ្ចូលនូវព័ត៌មានសំខាន់ៗដូចតទៅ៖ ១) ការពណ៌នាអំពីប្រភេទនិងបរិមាណនៃទំនិញ ការងារសាងសង់ ការងារជួសជុល ឬសេវាកម្ម ២) ឈ្មោះ អាសយដ្ឋាន អ៊ីមែល ទូរស័ព្ទ និងទូរសាររបស់អង្គភាពលទ្ធកម្ម ៣) វិធីសាស្រ្តលទ្ធកម្មសាធារណៈដែលត្រូវអនុវត្ត ៤) លក្ខខណ្ឌតម្រូវនៃបុរេលក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃ ៥) កាលបរិច្ឆេទលក់ ទទួល និងបើកឯកសារដេញថ្លៃ ៦) ការបញ្ជាក់អំពីលក្ខខណ្ឌតម្រូវនៃការតម្កល់ប្រាក់កក់ធានាការដេញថ្លៃនិងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា។[13] ព័ត៌មានតម្រូវសម្រាប់ការផ្សព្វផ្សាយភាគច្រើនគឺជាព័ត៌មានដែលធ្វើឡើងដោយផ្ទាល់មាត់ ដែលអាចមានភាពមិនច្បាស់លាស់។ ហេតុដូច្នេះ មាត្រា៤២ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងមាត្រា៤៤ នៃសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្ម

---

[10] អង្គការសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងលទ្ធកម្មសាធារណៈ(“OECD”), *កម្រងឧត្តមានុវត្តន៍នៃការអនុវត្តលទ្ធកម្មសាធារណៈសម្រាប់សុចរិតភាព*, ឆ្នាំ២០១៤ ទំព័រ ៤ ដល់ ៧

[11] ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ:, មាត្រា ៤០; សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ:, មាត្រា ៤២

[12] ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ:, មាត្រា ៤០; សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ:, មាត្រា ៤២

[13] ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ:, មាត្រា ៣៨

សាធារណៈបានចែងថា ស្ថាប័នអនុវត្តលទ្ធកម្មត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរអំពីឯកសារដេញថ្លៃ ឬធ្វើការប្រជុំមុនកាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃដើម្បីឆ្លើយបំភ្លឺ។ ក៏ប៉ុន្តែ ទាំងច្បាប់ស្តីពីលទ្ធកម្មសាធារណៈនិងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈមិនបានចែងអំពីគោលការណ៍ស្តីពីពេលវេលាគ្រប់គ្រាន់សម្រាប់ ១) ការផ្សព្វផ្សាយពីសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ និង ២) ការផ្តល់ការឆ្លើយតប ឬការប្រជុំដើម្បីឆ្លើយបំភ្លឺ នោះឡើយ។ ដូចគ្នានេះផងដែរ សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ មិនបានកំណត់អំពីលទ្ធភាពណាមួយសំរាប់ផ្តល់ការពន្យារពេលលើកាលបរិច្ឆេទឈប់ទទួលសំណើចំពោះអ្នកដេញថ្លៃដើម្បីដាក់សំណើដេញថ្លៃ ដើម្បីអនុញ្ញាតឱ្យអ្នកដេញថ្លៃនោះមានពេលវេលាគ្រប់គ្រាន់ក្នុងការពិចារណាលើការឆ្លើយបំភ្លឺចំពោះការដាក់សំណើរបស់ពួកគាត់ឡើយ។[14]

ជាក់ស្តែង ច្បាប់នៅប្រទេសកម្ពុជា តែងចែងឬបញ្ញត្តិអំពីគោលការណ៍នៃការអនុវត្ត ដែលនីតិវិធីនៃការអនុវត្តជាក់ស្តែងតែងត្រូវបានបញ្ញត្តិនៅក្នុងបទប្បញ្ញត្តិក្រោមច្បាប់ ដើម្បីរក្សាភាពបត់បែនខ្ពស់ តាមសេចក្តីតម្រូវនិងកាលៈទេសៈជាក់ស្តែង។ នៅក្នុងការអនុវត្ត បទប្បញ្ញត្តិទាំងនោះត្រូវបានដាក់អោយអនុវត្តដោយអាជ្ញាធរមានសមត្ថកិច្ច ខណៈពេលដែលរាល់ការបំពានត្រូវរងការពិន័យរដ្ឋបាល។ ដូចនេះ ការមិនកំណត់សេចក្តីតម្រូវជាអប្បបរមាណាមួយនៅក្រោមច្បាប់ នឹងអាចផ្តល់ជាផលវិបាកដល់ភាគីឯកជនក្នុងការប្តឹងទៅតុលាការ ដើម្បីទាមទារសំណង។ ហេតុដូច្នេះ លក្ខខណ្ឌនៃការឆ្លើយបំភ្លឺ ការពន្យារពេល និងលក្ខខណ្ឌតម្រូវនៃរយៈពេលសមរម្យខាងលើគួរត្រូវបានចែងនៅក្នុងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។

## ២).ថ្នាលអនឡាញសំរាប់លទ្ធកម្មសាធារណៈ

ការផ្សព្វផ្សាយព័ត៌មានស្តីពីលទ្ធកម្មសាធារណៈ នៅគ្រប់នីតិវិធីនៃកិច្ចលទ្ធកម្មសាធារណៈ គួរត្រូវបានធ្វើឡើងតាមរយៈថ្នាលអនឡាញ។ ជាឧទាហរណ៍ រដ្ឋាភិបាលរបស់ប្រទេសអូស្ត្រាលី បានបង្កើតគេហទំព័រមួយ ដែលផ្តល់នូវព័ត៌មានប្រមូលផ្តុំពាក់ព័ន្ធនឹងឱកាសធ្វើពាណិជ្ជកម្មជាមួយរដ្ឋាភិបាលអូស្ត្រាលី ផែនការលទ្ធកម្មប្រចាំឆ្នាំ និងរាល់កិច្ចសន្យាដែលត្រូវបានចុះហត្ថលេខា។[15] ដូចដែលបានរៀបរាប់ខាងលើ ច្បាប់ស្តីពីលទ្ធកម្មសាធារណៈនិងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ តម្រូវឱ្យមានការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃនិងសេចក្តីកែប្រែនានា នៅលើគេហទំព័ររបស់ ក.ស.ហ.វ និងគេហទំព័ររបស់ស្ថាប័នអនុវត្តលទ្ធកម្មសាធារណៈ ក៏ប៉ុន្តែ ព័ត៌មានសំខាន់ផ្សេងៗទៀតនៃលទ្ធកម្មសាធារណៈ រួមមានកិច្ចសន្យាដែលបានចុះហត្ថលេខាជាដើម មិនត្រូវបានទាមទារឱ្យមានការផ្សព្វផ្សាយនោះឡើយ។

[14] អង្គការសហប្រជាជាតិ, *គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ*, ខែមិថុនា ឆ្នាំ២០១៤, មាត្រា ១៤

[15] គេហទំព័រ https://www.tenders.gov.au/

តម្លាភាពនៃលទ្ធកម្មមិនគួរតម្រូវឱ្យមានត្រឹមតែសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃប៉ុណ្ណោះទេ ដែលលើសពីនេះ ការផ្សព្វផ្សាយជាសាធារណៈគួរមានសម្រាប់នីតិវិធីលទ្ធកម្មសាធារណៈទាំងមូល ចាប់ពីដំណាក់កាលបុរេលទ្ធកម្មសាធារណៈរហូតដល់ការបញ្ចប់កិច្ចលទ្ធកម្មសាធារណៈ។ លក្ខខណ្ឌតម្រូវនៃតម្លាភាព សំរាប់អំឡុងពេលនៃនីតិវិធីលទ្ធកម្មទាំងមូល ត្រូវមានតុល្យភាពជាមួយនឹងកាតព្វកិច្ចការរក្សាការសម្ងាត់។ សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈគួរផ្តល់នូវបញ្ញត្តិដែលគ្រប់គ្រងកាតព្វកិច្ចរក្សាការសម្ងាត់របស់បុគ្គលពាក់ព័ន្ធ និងនិយមន័យនៃព័ត៌មានដែលត្រូវបានចាត់ទុកជាពត៌មានសម្ងាត់ដែលមិនអាចត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ ពាក់ព័ន្ធជាមួយនឹងនិយមន័យនៃ “ព័ត៌មានសម្ងាត់” សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ អាចផ្តល់នូវបញ្ជីបើកចំហនូវអ្វីដែលត្រូវបានចាត់ទុកជាព័ត៌មានសម្ងាត់។ ដើម្បីបង្ហាញអំពីបទប្បញ្ញត្តិលើកាតព្វកិច្ចរក្សាការសម្ងាត់ សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈគួរពិចារណាទៅលើគម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ បានបែងចែកជាពីររវាង “ឯកសារសម្ងាត់” និង “ព័ត៌មានសម្ងាត់”។ មាត្រា២៤ នៃ*គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ របស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ* ចែងដូចខាងក្រោម៖

> **មាត្រា២៤- ការសម្ងាត់**
>
> ១. នៅក្នុងការទំនាក់ទំនងជាមួយអ្នកផ្គត់ផ្គង់ឬអ្នកទទួលការឬជាមួយបុគ្គលណាមួយ ស្ថាប័នអនុវត្តលទ្ធកម្មមិនត្រូវផ្សព្វផ្សាយព័ត៌មានណាមួយ ប្រសិនបានការមិនផ្សព្វផ្សាយព័ត៌មាននោះ គឺមានភាពចាំបាច់សម្រាប់ការពារផលប្រយោជន៍សន្តិសុខដ៏សំខាន់របស់រដ្ឋ ឬប្រសិនបើការផ្សព្វផ្សាយព័ត៌មាននោះផ្ទុយនឹងច្បាប់ រារាំងការអនុវត្តច្បាប់ បង្កព្យសនកម្មដល់ផលប្រយោជន៍ស្របច្បាប់នៃអាជីវកម្មរបស់អ្នកផ្គត់ផ្គង់ឬអ្នកទទួលការ ឬរារាំងការប្រកួតប្រជែងដោយស្មោះត្រង់ លើកលែងតែការផ្សព្វផ្សាយព័ត៌មាននោះត្រូវបានបញ្ជាដោយ [ឈ្មោះរបស់តុលាការ] ឬដោយ[ឈ្មោះរបស់ស្ថាប័នពាក់ព័ន្ធតែងតាំងដោយរដ្ឋ] ដែលជាកម្មវត្ថុនៃលក្ខខណ្ឌរបស់បទបញ្ជានោះ។
>
> ២. ក្រៅតែពីពេលដែលផ្តល់ឬបោះពុម្ពផ្សាយព័ត៌មានអនុលោមតាមកថាខណ្ឌទី២ និងទី១០ នៃមាត្រា២២ និងមាត្រា២៣ មាត្រា២៣ មាត្រា២៥ និងមាត្រា៤២នៃច្បាប់នេះ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវត្រួតពិនិត្យសំណុំបែបបទនៃបុរេលក្ខណៈសម្បត្តិជ្រើសរើស ព្រមទាំងបញ្ជូនសំណុំបែបបទនោះ

ដោយប្រុងប្រយ័ត្ន ដើម្បីចៀសវាងការបែកធ្លាយព័ត៌មានទៅកាន់អ្នកផ្គត់ផ្គង់ឬអ្នកទទួលការដែលជាដៃគូប្រកួតប្រជែង ឬបុគ្គលផ្សេងទៀតដែលមិនត្រូវបានអនុញ្ញាតឱ្យដឹងអំពីព័ត៌មាននេះ។

៣. ការពិភាក្សា ការទំនាក់ទំនង ការចរចា ឬកិច្ចសន្ទនាណាមួយរវាងស្ថាប័នអនុវត្តលទ្ធកម្ម និងអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការ អនុលោមតាមកថាខណ្ឌទី៣ នៃមាត្រា៤៨ និងចាប់ពីមាត្រា៤៩ ដល់មាត្រា៥២នៃច្បាប់នេះ ត្រូវចាត់ទុកជាការសម្ងាត់។ លើកលែងតែមានការតម្រូវច្បាប់ ឬការបញ្ជាដោយ [ឈ្មោះរបស់តុលាការមួយ] ឬដោយ [ឈ្មោះរបស់ស្ថាប័នពាក់ព័ន្ធតែងតាំងដោយរដ្ឋ] គ្មានភាគីណាមួយនៃការពិភាក្សា ការទំនាក់ទំនង ការចរចា ឬកិច្ចសន្ទនានោះ អាចផ្សព្វផ្សាយព័ត៌មានទៅឱ្យបុគ្គលផ្សេងទៀត អ្នកបច្ចេកទេស តម្លៃ ឬព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងការពិភាក្សា ការទំនាក់ទំនង ការចរចា ឬកិច្ចសន្ទនា ដោយមិនមានការព្រមព្រៀងពីភាគីម្ខាងទៀតឡើយ។

៤. ផ្អែកលើសេចក្តីតម្រូវនៅក្នុងកថាខណ្ឌទី១នៃមាត្រានេះ នៅក្នុងលទ្ធកម្មសាធារណៈដែលពាក់ព័ន្ធនឹងឯកសារសម្ងាត់ ស្ថាប័នអនុវត្តលទ្ធកម្មសាធារណៈអាច៖

ក. ដាក់កាតព្វកិច្ចរក្សាការសម្ងាត់ដល់អ្នកផ្គត់ផ្គង់ឬអ្នកទទួលការ និង

ខ. ទាមទារឱ្យអ្នកផ្គត់ផ្គង់ឬអ្នកទទួលការធានាថា ខ្លួននឹងបន្តអនុលោមជាមួយនឹងកាតព្វកិច្ចរក្សាការសម្ងាត់។

*គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ* បានលើកឡើងអំពីតម្រូវការរក្សាការសម្ងាត់ ដោយធ្វើការពិចារណាលើជ្រុងផ្សេងៗគ្នា ដូចខាងក្រោម៖

- ទំនាក់ទំនងនៅក្នុងកិច្ចលទ្ធកម្មពីស្ថាប័នអនុវត្តលទ្ធកម្ម ដែលទទួលរក្សាការសម្ងាត់ ត្រូវធ្វើឡើងដោយមធ្យោបាយសមរម្យមួយ ដើម្បីរក្សាសុវត្ថិភាពនៃសុក្រិត្យភាព សុចរិតភាព និងការសម្ងាត់នៃព័ត៌មានពាក់ព័ន្ធ។[16]
- គម្រូច្បាប់នេះទទួលស្គាល់នូវវិជ្ជភាពផ្សេងៗគ្នានិងមែកធាងនៃច្បាប់ពាក់ព័ន្ធ ជាពិសេសច្បាប់ពាក់ព័ន្ធនឹងពាណិជ្ជកម្មអេឡិចត្រូនិច ការគ្រប់គ្រងការកត់ត្រា នីតិវិធីតុលាការ ការប្រកួតប្រជែង ការការពារទិន្នន័យ និងការសម្ងាត់ កម្មសិទ្ធិបញ្ញានិងសិទ្ធិអ្នកនិពន្ធ។[17]

---

[16] អង្គការសហប្រជាជាតិ, *គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ*, ខែមិថុនា ឆ្នាំ២០១៤, មាត្រា ៧

[17] សេចក្តីណែនាំក្នុងការអនុម័តគម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, យោបល់នៃមាត្រាទី ៧

- ការសម្ងាត់ក្នុងអំឡុងពេលនីតិវិធីលទ្ធកម្មសាធារណៈ សំដៅដល់ ស្ថានភាពដែលស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវបានហាមឃាត់មិនឱ្យផ្សព្វផ្សាយព័ត៌មានសម្ងាត់ក្នុងនីតិវិធីលទ្ធកម្មទៅកាន់អ្នកផ្គត់ផ្គង់ អ្នកម៉ៅការ ឬបុគ្គលផ្សេងទៀត ដែលព័ត៌មានសម្ងាត់នៅត្រង់នេះសម្តៅដល់ព័ត៌មានដែលត្រូវបានផ្តល់ឱ្យនៅក្នុងអំឡុងពេលនៃនីតិវិធីលទ្ធកម្មសាធារណៈ រួមបញ្ចូលព័ត៌មានដែលការផ្សព្វផ្សាយអាចនឹង "បង្កពន្យសនកម្មលើផលប្រយោជន៍ស្របច្បាប់នៃអាជីវកម្មរបស់អ្នកផ្គត់ផ្គង់ឬអ្នកទទួលការ" ឬការផ្សព្វផ្សាយព័ត៌មាននោះនឹង"រារាំងដល់ការប្រកួតប្រជែងដោយស្មោះត្រង់" លើកលែងតែការផ្សព្វផ្សាយព័ត៌មានដែលត្រូវបានបញ្ជាដោយដីកាសម្រេចរបស់តុលាការឬស្ថាប័នពាក់ព័ន្ធដែលតែងតាំងដោយរដ្ឋ។[18] សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈមិនបានចែងអំពីតម្រូវការរក្សាការសម្ងាត់ណាមួយពាក់ព័ន្ធនឹងការទំនាក់ទំនងពីស្ថាប័នអនុវត្តលទ្ធកម្មនោះទេ។ ដូចនេះ កង្វះខាតនេះអាចទុកលទ្ធភាពឱ្យស្ថាប័នអនុវត្តលទ្ធកម្មបង្ហាញព័ត៌មានណាមួយពាក់ព័ន្ធនឹងនីតិវិធីលទ្ធកម្មទៅបុគ្គលណាមួយ ដែលធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍របស់បុគ្គលផ្សេងទៀតក្នុងនីតិវិធីលទ្ធកម្ម ដោយសារតែនិយមន័យនៃព័ត៌មានឬឯកសារសម្ងាត់នៅក្រោមសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ មាត្រា៤៧ នៅមានភាពមិនទាន់ច្បាស់លាស់។ ជាងនេះទៅទៀត ភាពមិនច្បាស់លាស់នៃការកំណត់អត្ថសញ្ញាណនៃព័ត៌មានសម្ងាត់ អាចរារាំងមិនឱ្យស្ថាប័នអនុវត្តលទ្ធកម្មផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយ តាមគោលការណ៍តម្លាភាព។

### ៣). ការបកស្រាយពីសេចក្តីសម្រេចប្រគល់កិច្ចសន្យា

ជាឧត្តមានុវត្តន៍ សេចក្តីសម្រេចទទួលយកអ្នកឈ្នះក្នុងការដេញថ្លៃ ត្រូវបានជូនជាដំណឹងដល់អ្នកដេញថ្លៃផ្សេងៗទៀត ព្រមទាំងផ្សព្វផ្សាយជាសាធារណៈនៅពេលដែលកិច្ចសន្យាលទ្ធកម្មត្រូវបានចុះហត្ថលេខា។[19] ឧទាហរណ៍ មាត្រា២៣(១) នៃ***គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ*** បានចែងថា "នៅពេលដែលកិច្ចសន្យាលទ្ធកម្មចូលជាធរមានឬត្រូវបានចុះហត្ថលេខា ស្ថាប័នអនុវត្តលទ្ធកម្មត្រូវផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យាលទ្ធកម្មឬកិច្ចព្រមព្រៀងនោះ ដោយបញ្ជាក់អំពីឈ្មោះរបស់អ្នកផ្គត់ផ្គង់ឬអ្នកទទួលការ និងតម្លៃនៃកិច្ចសន្យា ប្រសិនបើមាន។"

មាត្រា៤៧ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងមាត្រា៥០ នៃសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ តម្រូវឱ្យស្ថាប័នអនុវត្តលទ្ធកម្មចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាទៅឱ្យអ្នកដេញថ្លៃ

---

[18]អង្គការសហប្រជាជាតិ, *គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ*, ខែមិថុនា ឆ្នាំ២០១៤, មាត្រា ២៤

[19] អង្គការសហប្រជាជាតិ, *គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ*, ខែមិថុនា ឆ្នាំ២០១៤, មាត្រា ២២ និង មាត្រា ២៣

ឈ្នះ ដោយចម្លងជូនទៅគ្រប់អ្នកដេញថ្លៃផ្សេងៗទៀត បន្ទាប់ពីបញ្ចប់ការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ។ ការតម្រូវដោយច្បាប់បែបនេះ គឺមានលក្ខណៈសមស្របជាមួយនឹងឧត្តមានុវត្តន៍អន្តរជាតិ។ ក៏ប៉ុន្តែ ច្បាប់និងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈនៅកម្ពុជា មិនបានចែងពាក់ព័ន្ធនឹងការផ្សព្វផ្សាយអំពីការចូលជាធរមាននៃកិច្ចសន្យាលទ្ធកម្មនោះឡើយ។ ដូចគ្នាផងដែរ ច្បាប់និងបទប្បញ្ញត្តិក៏មិនបានតម្រូវឱ្យស្ថាប័នអនុវត្តលទ្ធកម្មផ្តល់នូវហេតុផលជាក់លាក់ចំពោះអ្នកចាញ់ការដេញថ្លៃនោះទេ។ តាមការបញ្ជាក់ដោយផ្ទាល់របស់មន្ត្រីមានសមត្ថកិច្ច តម្រូវការនៃការបកស្រាយអំពីលទ្ធផលនៃការដេញថ្លៃនិងការជូនដំណឹងដល់អ្នកដេញថ្លៃដែលមិនបានឈ្នះការដេញថ្លៃ នឹងមានដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។

## ខ. ការគ្រប់គ្រងល្អ

ឧត្តមានុវត្តន៍ឬគោលការណ៍មួយទៀតនៃលទ្ធកម្មសាធារណៈគឺ «គោលការណ៍សន្សំសំចៃ»។ យោងតាមសេចក្តីណែនាំស្តីពីការធ្វើកិច្ចលទ្ធកម្មសាធារណៈក្រោមគម្រោងហិរញ្ញប្បទានខាងក្រៅ គោលការណ៍នេះសំដៅដល់ "ការប្រើប្រាស់ធនធានដោយមានប្រសិទ្ធភាពនិងការសន្សំសំចៃខ្ពស់ ដើម្បីទាមទារឱ្យមានការវាយតម្លៃលើថ្លៃចំណាយនិងផលចំណេញ ហើយអាចរួមបញ្ចូលនូវការពិចារណាលើវដ្តនៃការចំណាយ និងកត្តាចូលរួមដែលមិនអស់ថ្លៃចំណាយដូចជាការគិតគូរពីបរិស្ថាននិងសង្គមជាដើម"។[20] ក៏ប៉ុន្តែច្បាប់ស្តីពីលទ្ធកម្មសាធារណៈ មិនបានចែងឱ្យច្បាស់ពីយន្តការតម្រូវសម្រាប់ការការពារបរិស្ថាន សង្គម និងអភិបាលកិច្ចសំរាប់រាល់អ្នកដេញថ្លៃ ដែលត្រូវគោរពតាមជាចាំបាច់ដោយផ្អែកលើអត្តចរិកនៃគម្រោងនីមួយៗ។ យ៉ាងណាមិញ មាត្រា៥៤ នៃសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈចែងពី "លទ្ធកម្មប្រកបដោយចីរភាព" នៅដំណាក់កាលអនុវត្ត ដោយមិនបានបញ្ជាក់ច្បាស់អំពីនិយមន័យនៃលទ្ធកម្មប្រកបដោយចីរភាពនោះទេ ហើយមន្ត្រីមានសមត្ថកិច្ចបានបញ្ជាក់ថា និយមន័យជាគោលការណ៍នៃពាក្យ"លទ្ធកម្មប្រកបដយចីរភាព"នឹងមានកំណត់នៅក្នុងច្បាប់ ហើយរាល់នីតិវិធីនិងការអនុវត្តលម្អិតនឹងមានបញ្ជាក់បន្ថែមនៅក្នុងបទប្បញ្ញតិក្រោមច្បាប់។

ច្បាប់ស្តីពីលទ្ធកម្មសាធារណៈបានចែងថា ផែនការលទ្ធកម្មត្រូវមានសង្គតិភាពនឹងកញ្ចប់ថវិកាប្រចាំឆ្នាំ។[21] ផ្អែកលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា សម្រាប់ជាគោលបំណងនៃការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីថវិកាប្រចាំឆ្នាំ អង្គភាពថវិកានីមួយទទួលខុសត្រូវធ្វើគម្រោងចិរការរបស់ខ្លួន ដែលរួមបញ្ចូលថវិកាសំរាប់គម្រោងលទ្ធកម្មសាធារណៈនេះផងដែរ។ ពាក់ព័ន្ធនឹងការធ្វើគម្រោងនេះ គោលការណ៍ណែនាំពាក់ព័ន្ធនឹងការដាក់បញ្ចូលគម្រោងលទ្ធកម្មដែលកំពុងដំណើរការទៅក្នុងផែនការថវិកាថ្មី និងការអនុវត្តក្របខណ្ឌថវិការយៈពេលមធ្យម នៅមានកម្រិត។ ជាលទ្ធផលភាពខ្វះខាតទាំងនេះអាចចោទជាបញ្ហាក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពាក់ព័ន្ធនឹងខ្ទង់ចំណាយសម្រាប់ទ្រទ្រង់

---

[20] គោលការណ៍ណែនាំសម្រាប់លទ្ធកម្មសាធារណៈរបស់គម្រោងហិរញ្ញប្បទានពីប្រភពខាងក្រៅ, វគ្គទី១ ទំព័រទី៧

[21] ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ៣១; សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ៣២

ការចំណាយទៅលើគម្រោងលទ្ធកម្មដែលកំពុងដំណើរការលើសពីឆ្នាំហិរញ្ញវត្ថុមួយ។ បញ្ហានេះអាចត្រូវបានកែសម្រួលបន្ទាប់ពីមានការអនុម័តយ៉ាងពេញលេញទៅលើ ១) ក្របខណ្ឌថវិការយៈពេលមធ្យម ២) ការធ្វើសមាហរណកម្មរវាងថវិកាមូលធននិងថវិកាចរន្ត និង ៣) ការធ្វើសមាហរណកម្មរវាងការរៀបចំផែនការនិងការអនុវត្តលទ្ធកម្មសាធារណៈជាមួយការរៀបចំផែនការថវិកា ការអនុវត្តថវិកា និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។ ហេតុដូច្នេះ ច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងបទប្បញ្ញត្តិផ្សេងទៀតអាចពិចារណាទៅលើ ១) ការកែទម្រង់ឆ្ពោះទៅកាន់ការអនុវត្តក្របខណ្ឌចំណាយរយៈពេលមធ្យម សំរាប់គម្រោងលទ្ធកម្មសាធារណៈ ដែលអនុវត្តចំពោះគម្រោងរយៈពេលវែងលើសពីមួយឆ្នាំហិរញ្ញវត្ថុ ២) សេចក្តីតម្រូវឱ្យមានផែនការចំណាយសង្ខេបសំរាប់ទ្រទ្រង់គម្រោងលទ្ធកម្មសាធារណៈភ្ជាប់ជាមួយនឹងឯកសារថវិកាប្រចាំឆ្នាំ ដើម្បីឱ្យសភាពិនិត្យ និងសម្រាប់ផ្សព្វផ្សាយជាសាធារណៈ និង ៣) សេចក្តីតម្រូវឱ្យមានរបាយការណ៍អនុវត្តលទ្ធកម្មសាធារណៈសង្ខេបភ្ជាប់ជាមួយនឹងឯកសារថវិកាប្រចាំឆ្នាំដើម្បីឱ្យសភាពិនិត្យ និងសម្រាប់ផ្សព្វផ្សាយជាសាធារណៈ។

លើសពីនេះទៅទៀត ជាឧត្តមានុវត្តន៍មួយផងដែរនោះ គណៈកម្មាធិការលទ្ធកម្មមិនត្រូវមានភាពលម្អៀងចំពោះអ្នកដេញថ្លៃណាមួយឡើយ ហើយមិនត្រូវទទួលរងឥទ្ធិពលដោយកត្តាខាងក្រៅណាមួយក្នុងការធ្វើសេចក្តីសម្រេចនោះទេ។ ពាក់ព័ន្ធនឹងការការពារពីការទទួលរងឥទ្ធិពលមិនត្រឹមត្រូវ *ក្រមសីលធម៌ស្តីពីលទ្ធកម្ម* តម្រូវឱ្យ គណៈកម្មាធិការលទ្ធកម្មមានអព្យាក្រឹត្យភាព ក្នុងការធ្វើសេចក្តីសម្រេចចិត្ត។[22] ក៏ប៉ុន្តែ របាយការណ៍នេះមិនអាចកំណត់នូវយន្តការជាក់លាក់ណាមួយសម្រាប់ផ្តល់ការការពារដល់គណៈកម្មាធិការលទ្ធកម្ម ប្រឆាំងនឹងឥទ្ធិពលមិនត្រឹមត្រូវពីបុគ្គលមានអំណាចនោះឡើយ។ ការមិនមាននូវបទប្បញ្ញត្តិជាក់លាក់បែបនេះ អាចបង្កជាហានិភ័យនូវការជះឥទ្ធិពលមិនត្រឹមត្រូវលើគណៈកម្មាធិការលទ្ធកម្មសាធារណៈ។ ជាឧទាហរណ៍ បន្ថែមពីលើកាតព្វកិច្ចធ្វើសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ដើម្បីបញ្ជៀប់ពីការធ្វើសកម្មភាពណាមួយដែលអាចផ្តល់អត្ថប្រយោជន៍ឬការអនុវត្តពិសេសលើអ្នកដេញថ្លៃណាម្នាក់ ភ្នាក់ងារលទ្ធកម្មនៃសហព័ន្ធអូទ្រីស ត្រូវបានហាមឃាត់ពីការទទួលយកអំណោយនៅក្នុងគ្រប់ទម្រង់ រួមទាំងនៅក្នុងឱកាសពិសេសដូចជាពិធីបុណ្យណូអែលជាដើម ពីអ្នកដេញថ្លៃ។[23]

ដោយហេតុថាអំពើពុករលួយអាចត្រូវបានចាត់ទុកជាបញ្ហាប្រឈមដ៏សំខាន់ក្នុងការធ្វើសេចក្តីសម្រេច អនុសញ្ញានៃអង្គការសហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយ តម្រូវឱ្យរដ្ឋផ្សព្វផ្សាយកម្មវិធីបណ្តុះបណ្តាលទៅកាន់មន្ត្រីសាធារណៈដើម្បីជាមធ្យោបាយក្នុងការផ្សព្វផ្សាយចំណេះដឹងពីហានិភ័យនៃអំពើពុករលួយនៅក្នុងការអនុវត្តតួនាទីរបស់ខ្លួន។[24] ពាក់ព័ន្ធនឹងវិធាននេះ ប្រទេសអាល្លឺម៉ង់បានរៀបចំសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលស្តីពីការប្រឆាំងអំពើពុករលួយ

---

[22] ប្រកាសលេខ ៩៨៧ ស.ហ.វ/ប្រ.ក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ស្តីពី *ក្រមសីលធម៌ស្តីពីលទ្ធកម្ម* , ប្រកា ៥.

[23] OECD, *កម្រងឧត្តមានុវត្តន៍នៃការអនុវត្តលទ្ធកម្មសាធារណៈសម្រាប់សុចរិតភាព*, ឆ្នាំ២០១៤ ទំព័រ ២០

[24] អនុសញ្ញានៃអង្គការសហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយ, មាត្រា ៧, ឯកសារនេះមាននៅ: https://www.unodc.org/documents/brussels/UN_Convention_Against_Corruption.pdf

ទៅកាន់មន្ត្រីរបស់ខ្លួន។[25] សិក្ខាសាលានិងវគ្គបណ្ដុះបណ្ដាលទាំងនេះ ផ្ដល់ឱ្យមន្ត្រីនូវចំណេះដឹងពីហានិភ័យក្នុងការប្រព្រឹត្តអំពើកេងប្រវ័ញ្ច សកម្មភាពទប់ស្កាត់អំពើទាំងនោះ និងនីតិវិធីរាយការណ៍អំពីការបំពាន។

ពាក់ព័ន្ធនឹងនីតិវិធីរាយការណ៍ ការិយាល័យប្រឆាំងឧក្រិដ្ឋកម្មនិងគ្រឿងញៀនរបស់អង្គការសហប្រជាជាតិបានបញ្ជាក់ថា តួនាទីមួយក្នុងចំណោមតួនាទីទាំងអស់របស់សង្គមស៊ីវិល ទាក់ទងនឹងលទ្ធកម្មសាធារណៈ គឺពាក់ព័ន្ធនឹងបញ្ហានៃការរាយការណ៍ពីខាងក្រៅ ដែលទាមទារឱ្យមាននីតិវិធីទទួលយកការរាយការណ៍របស់បុគ្គលរាយការណ៍។[26] បន្ថែមពីនេះ នៅក្នុងប្រទេសបារាំង ការិយាល័យកណ្ដាលប្រឆាំងអំពើពុករលួយ បានរៀបចំការបណ្ដុះបណ្ដាលដោយលើកយកករណីសិក្សាជាឧទាហរណ៍ ដើម្បីបង្ហាញអំពីស្ថានភាពដែលចោទជាបញ្ហាលើភាពមិនប្រក្រតីនៅក្នុងនីតិវិធីលទ្ធកម្មនិងវិធីសាស្ត្រក្នុងការដោះស្រាយស្ថានភាពទាំងនោះ។[27]

## គ. គណនេយ្យភាព និងសុចរិតភាព

ច្បាប់និងសេចក្តីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ បានកំណត់នូវគោលការណ៍គណនេយ្យភាព ជាគោលការណ៍ដើម្បីអនុវត្តនៅក្នុងនីតិវិធីលទ្ធកម្មសាធារណៈ។[28] ដើម្បីធានាឱ្យបាននូវគណនេយ្យភាពនៅក្នុងនីតិវិធីលទ្ធកម្មសាធារណៈ ស្ថាប័នអនុវត្តលទ្ធកម្មនិងមន្ត្រីលទ្ធកម្មត្រូវ៖

- ធានាថា វចនាសម្ព័ន្ធនិងការទទួលខុសត្រូវលើការអនុវត្តក្នុងលទ្ធកម្មសាធារណៈមានភាពច្បាស់លាស់ និង
- រៀបចំនិងអនុម័តវិធីសាស្រ្ត ដើម្បីចែងអោយបានជាក់លាក់អំពីការទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះលទ្ធកម្មសាធារណៈ។

**ពាក់ព័ន្ធនឹងភាពច្បាស់លាស់នៃខ្សែចង្វាក់នៃការទទួលខុសត្រូវ៖**

- សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ កំណត់ការដេញថ្លៃប្រកួតប្រជែងជាសាធារណៈជា “*វិធីសាស្ត្រលទ្ធកម្មសំរាប់ជ្រើសរើស*” ដែលត្រូវធ្វើឡើងនៅក្នុងលទ្ធកម្មសាធារណៈ (មាត្រា១១)។ យ៉ាងណាមិញ *គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ* បានកំណត់ការដេញថ្លៃជាសាធារណៈជា *វិធីសាស្រ្តលទ្ធកម្មតម្រូវ*។ *វិធីសាស្ត្រលទ្ធកម្មតម្រូវ* គឺជាវិធីសាស្រ្ត

[25] OECD, *កម្រងឧត្តមានុវត្តន៍នៃការអនុវត្តលទ្ធកម្មសាធារណៈសម្រាប់សុចរិតភាព*, ឆ្នាំ២០១៤ ទំព័រ ២៣

[26] **UNDOC**, កិច្ចខិតខំប្រឹងប្រែងរបស់សង្គមស៊ីវិលក្នុងការចូលរួមពង្រឹងកិច្ចលទ្ធកម្មសាធារណៈនិងប្រព័ន្ធការពារនីតិវិធីរាយការណ៍នៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង, ឯកសារនេះមាននៅ https://www.unodc.org/unodc/en/ngos/civil-society-efforts-contribute-to-strengthening-public-procurement-and-whistle-blower-protection-systems-in-southern-africa.html

[27] OECD, *កម្រងឧត្តមានុវត្តន៍នៃការអនុវត្តលទ្ធកម្មសាធារណៈសម្រាប់សុចរិតភាព*, ឆ្នាំ២០១៤ ទំព័រ ២៤

[28] ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ១; សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ២

ដែលត្រូវយកមកអនុវត្តដោយគ្មានលក្ខខណ្ឌ ហើយត្រូវយកមកប្រើប្រាស់គ្រប់ពេលវេលា។ ហេតុដូច្នេះ ការប្រើប្រាស់វិធីសាស្ត្រលទ្ធកម្មផ្សេងពីនេះតម្រូវឱ្យមានការបញ្ជាក់ហេតុផលពិសេសច្បាស់លាស់។[29]

- **ការទិញទំនិញជាកញ្ចប់៖** ខណៈដែលច្បាប់និងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ បានចែងថា ស្ថាប័នអនុវត្តលទ្ធកម្ម នៅពេលអនុវត្តផែនការលទ្ធកម្ម ត្រូវចងជាកញ្ចប់លទ្ធកម្ម ចំពោះមុខសញ្ញាលទ្ធកម្ម ដែលស្ថិតក្នុងប្រភេទដូចគ្នា និងមានលក្ខណៈដូចគ្នាឬប្រហាក់ប្រហែលគ្នា។ យ៉ាងណាមិញ ច្បាប់និង សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈមិនបានលើកឡើងអំពីលទ្ធភាពដែលស្ថាប័នអនុវត្តលទ្ធកម្ម មួយអាចធ្វើលទ្ធកម្មទំនិញនិង/ឬសេវាសរុប ជំនួសឱ្យស្ថាប័នអនុវត្តលទ្ធកម្មផ្សេងទៀតនោះទេ។[30]
- **ការលុបចោលលទ្ធកម្ម៖** ច្បាប់និងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈមិនបានចែងអំពីនីតិវិធីដើម្បី លុបចោលកិច្ចលទ្ធកម្មសាធារណៈនោះឡើយ។ ខណៈពេលដែល *គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ របស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ* បានទទួលស្គាល់សិទ្ធិឥត លក្ខខណ្ឌរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ក្នុងការលុបចោលកិច្ចលទ្ធកម្មសាធារណៈ មុននឹងការទទួលយក សំណើដែលទទួលបានជោគជ័យ។[31] ជាអនុសាសន៍ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវផ្តល់សេចក្តីថ្លែងការណ៍ ខ្លីមួយអំពីហេតុផលសម្រាប់ការសម្រេចលុបចោលកិច្ចលទ្ធកម្មសាធារណៈ ដែលវិធីសាស្ត្រក្នុងការផ្តល់ សេចក្តីថ្លែងការណ៍នេះត្រូវមានភាពគ្រប់គ្រាន់ ហើយអាចធ្វើការត្រួតពិនិត្យឡើងវិញបានទៅលើសេចក្តី សម្រេចនោះ។
- **ការផ្សព្វផ្សាយជាសាធារណៈនូវការប្រគល់កិច្ចសន្យា៖** ខណៈដែលសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ចែងថា សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃត្រូវធ្វើជាសាធារណៈតាមរយៈមធ្យោបាយជាច្រើន ដែលសេចក្តី តម្រូវនេះ មិនបានដាក់ជាកាតព្វកិច្ចឱ្យធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យាលទ្ធកម្ម ចំពោះតែអ្នកដេញថ្លៃឈ្នះនិងអ្នកដេញថ្លៃចាញ់តែប៉ុណ្ណោះ[32]។ លើកលែងតែក្នុងករណីពិសេសផ្អែកលើ តម្លៃក្នុងកម្រិតកំណត់ដែលចែងដោយច្បាប់ជាតិ *គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈរបស់គណៈកម្មការ នៃអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ* បានចែងអំពីកាតព្វកិច្ចសំរាប់ស្ថាប័នអនុវត្ត លទ្ធកម្ម ក្នុងការផ្សព្វផ្សាយភ្លាមនូវសេចក្តីជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យានិងព័ត៌មានលម្អិត។[33]

---

[29] អង្គការសហប្រជាជាតិ, សេចក្តីណែនាំស្តីពីការអនុម័តគម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, យោបល់លើ មាត្រា ២៨

[30] ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ៣២; សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ៣៣

[31] អង្គការសហប្រជាជាតិ, សេចក្តីណែនាំស្តីពីការអនុម័តគម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, យោបល់លើ មាត្រា ១៩

[32] សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ៤២ និង មាត្រា ៥០

[33] គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ២៣

- **ឯកសារកត់ត្រានីតិវិធីលទ្ធកម្ម៖** *គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ* បានចែងអំពីព័ត៌មានសំខាន់នីមួយៗដែលត្រូវកត់ត្រាទុកដោយស្ថាប័នអនុវត្តលទ្ធកម្ម។ ចំណុចដែលសំខាន់នោះគឺ សេចក្តីតម្រូវឱ្យមានការចែងអំពី"ហេតុផលនិងស្ថានភាពសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម" សម្រាប់ផ្តល់ជាសំអាងទៅលើការធ្វើសេចក្តីសម្រេចសំខាន់ដោយអង្គភាពនោះ។[34] សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈបានចែងពីតម្រូវការមួយចំនួនពាក់ព័ន្ធនឹងស្តង់ដារនៃការកត់ត្រា ក្នុងគោលបំណងតាមដាននិងត្រួតពិនិត្យមើលលើនីតិវិធីធ្វើសេចក្តីសម្រេចដែលធ្វើដោយស្ថាប័នអនុវត្តលទ្ធកម្ម។[35]

*គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ* បានចែងអំពីតម្រូវការគណនេយ្យភាពលើសេចក្តីសម្រេច ដែលប្រើការដេញថ្លៃដោយស្ថាប័នអនុវត្តលទ្ធកម្ម។[36] អំណះអំណាងនៃតម្រូវការនោះគឺ *"ព័ត៌មានដែលត្រូវបានផ្សព្វផ្សាយនៅក្នុងសេចក្តីជូនដំណឹងជាមុននៃលទ្ធកម្មសាធារណៈ គឺជាតម្រូវការអប្បបរមា ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងជាសាធារណៈ និងលទ្ធភាពតវ៉ាដោយអ្នកផ្គត់ផ្គង់ឬអ្នកទទួលការ ដែលមិនពេញចិត្តនឹងសេចក្តីសម្រេច"*។ សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈរក្សាកាតព្វកិច្ចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ក្នុងការផ្សព្វផ្សាយឯកសារជូនដំណឹងស្តីពីការដេញថ្លៃ។ កាតព្វកិច្ចដែលបានចែងនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (ជំពូកទី៨) ស្តីពីនីតិវិធីអនុវត្តលទ្ធកម្ម អាចត្រូវបានបកស្រាយថាជាលក្ខខណ្ឌអនុវត្តទូទៅចំពោះគ្រប់វិធីសាស្ត្រលទ្ធកម្ម។

បញ្ហាមួយទៀតនៃគណនេយ្យភាពនោះគឺ ការបែងចែកអំណាចនិងមុខងារ ក្នុងលទ្ធកម្មសាធារណៈ។ ដូចដែលបានបញ្ជាក់ខាងលើ **ក.ស.ហ.វ.** គឺជាស្ថាប័នគ្រប់គ្រងលទ្ធកម្មសាធារណៈ។ សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈគូសបញ្ជាក់ថា **ក.ស.ហ.វ.** គឺជាអាជ្ញាធរមានសមត្ថកិច្ចដើម្បីអនុវត្តមុខងារលទ្ធកម្មកណ្តាល ត្រួតពិនិត្យលើកិច្ចសន្យាលទ្ធកម្មសាធារណៈ និងវាយតម្លៃការអនុវត្តក្របខណ្ឌច្បាប់នៃលទ្ធកម្ម។[37] *គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ* មិនបានចែងអំពីយន្តការតម្រូវឱ្យស្ថាប័នអនុវត្តលទ្ធកម្មស្នើសុំការឯកភាពជាមុនពីនិយ័តករលទ្ធកម្មសាធារណៈ ចំពោះការធ្វើកិច្ចលទ្ធកម្មសំខាន់មួយចំនួននោះទេ។[38] ផ្ទុយមកវិញ សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈបានរក្សាទុកនីតិវិធីលទ្ធកម្ម

---

[34] គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ២៥

[35] សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ៤៦

[36] គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ៣៤ និង មាត្រា ៣៥

[37] ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ៥ និង សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ៤

[38] អង្គការសហប្រជាជាតិ, សេចក្តីណែនាំស្តីពីការអនុម័តគម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, ផ្នែកទី១ ឃ្លាទី៧២

សាធារណៈលើសកម្មភាពមួយចំនួនជាមុខងារលទ្ធកម្មកណ្តាល ដែលត្រូវទទួលយកការឯកភាពជាមុនពី **គ.ស.ហ.វ.**។ ជាឧទាហរណ៍ ជម្រើសសម្រាប់វិធីសាស្ត្រលទ្ធកម្មដោយឡែកនិងបុរេលក្ខណៈសម្បត្តិនៃអ្នកដេញថ្លៃ សម្រាប់ "គម្រោងលទ្ធកម្មខ្នាតធំដែលមានលក្ខណៈយុទ្ធសាស្ត្រនិងទិដ្ឋភាពបច្ចេកទេសជាក់លាក់សម្រាប់ការគ្រប់គ្រង និងលទ្ធកម្មដែលមានភាពប្រែប្រួលខ្ពស់" ត្រូវទទួលបានការឯកភាពលើឯកសារដេញថ្លៃជាមុនពី **គ.ស.ហ.វ.** មុនការចេញសេចក្តីជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យា។ ជាក់ស្តែង ការប្រើប្រាស់យន្តការឯកភាពជាមុន អាចផ្តល់នូវគុណសម្បត្តិ ក្នុងការជួយស្វែងរកកំហុសនិងបញ្ហាដែលអាចកើតឡើង ការធ្វើសមាហរណកម្មក្នុងប្រព័ន្ធលទ្ធកម្មជាតិ និងប្រតិបត្តិជាកសាងសមត្ថភាព។ យ៉ាងណាមិញ ការណ៍នេះក៏អាចផ្តល់ជាគុណវិបត្តិផងដែរដូចជា ការទប់ស្កាត់ក្នុងការធ្វើសេចក្តីសម្រេចលើលទ្ធកម្មទំនិញសម្រាប់រយៈពេលវែង និងការទទួលយកហានិភ័យនៃការទទួលខុសត្រូវ។[39]

គោលការណ៍មួយទៀតដែលបានកំណត់នៅក្នុង មាត្រា ១ នៃសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ គឺគោលការណ៍សុចរិតភាព។ យោងតាមនីតិវិធីរួមសម្រាប់ការគ្រប់គ្រងការរៀបចំនិងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍[40] គោលការណ៍សុចរិតភាព ត្រូវបានបកស្រាយថា "*សុចរិតភាពទាមទារឱ្យមានការប្រើប្រាស់មូលនិធិ ធនធាននិងអំណាច ដោយសមស្រប សម្រាប់គោលបំណង ស្របតាមប្រយោជន៍សាធារណៈ និងគោលការណ៍ដ៏ធំទូលាយនៃអភិបាលកិច្ចដ៏ល្អ។ គោលការណ៍នេះតម្រូវឱ្យរដ្ឋាភិបាល និងមន្ត្រីគម្រោង អ្នកដេញថ្លៃ អ្នកទទួលការ អ្នកផ្តល់យោបល់ អ្នកផ្គត់ផ្គង់ ។ល។ ដែលចូលរួមនៅក្នុងនីតិវិធីលទ្ធកម្មធ្វើការសង្កេតស្តង់ដារនៃក្រមសីលធម៌ដ៏ល្អ និងភាពស្មោះត្រង់។ ពួកគេត្រូវចៀសឱ្យឆ្ងាយពីអំពើឆបោកនិងពុករលួយ។*"

អនុលោមតាម *ច្បាប់ស្តីពីលទ្ធកម្មសាធារណៈគម្រូរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ*[41] **គ.ស.ហ.វ.** បានអនុម័តប្រកាសលេខ ៨៨៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០១៦ ស្តីពីក្រមសីលធម៌លទ្ធកម្មសាធារណៈ ("**ប្រកាសលេខ ៨៨៧**") ដើម្បីលើកកម្ពស់សមភាព តម្លាភាព និងគណនេយ្យភាព នៅក្នុងការអនុវត្តគម្រោងលទ្ធកម្មសាធារណៈ។ ក្រមសីលធម៌លទ្ធកម្មសាធារណៈ បានលើកឡើងជាពិសេសអំពីការធ្វើលទ្ធកម្មសាធារណៈដោយបុគ្គល ក៏ប៉ុន្តែវិសាលភាពរបស់ប្រកាសនេះក៏លាដសន្ធឹងទៅគ្រប់គ្រងរាល់បុគ្គលពាក់ព័ន្ធនឹងគម្រោងលទ្ធកម្មសាធារណៈផងដែរ រួមមាន សមាជិកគណៈកម្មាធិការលទ្ធកម្មសាធារណៈ ក្រុមការងារលទ្ធកម្មសាធារណៈ មន្ត្រីលទ្ធកម្មសាធារណៈ និងអ្នកដេញថ្លៃដែលពាក់ព័ន្ធនៅក្នុងនីតិវិធីលទ្ធកម្ម

---

[39] អង្គការសហប្រជាជាតិ, សេចក្តីណែនាំស្តីពីការអនុម័តគម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, ផ្នែកទី១ ឃ្លាទី៧២

[40] នីតិវិធីរួមសម្រាប់ការគ្រប់គ្រងការរៀបចំនិងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍, វគ្គមួយ ទំព័រទី៨

[41] គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ២៦(ក្រមសីលធម៌លទ្ធកម្មសាធារណៈ).

សាធារណៈ។[42] ក្រមសីលធម៌លទ្ធកម្ម[43]បានកំណត់នូវគោលការណ៍ជាសេរី ដើម្បីទប់ស្កាត់ស្ថានភាពណាមួយ ដែលអាចជះឥទ្ធិពលលើភាពអព្យាក្រឹត្យរបស់មន្ត្រីនៅក្នុងអនុវត្តតួនាទីរបស់ខ្លួន ដូចជាទំនាស់ផលប្រយោជន៍ ឬ ការប្រព្រឹត្តអំពើពុករលួយ ជាដើម។

*គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្ម អន្តរជាតិ* បានចែងថា ក្រមសីលធម៌នេះត្រូវតែអាចឱ្យសាធារណជនចូលមើលបាន និងទទួលបានការរក្សាទុកជា ប្រព័ន្ធ។[44] ជាគោលការណ៍ បទប្បញ្ញត្តិត្រូវផ្សព្វផ្សាយជាសាធារណៈនៅក្នុងរាជកិច្ច។ ក្រមសីលធម៌លទ្ធកម្ម អាចស្វែងបានរកតាមរយៈគេហទំព័ររបស់ **ក.ស.ហ.វ.** ជាភាសាខ្មែរ។ ក៏ប៉ុន្តែ ក្រមសីលធម៌លទ្ធកម្មសាធារណៈ នៅក្រោមនីតិវិធីរួមសំរាប់ការគ្រប់គ្រងការរៀបចំនិងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ មិនអាចស្វែងរកបាននូវអត្ថបទបកប្រែជាភាសាអង់គ្លេសបានឡើយ។

កម្មវត្ថុរបស់ក្រមសីលធម៌នេះ គឺដើម្បីកំណត់របបពិសេសមួយសំរាប់នីតិវិធីលទ្ធកម្មសាធារណៈ ស្របតាម របបទូទៅដែលគ្រប់គ្រងសកម្មភាពរបស់មន្ត្រីរាជការនៅក្នុងរដ្ឋនីមួយៗ។ ប្រទេសកម្ពុជាបានចូលជាសមាជិក របស់អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយនៅក្នុងឆ្នាំ២០០៧។ អនុសញ្ញានេះបែងចែករបប ចំនួនពីរដែលគ្រប់គ្រងលើក្រមសីលធម៌នោះ គឺ ១) របបទូទៅសម្រាប់មន្ត្រីរាជការ និង ២) របបពិសេសសម្រាប់ លទ្ធកម្មសាធារណៈ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ខណៈពេលដែលរបបទូទៅគ្រប់គ្រងលើសកម្មភាព របស់មន្ត្រីរាជការ ត្រូវបានគ្រប់គ្រងនៅក្នុងប្រទេសកម្ពុជាដោយច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និង ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ច្បាប់ស្តីពីលទ្ធកម្មសាធារណៈនិងក្រមសីលធម៌លទ្ធកម្មសាធារណៈបាន កំណត់អំពីរបបពិសេស។ ដើម្បីវាយតម្លៃថា តើរបបពិសេសនេះស្របជាមួយស្តង់ដារកំណត់ក្រោម*គម្រូច្បាប់ស្តីពី លទ្ធកម្មសាធារណៈរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ*ដែរឬអត់[45] យើងអាចវាយតម្លៃបន្ថែមទៀតលើបញ្ហាដូចខាងក្រោម៖

- ការទប់ស្កាត់ទំនាស់ផលប្រយោជន៍នៅក្នុងលទ្ធកម្មសាធារណៈ និង

---

[42] ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ៦៤ និង សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ៧០

[43] យោងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ពាក្យ “ក្រមសីលធម៌លទ្ធកម្ម” សំដៅដល់ “ក្រមដែលអ្នកចូលរួមពាក់ព័ន្ធនឹងលទ្ធកម្ម សាធារណៈត្រូវយល់ដឹងនិងអនុវត្តដោយស្មោះត្រង់តាមបទប្បញ្ញត្តិគតិយុត្តជាធរមាន និងអនុវត្តឱ្យបានត្រឹមត្រូវតាមតួនាទីនិងមុខងាររបស់ ខ្លួន”

[44] គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ២៦

[45] អង្គការសហប្រជាជាតិ, សេចក្តីណែនាំស្តីពីការអនុម័តគម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, យោបល់លើ មាត្រា ២៦

- វិធីសាស្ត្រដើម្បីបញ្ញត្តិបញ្ហាពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់បុគ្គលសំរាប់លទ្ធកម្មសាធារណៈដូចជា ការប្រកាសអំពីផលប្រយោជន៍នៅក្នុងលទ្ធកម្មពិសេសណាមួយ នីតិវិធីត្រួតពិនិត្យ និងតម្រូវក្នុងការ បណ្តុះបណ្តាល។

ពាក់ព័ន្ធនឹងបញ្ហានេះ ច្បាប់និងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈតម្រូវឱ្យសមាជិកទាំងអស់របស់ គណៈកម្មាធិការលទ្ធកម្មសាធារណៈ ដែលទទួលខុសត្រូវលើការពិនិត្យឡើងវិញនិងការធ្វើសេចក្តីសម្រេចលើការ ដាក់សំណើដេញថ្លៃ ត្រូវចុះហត្ថលេខាលើសេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្មសាធារណៈ។[46]

ដើម្បីការអនុវត្តជាប្រព័ន្ធ ក្រមសីលធម៌ក្នុងរបបពិសេសនៃលទ្ធកម្មសាធារណៈនេះត្រូវធ្វើសមាហរណកម្ម ជាមួយនឹងក្រមសីលធម៌ក្នុងរបបទូទៅ ដើម្បីធានានូវសុចរិតភាពនៃនីតិវិធីលទ្ធកម្មសាធារណៈក្នុងប្រព័ន្ធរដ្ឋបាល សាធារណៈ។[47] ហេតុដូច្នេះ ច្បាប់ស្តីពីលទ្ធកម្មសាធារណៈបានចែងថា បទល្មើសនៃអំពើពុករលួយ ត្រូវស្ថិតនៅ ក្រោមសមត្ថកិច្ចរបស់អង្គភាពប្រឆាំងអំពើពុករលួយ។[48] សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈបន្ថែមថា ស្ថាប័ន ដែលមានសមត្ថកិច្ចតែមួយគត់ក្នុងធ្វើការស៊ើបអង្កេតលើរឿងក្តីគឺអង្គភាពប្រឆាំងអំពើពុករលួយ គឺអង្គភាពប្រឆាំង អំពើពុករលួយ ដែលត្រូវធ្វើការស៊ើបអង្កេតនិងកសាងសំណុំរឿងបញ្ជូនទៅតុលាការ។[49] ច្បាប់ស្តីពីការប្រឆាំង អំពើពុករលួយ បានកំណត់បទល្មើសមួយចំនួន ដូចជាបទល្មើសពុករលួយ ទំនាស់ផលប្រយោជន៍ និងនិយមន័យ នៃ "អត្ថប្រយោជន៍" ឬ "អំណោយ"។ សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈក៏បានចែងអំពីនិយមន័យដ៏ខ្លីនៃ បទល្មើសពុករលួយ ខណៈដែលច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ គ្រប់ដណ្តប់បទល្មើសពុករលួយនេះយ៉ាង ទូលំទូលាយ[50] រួមមានបទល្មើសកំណត់ដោយក្រមព្រហ្មទណ្ឌជាដើម។

## ឃ. ការគ្រប់គ្រង និងការត្រួតពិនិត្យ

យន្តការមួយក្នុងចំណោមយន្តការជាច្រើន នៅក្នុងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ គឺយន្តការត្រួតពិនិត្យគម្រោង លទ្ធកម្មសាធារណៈ ដើម្បីធានានូវគុណភាពរបស់គម្រោងនោះ។ ហេតុដូចនេះ ការទទួលយកលទ្ធផលនៃគម្រោង នីមួយៗត្រូវតែធ្វើឡើងដោយពិនិត្យមើលលើភាពសមស្របនៃទំហំ បរិមាណ គុណភាព និងលក្ខណៈបច្ចេកទេស ដូច មានចែងនៅក្នុងកិច្ចសន្យាលទ្ធកម្មសាធារណៈ។ មាត្រា ៦២ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈចែងបន្ថែមអំពីការ

---

[46] ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ៤៦ និង សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ៤៩

[47] អង្គការសហប្រជាជាតិ, សេចក្តីណែនាំស្តីពីការអនុម័តគម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, យោបល់លើបុព្វកថា

[48] សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ៧៣

[49] សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ៧៩

[50] សូមចូលមើល ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ជំពូក ៦

បង្កើត*គណៈកម្មការប្រគល់ទទួល*។ ក៏ប៉ុន្តែនីតិវិធីនៃការបង្កើតគណៈកម្មការប្រគល់ទទួលទំនិញនិងការងារ ត្រូវកំណត់ដោយប្រកាសរបស់ **ក.ស.ហ.វ.**[51] ដែលប្រកាសនេះមិនទាន់ត្រូវបានរកឃើញនៅឡើយនោះទេ។

ចំពោះការអនុវត្តជាគោលការណ៍ គម្រោងលទ្ធកម្មសាធារណៈណាមួយដែលបានបញ្ចប់ ត្រូវតែពិនិត្យឡើងវិញឱ្យបានត្រឹមត្រូវ ដើម្បីទទួលបានការទទួលស្គាល់និងទទួលយក ដោយអាជ្ញាធរមានសមត្ថកិច្ច។ បន្ថែមពីលើនេះ សមិទ្ធផលសម្រេចនៃគម្រោងលទ្ធកម្មដែលបានបញ្ចប់ ត្រូវចាត់ទុកជាទ្រព្យរដ្ឋ ដោយត្រូវកត់បញ្ចូលឱ្យបានត្រឹមត្រូវនៅក្នុងតារាងតុល្យការរបស់រដ្ឋ ដើម្បីឱ្យស្ថិតនៅក្រោមការគ្រប់គ្រងដោយអាជ្ញាធរមានសមត្ថកិច្ចសម្រាប់ការគ្រប់គ្រងទ្រព្យរដ្ឋ។ ជាក់ស្ដែង មន្ត្រីមានសមត្ថកិច្ចបានបញ្ជាក់ថា មានបទប្បញ្ញត្តិក្រោមច្បាប់ សម្រាប់កំណត់អំពីការពិនិត្យនិងទទួលយកសមិទ្ធផលនៃការអនុវត្តកិច្ចសន្យាលទ្ធកម្ម ហើយការកត់បញ្ចូលទ្រព្យរដ្ឋបាននិងកំពុងចាប់ផ្ដើមដាក់ឱ្យអនុវត្តដែលនឹងទាមទារឱ្យមានការធ្វើសន្ទានកម្មរវាងប្រព័ន្ធព័ត៌មានវិទ្យាលទ្ធកម្ម ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងទ្រព្យរដ្ឋ និងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

លើសពីនេះទៅទៀត **ក.ស.ហ.វ.** បានអនុម័តប្រកាសស្ដីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ (“**ប្រកាសលេខ ១៦១៣**”)។[52] ប្រកាសនេះបានចែងអំពីតួនាទីនិងការទទួលខុសត្រូវរបស់បុគ្គលពាក់ព័ន្ធនឹងគម្រោងលទ្ធកម្មសាធារណៈ មានដូចជា អង្គភាពអនុវត្ត អង្គភាពថវិកា **ក.ស.ហ.វ.** អ្នកផ្គត់ផ្គង់ អ្នកដេញថ្លៃឈ្នះ និងវិស្វករ។ នៅក្នុងប្រកាសនេះ ស្ថាប័នអនុវត្តលទ្ធកម្មនិងអង្គភាពលទ្ធកម្មត្រូវទទួលខុសត្រូវផ្ទាល់ក្នុងការអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ។ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃ **ក.ស.ហ.វ.** គឺជាស្ថាប័នទទួលខុសត្រូវក្នុងការគ្រប់គ្រងគម្រោងលទ្ធកម្មសាធារណៈ។ ក្នុងចំណោមតួនាទីផ្សេងទៀត អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ទទួលមុខងារដើម្បីចុះមើលទីតាំងដោយផ្ទាល់ ពិនិត្យឡើងវិញនូវការអនុវត្តកិច្ចសន្យាលទ្ធកម្មលទ្ធកម្ម ផ្ដល់ប្រឹក្សា និងលើកកម្ពស់ការអនុវត្តគម្រោងប្រកបដោយប្រសិទ្ធភាព អនុលោមតាមតម្រូវការគុណភាព និងលើកឡើងនូវបញ្ហាដែលខ្លួនបានជួបប្រទះក្នុងពេលអនុវត្តគម្រោងដើម្បីស្វែងរកដំណោះស្រាយ។ តាមការបញ្ជាក់ពីមន្ត្រីមានសមត្ថកិច្ច សេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈនឹងបញ្ចូលការអនុវត្តឬគ្រប់គ្រងលទ្ធកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលប្រព័ន្ធព័ត៌មានវិទ្យាលទ្ធកម្មនឹងត្រូវធ្វើសន្ទានកម្មភ្ជាប់ជាមួយនឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីការរៀបចំថវិកា និងការអនុវត្តថវិកា និងប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

ដើម្បីធានាឱ្យមាននូវការត្រួតពិនិត្យដ៏ល្អនៃលទ្ធកម្មសាធារណៈ ប្រទេសមួយចំនួនដូចជា ប្រទេសប្រេស៊ីល ប្រទេសបារាំង និងប្រទេសកូរ៉េ បានអនុម័តនូវវិធីសាស្ត្រដែលតម្រូវឱ្យមានការវាយតម្លៃហានិភ័យជាប្រចាំ នៅក្នុងវដ្ត

---

[51] ច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ, មាត្រា ៥៩ និង សេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ, មាត្រា ៦២

[52] ប្រកាសលេខ ១៦១ ស.ហ.វ./ប្រ.ក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ស្ដីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ

លទ្ធកម្មសាធារណៈ ដោយរៀបចំជាផែនការឬយុទ្ធសាស្ត្រវាយតម្លៃកត្តាហានិភ័យនិងបញ្ហាប្រឈមក្នុងលទ្ធកម្មសាធារណៈ។[53] ច្បាប់ស្តីពីលទ្ធកម្មនិងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្ម មិនបានចែងអំពីវិធីសាស្ត្រនេះឡើយ ហើយប្រកាសស្តីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ[54] ក៏មិនបានចែងអំពីការវាយតម្លៃហានិភ័យ ដែលត្រូវអនុវត្តដោយអង្គភាពគ្រប់គ្រងលទ្ធកម្ម ឬអង្គភាពអនុវត្តលទ្ធកម្មដោយខ្លួនឯងផ្ទាល់នោះដែរ។

ពាក់ព័ន្ធនឹងសិទ្ធិប្តឹងតវ៉ាឬឧបាស្រ័យ ដែលនឹងត្រូវពិភាក្សាបន្ថែមទៀតនៅផ្នែកខាងក្រោម គឺជាយន្តការមួយក្នុងចំណោមយន្តការទាំងអស់ ដើម្បីពិនិត្យមើលសេចក្តីសម្រេចដែលធ្វើឡើងដោយគណៈកម្មាការធ្វើសេចក្តីសម្រេច។[55] យន្តការជំទាស់តវ៉ានេះត្រូវបានចែងនៅក្នុងច្បាប់ស្តីពីលទ្ធកម្មសាធារណៈនិងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។ ជាងនេះទៅទៀត ដើម្បីធានាថា មិនមានភាពមិនប្រក្រតីណាមួយបានកើតឡើង នៅក្នុងសេចក្តីសម្រេចដែលធ្វើដោយគណៈកម្មាធិការចំពោះអ្នកដេញថ្លៃ វាមានភាពចាំបាច់ណាស់ដែលសេចក្តីសម្រេចដែលបានធ្វើឡើងនេះ ត្រូវបានប្រកាសឱ្យរាល់អ្នកដេញថ្លៃបានដឹង ព្រមទាំងប្រកាសជាសាធារណៈ។ ការធ្វើបែបនេះ អាចអនុញ្ញាតិឱ្យរាល់អ្នកដេញថ្លៃណាដែលសង្ស័យថាមានភាពមិនប្រក្រតីនៅក្នុងនីតិវិធីដេញថ្លៃ ទទួលបាននូវឱកាសក្នុងការដាក់ពាក្យបណ្តឹង ឬជំទាស់ប្រឆាំងនឹងសេចក្តីសម្រេចនេះ មុននឹងការចុះកិច្ចសន្យាលទ្ធកម្មលើគម្រោង។

សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈចែងនូវយន្តការថ្មីមួយ ដោយប្រគល់អំណាចទៅឱ្យ **ក.ស.ហ.វ.** ដើម្បីធ្វើការត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយ។[56] បើទោះជាមានបញ្ញត្តិបែបនេះក្តី សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈមិនបានចែងអំពីលក្ខខណ្ឌឬសេចក្តីតម្រូវណាមួយពាក់ព័ន្ធនឹងការត្រួតពិនិត្យនេះឡើយ។ ច្បាប់នេះទុកសមត្ថកិច្ចឱ្យ **ក.ស.ហ.វ.** កំណត់នីតិវិធីដើម្បីធ្វើការត្រួតពិនិត្យតាមក្រោយនេះ ដោយរៀបចំនិងអនុម័តនូវប្រកាសបំពេញបន្ថែម។ លើសពីនេះ នៅក្នុងឋានានុក្រមនៃច្បាប់ សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈបានចែងថា **ក.ស.ហ.វ.**មានសិទ្ធិអំណាចត្រួតពិនិត្យក្នុងអំឡុងពេលនៃដំណើរការកិច្ចលទ្ធកម្ម ក្នុងករណីពិនិត្យឃើញថា មានភាពមិនប្រក្រតីដែលកើតឡើងនៅក្នុងដំណាក់កាលណាមួយនៃការអនុវត្តលទ្ធកម្មសាធារណៈ។[57] សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈមិនបានចែងនូវបញ្ញត្តិជាក់លាក់ណាមួយ ពាក់ព័ន្ធនឹងការដាក់ពាក្យបណ្តឹងនិងយន្តការដោះស្រាយវិវាទនោះទេ (សូមមើលផ្នែកខាងក្រោម)។

---

[53] OECD, *កម្រងឧត្តមានុវត្តន៍នៃការអនុវត្តលទ្ធកម្មសាធារណៈសម្រាប់សុចរិតភាព*, ឆ្នាំ២០១៤ ទំព័រ ២៦

[54] ប្រកាសលេខ ១៦១ ស.ហ.វ/ប្រ.ក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ

[55] ការិយាល័យប្រឆាំងបទល្មើសនិងគ្រឿងញៀន, សៀវភៅណែនាំប្រឆាំងអំពើពុករលួយ៖ ឧត្តមានុវត្តន៍ក្នុងការធានាអនុលោមភាពតាមប្រការ ៩ នៃ អនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ ឆ្នាំ២០១៣ ទំព័រ ១១ ឯកសារនេះមាននៅ: https://www.unodc.org/documents/corruption/Publications/2013/Guidebook_on_anti-corruption_in_public_procurement_and_the_management_of_public_finances.pdf

[56] សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ៦៨

[57] សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ៦៩

## ខ. សិទ្ធិតវ៉ានិងខ្ទង់ប្រាស្រ័យ

*ច្បាប់ស្ដីពីលទ្ធកម្មសាធារណៈគម្រូរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្ដីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ* បានផ្ដល់នូវប្រព័ន្ធពីរប្រភេទនៃការជំទាស់តវ៉ាលើនីតិវិធី សម្រាប់ឱ្យ "អ្នកផ្គត់ផ្គង់ឬអ្នកទទួលការ ដែលទាមទារថា ខ្លួនបានទទួលរងការខូចខាត ឬទាមទារថា ខ្លួនអាចទទួលរងការបាត់បង់ឬគ្រោះថ្នាក់ ដោយសារតែកំហុសឆ្គងលើនីតិវិធីក្នុងការធ្វើសេចក្ដីសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម"។[58] ទីមួយ សិទ្ធិជាមូលដ្ឋាន ក្នុងការជំទាស់ឬតវ៉ាអាចធ្វើឡើងតាមរយៈ "ការដាក់ពាក្យស្នើសុំឱ្យពិនិត្យឡើងវិញទៅស្ថាប័នអនុវត្តលទ្ធកម្ម" និង/ឬ "ការដាក់ពាក្យស្នើសុំសម្រាប់ការត្រួតពិនិត្យទៅ[ស្ថាប័នឯករាជ្យ]ដែលកំណត់ដោយច្បាប់ជាតិ បន្ទាប់មកទៀតជាការត្រួតពិនិត្យដោយស្ថាប័នតុលាការ ឬសិទ្ធិក្នុងការដាក់ពាក្យបណ្ដឹងទៅតុលាការ តាមរយៈ "ការដាក់ពាក្យស្នើសុំ ឬបណ្ដឹងទៅ[តុលាការ ]"។

សេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ បានបែងចែកជាពីរវវាង ១) ពាក្យបណ្ដឹង ដែលធ្វើឡើងដោយអ្នកដេញថ្លៃនៅគ្រប់នីតិវិធីណាមួយនៃវដ្ដលទ្ធកម្ម រួមបញ្ចូលទាំងពាក្យបណ្ដឹងក្នុងអំឡុងដែលបើកឱ្យមានការជំទាស់តវ៉ា និង ២) វិវាទដែលកើតឡើងរវាងគូភាគីអំឡុងពេលអនុវត្តកិច្ចសន្យាលទ្ធកម្ម។ នីតិវិធីពាក់ព័ន្ធនឹងការដាក់ពាក្យបណ្ដឹង និងការដោះស្រាយវិវាទ ត្រូវបានកំណត់នៅក្នុងអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨។

បទដ្ឋានគតិយុត្តរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្ដីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិបានចាត់ទុកពាក្យស្នើសុំសម្រាប់ការត្រួតពិនិត្យឡើងវិញទៅស្ថាប័នអនុវត្តលទ្ធកម្មជាជម្រើសនៃយន្តការដោះស្រាយវិវាទ មួយ។ ផ្ទុយទៅវិញ សេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ បានណែនាំថា យន្តការនេះ គឺជាជំហានដំបូងបំផុតក្នុងការដោះស្រាយបណ្ដឹងលទ្ធកម្មសាធារណៈ។ សម្រាប់ការដាក់ពាក្យស្នើសុំត្រួតពិនិត្យឡើងវិញទៅស្ថាប័នឯករាជ្យ សេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ មិនបានកំណត់សមត្ថកិច្ចរបស់ស្ថាប័នផ្សេងទៀតក្រៅពី **ក.ស.ហ.វ.** នោះឡើយ។ គម្រូច្បាប់ស្ដីពីលទ្ធកម្មសាធារណៈរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្ដីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ បានបញ្ជាក់អំពីលក្ខណៈនៃស្ថាប័នឯករាជ្យថា គឺជាស្ថានភាពរបស់លិខិតបទដ្ឋានគតិយុត្តលទ្ធកម្មជាតិ នឹងសង្កត់ធ្ងន់ថាយន្តការជំទាស់តវ៉ា ត្រូវតែមានប្រសិទ្ធភាព។ លើសពីនេះ គណៈកម្មការនៃអង្គការសហប្រជាជាតិស្ដីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិក៏បានផ្ដល់គោលការណ៍ណែនាំលើអត្ថន័យនៃពាក្យ "***ឯករាជ្យ***" នៅក្នុងបរិបទនៃគម្រូច្បាប់ស្ដីពីលទ្ធកម្មសាធារណៈរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្ដីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិនៅត្រង់ ជំពូក ៨ ថា៖

[58] គម្រូច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ, មាត្រា ៦៨

*“ជាឯករាជ្យភាពរបស់ស្ថាប័នអនុវត្តលទ្ធកម្មសាធារណៈ ជាជាងឯករាជ្យរបស់រាជរដ្ឋាភិបាលជារួម និងជាការទទួលបានការការពារពីសម្ពាធនយោបាយ។ សម្រាប់ហេតុផលដូចគ្នាដែលអនុវត្តលើការត្រួតពិនិត្យបែបរដ្ឋបាលតាមឋានានុក្រម “**<u>អង្គភាពរដ្ឋបាលដែលនៅក្រោមគម្រូច្បាប់ មានសមត្ថកិច្ចធ្វើការឯកភាពលើសកម្មភាពឬសេចក្តីសម្រេចមួយចំនួនរបស់ស្ថាប័នអនុវត្តលទ្ធកម្មសាធារណៈ ឬនីតិវិធីដែលអនុវត្តដោយស្ថាប័នអនុវត្តលទ្ធកម្មសាធារណៈ ឬណែនាំស្ថាប័នអនុវត្តលទ្ធកម្មលើនីតិវិធី អង្គភាពរដ្ឋបាលនោះនឹងមិនបំពេញលក្ខខណ្ឌសម្រាប់ឯករាជ្យភាពឡើយ</u>** [គូសបញ្ជាក់ដោយអ្នកនិពន្ធនៃរបាយការណ៍នេះ]។ ជាលទ្ធផលរដ្ឋនានានឹងចង់គិតពិចារណាជាពិសេសថា តើអង្គភាពឯករាជ្យ គួរតែដាក់បញ្ចូល ឬមាននូវសមាសភាពរបស់អ្នកជំនាញពីខាងក្រៅដែលមានឯករាជ្យភាពពីរាជរដ្ឋាភិបាលដែរឬទេ។ ឯករាជ្យភាព មានសារៈសំខាន់សម្រាប់ការអនុវត្តលទ្ធកម្មសាធារណៈ ព្រោះប្រសិនបើនីតិវិធីត្រួតពិនិត្យសេចក្តីសម្រេចមិនមានភាពឯករាជ្យនោះទេ ការជំទាស់តវ៉ាផ្សេងបន្ថែមទៀតទៅស្ថាប័នតុលាការអាចកើតមានឡើង ដែលអាចបង្កផលវិបាកយូរអង្វែងដល់នីតិវិធីលទ្ធកម្មសាធារណៈ។*

ហេតុដូច្នេះ រាជរដ្ឋាភិបាលកម្ពុជាអាចពិចារណាលើលទ្ធភាពជម្រុញឱ្យមានស្ថាប័នឯករាជ្យ ស្របជាមួយនឹងលក្ខខណ្ឌនៃពាក្យឯករាជ្យដូចមានចែងខាងលើ ដែលជាស្ថាប័នមានសមត្ថកិច្ចអនុវត្តការត្រួតពិនិត្យបែបរដ្ឋបាល ឬធ្វើឱ្យយន្តការលើពាក្យបណ្តឹងដែលដាក់ទៅស្ថាប័នអនុវត្តលទ្ធកម្ម ឬ **ក.ស.ហ.វ.** មានវិធាននីតិវិធីឯករាជ្យគ្រប់គ្រាន់ដោយមិនមានទំនាស់ផលប្រយោជន៍ លើសពីយន្តការប្រឹក្សាយោបល់ឬសន្ទានកម្ម។ ជាផ្នែកមួយនៃតុល្យភាពនៃអំណាច សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈក៏បានកំណត់ពីនីតិវិធីត្រួតពិនិត្យតាមផ្លូវច្បាប់របស់ **ក.ស.ហ.វ** ដែលការត្រួតពិនិត្យនេះអាចត្រូវបានជំទាស់ដោយតុលាការកម្ពុជាផងដែរ។[59]

សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈមិនបានពន្យល់ឱ្យបានច្បាស់លាស់ទេ ទាក់ទងនឹងវិសាលភាពនៃពាក្យបណ្តឹង។ ដូចបានរៀបរាប់ពីខាងដើម *គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ*បានចែងអំពីវិសាលភាពនៃការតវ៉ា ដែលអ្នកផ្គត់ផ្គង់ឬអ្នកទទួលការធ្វើឡើងដើម្បីស្វែងរកដំណោះស្រាយឬសំណងការខូចខាតដែលជា *“ការទាមទារថា ខ្លួនបានទទួលរងការខូចខាត ឬទាមទារថាខ្លួនអាចទទួលរងការបាត់បង់ ឬគ្រោះថ្នាក់ ដោយសារតែកំហុសឆ្គងលើនីតិវិធីក្នុងការធ្វើសេចក្តីសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្មសាធារណៈ”*។ យ៉ាងណាមិញ សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ គ្រាន់តែចែងយ៉ាងទូលាយអំពី

[59] ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ៦២ និង សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ៦៥

ហេតុផលនៃការដាក់ពាក្យបណ្តឹងទាក់ទងនឹងភាពមិនប្រក្រតីដែលគួរឱ្យសង្ស័យនៅក្នុងនីតិវិធីលទ្ធកម្មសាធារណៈតែប៉ុណ្ណោះ។

ចំពោះសិទ្ធិរបស់បុគ្គលដែលមានផលប្រយោជន៍ ក្នុងការធ្វើជាភាគីនៅក្នុងនីតិវិធីជំទាស់តវ៉ា *គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ* បានផ្តល់អនុសាសន៍ថា សិទ្ធិនោះត្រូវបានផ្តល់ឱ្យអ្នកផ្គត់ផ្គង់ឬអ្នកទទួលការ និងអ្នកផ្គត់ផ្គង់ឬអ្នកទទួលការមានសក្តានុពល ប៉ុន្តែមិនត្រូវបានផ្តល់ឱ្យសាធារណជនទូទៅនោះទេ។ សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ បានផ្តល់សិទ្ធិប្តឹងតវ៉ានេះដល់អ្នកដេញថ្លៃនិងអ្នកដេញថ្លៃមានសក្តានុពល ដែលត្រូវចាត់ទុកជាអ្នកមានផលប្រយោជន៍នៅក្នុងនីតិវិធីលទ្ធកម្ម ហើយសាធារណជនមិនត្រូវបានផ្តល់សិទ្ធិក្នុងការជំទាស់តវ៉ាជាបុគ្គលមានផលប្រយោជន៍នោះទេ។[60] លើសពីនេះ សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ មិនបានបញ្ជាក់អំពីកម្មវិបាកឬអានុភាពនៃការប្តឹងតវ៉ានោះទេ។ ជាលទ្ធផល អានុភាពនៃនីតិវិធីជំទាស់តវ៉ានៅលើកិច្ចលទ្ធកម្មសាធារណៈ អាចនៅមានភាពស្រពិចស្រពិល។

សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ បានចែងថា ពាក្យបណ្តឹងអាចត្រូវបានដាក់តវ៉ា *"នៅគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធីលទ្ធកម្ម"* ដែលបញ្ញត្តិទូលាយមួយនេះអាចនឹងក្លាយជាកម្មវត្ថុនៃការបកស្រាយ។ នេះមកពីហេតុថា សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ មិនបានរឹតត្បិតទៅលើអាជ្ញាយុកាលកំណត់ សម្រាប់ការដាក់ពាក្យបណ្តឹងជាក់ស្តែងមានដូចជាអាជ្ញាយុកាលនៃពាក្យបណ្តឹងទៅតុលាការ ហើយក៏មិនបានដាក់កំហិតលើសិទ្ធិក្នុងការដាក់ពាក្យបណ្តឹងនៅគ្រប់ដំណាក់កាលនៃនីតិវិធីលទ្ធកម្មសាធារណៈផងដែរ។ ដូចគ្នានេះ សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ មិនបានចែងអំពីរយៈពេលកំណត់លើការសម្រេចសេចក្តីលើពាក្យបណ្តឹង នៅក្នុងនីតិវិធីជំទាស់តវ៉ាតាមបែបរដ្ឋបាលនោះទេ។[61] ខណៈពេលដែលអាចបង្កើតឱ្យមាននូវផលប្រយោជន៍ តាមរយៈការផ្តល់នូវភាពបត់បែនក្នុងការដោះស្រាយបញ្ហាស្របទៅតាមស្ថានភាពនៃគម្រោងលទ្ធកម្មសាធារណៈនីមួយៗ នីតិវិធីលទ្ធកម្មអាចប្រឈមនិងការពន្យារពេល

[60] សូមមើលជាឧទាហរណ៍ សេចក្តីណែនាំ ២០០៧/៦៦/អឺរ៉ុប នៃសភានិងក្រុមប្រឹក្សាអឺរ៉ុប ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៧ កែសម្រួលសេចក្តីណែនាំរបស់ក្រុមប្រឹក្សាលេខ ៨៩/៦៦៥/ក្រុមប្រឹក្សាអឺរ៉ុប និងលេខ ៩២/១៣/ក្រុមប្រឹក្សាអឺរ៉ុប ពាក់ព័ន្ធនឹងការបង្កើនប្រសិទ្ធភាពនៃនីតិវិធីត្រួតពិនិត្យការផ្តល់កិច្ចសន្យា ឃ្លា១៣ ដល់១៤ ដែលបញ្ជាក់ថា "កិច្ចសន្យាដែលកើតចេញពីការផ្តល់កិច្ចសន្យាផ្ទុយច្បាប់ត្រូវចាត់ទុកជាមោឃៈ។ ការមោឃៈនេះ នឹងត្រូវមានអានុភាពដោយឯកឯង ប៉ុន្តែត្រូវបានមានការបញ្ជាក់ដោយអង្គភាពឯករាជ្យដែលមានសមត្ថកិច្ច" "ការចាត់ទុកជាមោឃៈនេះ មានប្រសិទ្ធភាពខ្ពស់ក្នុងការបង្កើនកិច្ចប្រកួតប្រជែង និងបង្កើតឱកាសធុរកិច្ចថ្មី សម្រាប់ប្រតិបត្តិការសេដ្ឋកិច្ច ដែលត្រូវរងគ្រោះដោយអំពើខុសច្បាប់ ក្នុងការប្រកួតប្រជែង..." ដែលឯកសារនេះអាចមាននៅ http://data.europa.eu/eli/dir/2007/66/oj

[61] សូមមើលជាឧទាហរណ៍ ធនាគារអភិវឌ្ឍន៍អាស៊ី *គោលនយោបាយលទ្ធកម្មសាធារណៈរបស់ធនាគារអភិវឌ្ឍន៍អាស៊ី: ទំនិញ ការងារ និងសេវាពិគ្រោះឬមិនពិគ្រោះ* ឆ្នាំ២០១៧ ឃ្លាទី៩ ដែលឯកសារនេះមាននៅ: https://www.adb.org/sites/default/files/adb-procurement-policy.pdf

មិនសមហេតុផល និងជាកម្មវត្ថុនៃការសម្រេចចិត្តដោយឆន្ទានុសិទ្ធ ប្រសិនបើពាក្យបណ្ដឹងដែលធ្វើឡើងដោយអ្នកដេញថ្លៃមិនត្រូវបានវិនិច្ឆ័យ និងដោះស្រាយដោយអាជ្ញាធរមានសមត្ថកិច្ចឱ្យបានទាន់ពេលវេលា។

គម្រូច្បាប់ស្ដីពីលទ្ធកម្មសាធារណៈរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្ដីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ បានលើកឡើងនូវបញ្ហាអាជ្ញាយុកាលសម្រាប់ការជំទាស់តវ៉ាដែលធ្វើឡើងដោយបុគ្គលមានសមត្ថកិច្ច ឬរយៈពេលកំណត់សម្រាប់អង្គភាពដែលពាក់ព័ន្ធក្នុងការចេញសេចក្ដីសម្រេចទៅលើការជំទាស់តវ៉ានោះ។ ខណៈពេលដែលគម្រូច្បាប់ស្ដីពីលទ្ធកម្មសាធារណៈរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្ដីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ មិនបានចែងអំពីពេលវេលាច្បាស់លាស់សម្រាប់ការចេញសេចក្ដីសម្រេចរបស់ខ្លួនទៅនឹងបណ្ដឹងជំទាស់តវ៉ានោះទេ ហើយគម្រូច្បាប់នេះបានផ្ដល់ជាគោលការណ៍ណែនាំសម្រាប់ពិចារណាក្នុងការ *"ប្រើប្រាស់រយៈពេលឱ្យកាន់ខ្លីស្របតាមប្រព័ន្ធច្បាប់របស់ខ្លួន ដើម្បីជៀសវាងការបង្អាក់នីតិវិធីលទ្ធកម្ម"*។[62] ពាក់ព័ន្ធនឹងការជំទាស់តវ៉ាលើសេចក្ដីសម្រេចរបស់គណៈកម្មាធិការលទ្ធកម្មក្នុងការប្រគល់កិច្ចសន្យាលទ្ធកម្ម មាត្រា ៥១ នៃសេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ បានធ្វើវិសោធនកម្មមាត្រា ៤៨ នៃច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ។ នៅក្រោមបញ្ញត្តិនៃសេចក្ដីព្រាងច្បាប់នេះ ពាក្យបណ្ដឹងជំទាស់តវ៉ានឹងសេចក្ដីសម្រេចរបស់គណៈកម្មាធិការលទ្ធកម្មសាធារណៈ ត្រូវធ្វើឡើងក្នុងរយៈពេល ១០ ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្ដីជូនដំណឹងពីសេចក្ដីសម្រេចរបស់គណៈកម្មាធិការលទ្ធកម្មសាធារណៈ។ នៅពេលបានទទួលពាក្យបណ្ដឹង គណៈកម្មាធិការលទ្ធកម្មសាធារណៈត្រូវចាត់វិធានការភ្លាមៗ ដើម្បីដោះស្រាយបញ្ហានេះ ហើយប្រសិនបើខកខានមិនបានចាត់វិធានការទេនោះ គណៈកម្មាធិការលទ្ធកម្មសាធារណៈត្រូវបញ្ជូនពាក្យបណ្ដឹងជំទាស់តវ៉ានៅទៅ **ក.ស.ហ.វ.**។[63] ក្នុងករណីនេះការបកស្រាយអាចធ្វើឡើងផ្ទុយគ្នា ទាក់ទងនឹងការចុះហត្ថលេខានិងការអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ។ ករណីពាក្យបណ្ដឹងជំទាស់តវ៉ាត្រូវបានបញ្ជូនទៅ **ក.ស.ហ.វ.** ការបកស្រាយអាចត្រូវបានធ្វើឡើងផ្ទុយគ្នា ពាក់ព័ន្ធនឹងការចុះហត្ថលេខានិងការអនុវត្តកច្ចសន្យាលទ្ធកម្មសាធារណៈ។ ជាពិសេស នៅពេលដែលពាក្យបណ្ដឹងត្រូវបានដាក់ក្នុងអំឡុងពេលដែលបើកឱ្យមានការតវ៉ា អាជ្ញាធរដែលពាក់ព័ន្ធមិនត្រូវចាប់ផ្ដើមចុះកិច្ចសន្យាលទ្ធកម្មសាធារណៈនោះទេ។ ក៏ប៉ុន្តែ នៅពេលដែលការបកស្រាយបែបនេះអាចត្រូវបានយកមកអនុវត្ត ពាក្យពេចន៍នៅក្នុងសេចក្ដីព្រាងស្ដីពីលទ្ធកម្មសាធារណៈ មិនត្រូវបានពន្យល់ឱ្យច្បាស់លាស់ទេ ហេតុដូច្នេះ បណ្ដាលឱ្យមិនមានការលើកយកមកពិភាក្សាអំពីបញ្ហានៃបណ្ដឹងជំទាស់តវ៉ាប្រឆាំងនឹងសេចក្ដីសម្រេចរបស់ **ក.ស.ហ.វ.** រយៈពេលកំណត់ដើម្បីដាក់ពាក្យបណ្ដឹង ព្រមទាំងការចុះកិច្ចសន្យាក្នុងកាលៈទេសៈបន្ទាន់។[64] គម្រូច្បាប់ស្ដីពីលទ្ធកម្មសាធារណៈរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិ

[62] អង្គការសហប្រជាជាតិ, *សេចក្ដីណែនាំស្ដីពីការអនុម័តគម្រូច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ*, យោបល់លើ មាត្រា ៦៥

[63] សេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ, មាត្រា ៥១

[64] មើលជាការប្រៀបធៀប, អង្គការសហប្រជាជាតិ, *គម្រូច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ*, មិថុនា ២០១៤, មាត្រា ៦៥

ស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិបានចែងថា "ស្ថាប័នអនុវត្តលទ្ធកម្ម មិនត្រូវធ្វើសកម្មភាពណាមួយដែលនឹងនាំឱ្យកិច្ចសន្យាលទ្ធកម្មចូលជាធរមាន (...) នៅក្នុងនីតិវិធីលទ្ធកម្ម(...)[65]។

ចំពោះយន្តការដោះស្រាយវិវាទរបស់គូភាគីនៅក្នុងពេលអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈបានកំណត់បញ្ញត្តិថ្មីថា *"វិវាទទាំងឡាយណាដែលកើតឡើងក្នុងអំឡុងពេលនៃការអនុវត្តកិច្ចសន្យាលទ្ធកម្ម គូភាគីនៃកិច្ចសន្យាត្រូវដោះស្រាយតាមបញ្ញត្តិនិងយន្តការដែលមានចែងក្នុងកិច្ចសន្យា"*។[66] សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ មិនបានធ្វើការហាមឃាត់ឱ្យជាក់លាក់នូវទម្រង់ណាមួយនៃការដោះស្រាយវិវាទឡើយ ហើយក៏មិនផ្តល់ភាពច្បាស់លាស់នូវលទ្ធភាពសម្រាប់គូភាគីក្នុងការជ្រើសរើសសម្រាប់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដូចជាមជ្ឈត្តកម្មជាដើម។ សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ បានចែងថា **ក.ស.ហ.វ.** ត្រូវចេញបទប្បញ្ញត្តិ ដែលមានភ្ជាប់ជាមួយនឹងគំរូកិច្ចសន្យាលទ្ធកម្ម។[67] បច្ចុប្បន្ននេះ ការស្រាវជ្រាវនេះមិនទាន់បានស្វែងរកឃើញប្រកាសណាមួយចេញដោយ **ក.ស.ហ.វ.** ដើម្បីកំណត់ពីគំរូកិច្ចសន្យាលទ្ធកម្មនេះទេ។ យើងឃើញមានគម្រូកិច្ចសន្យាស្តីពីសេវាប្រឹក្សាយោបល់នៅក្នុងនីតិវិធីប្រតិបត្តិការស្តង់លើការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់គម្រោង/កម្មវិធីដែលបានទទួលហិរញ្ញប្បទានពីខាងក្រៅ នៅក្នុងប្រទេសកម្ពុជា ភាគ ២[68] និង ៣[69]។ ក្នុងចំណោមគម្រូកិច្ចសន្យាដែលបានផ្តល់ជូន គម្រូកិច្ចសន្យាសម្រាប់សេវាប្រឹក្សារបស់បុគ្គល បានកំណត់ខចែងស្តីពីការដោះស្រាយវិវាទមិនជាក់លាក់ដោយអនុញ្ញាតឱ្យគូភាគីនៃកិច្ចសន្យាជ្រើសរើសមជ្ឈត្តកម្ម ឬការសម្រេចសេចក្តីតាមប្រព័ន្ធតុលាការសម្រាប់ជាមធ្យោបាយក្នុងការដោះស្រាយវិវាទ។[70] ម៉្យាងវិញទៀត គម្រូកិច្ចសន្យាដែលមានចែងក្នុងនីតិវិធីប្រតិបត្តិការស្តង់ដារលើការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់

[65] គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ៦៥

[66] សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ៦៧

[67] ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ៥៣ និង សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ៥៦

[68] ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, *នីតិវិធីប្រតិបត្តិការស្តង់លើការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់គម្រោង/កម្មវិធីដែលបានទទួល ហិរញ្ញប្បទានពីខាងក្រៅ នៅក្នុងប្រទេសកម្ពុជា* ភាគII, ទំព័រ ៧៤ ដល់ ៧៥,ឯកសារនេះមាននៅ: https://gdicdm.mef.gov.kh/en/2020/10/05/10176.html

[69] ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, *នីតិវិធីប្រតិបត្តិការស្តង់លើការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់គម្រោង/កម្មវិធីដែលបានទទួល ហិរញ្ញប្បទានពីខាងក្រៅ នៅក្នុងប្រទេសកម្ពុជា* ភាគIII, ទំព័រ ៤៦២ ដល់ ៤៧១,ឯកសារនេះមាននៅ: https://gdicdm.mef.gov.kh/en/2020/10/05/10179.html

[70] ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, *នីតិវិធីប្រតិបត្តិការស្តង់លើការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់គម្រោង/កម្មវិធីដែលបានទទួល ហិរញ្ញប្បទានពីខាងក្រៅ នៅក្នុងប្រទេសកម្ពុជា* ភាគIII, ទំព័រ ៤៧១ ឃ្លា ១៥

គម្រោង/ កម្មវិធីដែលផ្តល់ហិរញ្ញប្បទានពីខាងក្រៅនៅក្នុងប្រទេសកម្ពុជាភាគទី ២ មិនបានកំណត់អំពីខចែង ស្តីពីការដោះស្រាយវិវាទណាមួយឡើយ។[71]

ទោះបីជាបានកំណត់ដូចខាងលើក៏ដោយ ដោយហេតុថាវិសាលភាពនៃស្វ័យភាពរបស់ភាគី គឺជាធាតុសំខាន់នៃសេចក្តីសម្រេច ក្នុងការចុះកិច្ចសន្យា ដែលរាល់បញ្ហាទាំងនេះ គួរតែត្រូវបានកំណត់នៅក្នុងឋានានុក្រមនៃច្បាប់នីមួយៗ។[72] ឧទាហរណ៍ មាត្រា ៤៥ នៃច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជនបានចែងថា កិច្ចសន្យាភាពជាដៃគូរវាងរដ្ឋនិងឯកជនអាចបញ្ចូលកិច្ចព្រមព្រៀងមជ្ឈត្តកម្ម ដើម្បីដោះស្រាយវិវាទ រវាងទីភ្នាក់ងារអនុវត្ត និងដៃគូឯកជន។[73] ហេតុដូច្នេះ សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ គួរកំណត់នូវកម្រិតនៃភាពជាក់លាក់យ៉ាងសមហេតុផលមួយក្នុងករណីសេចក្តីព្រាងច្បាប់នេះ កំណត់អំពីវិសាលភាពស្វ័យភាពនៃគូភាគី នៅក្រោមកិច្ចសន្យាលទ្ធកម្ម។ ច្បាប់ស្តីពីលទ្ធកម្មសាធារណៈគម្រូរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ ក៏មិនបានកំណត់អំពីលទ្ធភាពសំរាប់ប្រើប្រាស់យន្តការមជ្ឈត្តកម្មដែរ ព្រោះខចែងនេះត្រូវបានចាត់ទុកថា"ជាខចែងដ៏កម្រមួយ" នៅក្នុងលទ្ធកម្មសាធារណៈ។[74]

## ច. ការចូលរួមពីសាធារណៈជន

ក្នុងគោលបំណងសម្រាប់ការពង្រឹងប្រព័ន្ធលទ្ធកម្មសាធារណៈ អនុសាសន៍មួយក្នុងចំណោមអនុសាសន៍ផ្សេងទៀតដែលបានផ្តល់ដោយ អង្គការសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការសេដ្ឋកិច្ច (“OECD”) គឺរាជរដ្ឋាភិបាលគួរតែ"ជម្រុញឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធប្រកបដោយតម្លាភាពនិងប្រសិទ្ធភាព"។[75] ការចូលរួមពីភាគីពាក់ព័ន្ធ ជាពិសេសភាគីក្នុងវិស័យឯកជននិងសង្គមស៊ីវិល គួរតែធ្វើឡើងនៅពេលមានការកែប្រែណាមួយនៅក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈ។[76] គោល

---

[71] ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, *នីតិវិធីប្រតិបត្តិការស្តង់ដារលើការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់គម្រោង/កម្មវិធីដែលបានទទួល ហិរញ្ញប្បទានពីខាងក្រៅ នៅក្នុងប្រទេសកម្ពុជា* ភាគII, ទំព័រ ៧៤ ដល់ ៧៥

[72] សូមមើល, អង្គការសហប្រជាជាតិ, សេចក្តីណែនាំស្តីពីការអនុម័តគម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, ២០១២, យោបល់លើជំពូក ៧ (នីតិវិធីនៃការតវ៉ា) ទំព័រ ២៩៩ ដល់ ៣០០ : “ ជំពូក ៨ មិនបានចែងអំពីលទ្ធភាពក្នុងការដោះស្រាយជម្លោះតាមមជ្ឈត្តកម្ម ឬវិធីផ្សេងនោះទេ ដោយសារការប្រើប្រាស់មជ្ឈត្តកម្មនៅក្នុងនីតិវិធីលទ្ធកម្មមិនសូវមានជាទៀងទាត់ ហើយយោងតាមស្ថានភាពនៃជម្លោះតវ៉ាប្រឆាំងនីតិវិធីដែលតែងមានសកម្មភាពឬការសម្រេច ដោយស្ថាប័នអនុវត្តលទ្ធកម្មជាអ្នកប្តឹងតវ៉ាឬមិនប្តឹងតវ៉ាជាមួយនឹងសេចក្តីតម្រូវនៃគម្រូច្បាប់។ ទោះបីជាបែបនេះក្តី គម្រូច្បាប់មិនមានបំណងស្នើឱ្យស្ថាប័នអនុវត្តលទ្ធកម្មនិងអ្នកផ្គត់ផ្គង់ត្រូវបានហាមឃាត់មិនឱ្យដាក់ជម្លោះពាក់ព័ន្ធនឹងនីតិវិធីទៅដោះស្រាយតាមគម្រូច្បាប់នោះទេ។” សូមមើល *បទប្បញ្ញត្តិចេញដោយប្រធានធិបតីឥណ្ឌូនេស៊ីលើលទ្ធកម្មរបស់រដ្ឋាភិបាល (២០១៨)* មាត្រា៨៥ ដែលអនុញ្ញាតឱ្យប្រើប្រាស់មជ្ឈត្តកម្មសម្រាប់ដោះស្រាយជម្លោះរវាងស្ថាប័នអនុវត្តលទ្ធកម្មនិងអ្នកទទួលការ

[73]ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន, នស/រកម/១១២១/១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១, ឯកសារនេះមាននៅ https://ppp.mef.gov.kh/fileadmin/user_upload/Law_of_PPP_EN.pdf

[74] អង្គការសហប្រជាជាតិ, សេចក្តីណែនាំស្តីពីការអនុម័តគម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, យោបល់លើជំពូក៨ ឃ្លា១៧

[75] OECD, *OECD អនុសាសន៍របស់ក្រុមប្រឹក្សាលើលទ្ធកម្មសាធារណៈ*, ២០១៥, ទំព័រ៩ ឯកសារនេះមាននៅ: https://www.oecd.org/gov/public-procurement/OECD-Recommendation-on-Public-Procurement.pdf

[76] OECD, *OECD អនុសាសន៍របស់ក្រុមប្រឹក្សាលើលទ្ធកម្មសាធារណៈ*, ២០១៥, ទំព័រ៩, ផ្នែក៦

បំណងនៃការចូលរួមនេះ គឺដើម្បីអញ្ជើញភាគីដែលពាក់ព័ន្ធមកធ្វើការផ្តល់មតិយោបល់ ទៅលើសេចក្តីព្រាងវិសោធនកម្មច្បាប់ ក៏ដូចជាជូនដំណឹងដល់ភាគីដែលពាក់ព័ន្ធអំពីកាធ្វើការវិសោធនកម្មនេះផងដែរ។ ស្របពេលជាមួយគ្នានេះដែរ ការស្រាវជ្រាវបានឱ្យដឹងថា រាជរដ្ឋាភិបាលកម្ពុជាបានអញ្ជើញភាគីដែលពាក់ព័ន្ធមកផ្តល់មតិយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈនៅកម្ពុជា។

នៅក្នុងដំណាក់កាលបុរេដេញថ្លៃ ជាពិសេសការរៀបចំផែនការគម្រោងលទ្ធកម្មសាធារណៈ ច្បាប់ស្តីពីលទ្ធកម្មសាធារណៈមិនបានចែងអំពីឱកាសណាមួយសម្រាប់សាធារណជន ក្នុងការចូលរួមរៀបចំផែនការលទ្ធកម្មសាធារណៈនោះទេ។ ទាំងច្បាប់និងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ មិនបានបញ្ញត្តិអំពីឱកាសណាមួយនៃការបង្កើតឱ្យមានកិច្ចសន្ទនារវាងភាគីដែលពាក់ព័ន្ធ ដើម្បីធ្វើបច្ចុប្បន្នភាពទីផ្សារនិងផ្តល់ដំណឹងជូនភាគីដែលពាក់ព័ន្ធ ដែលអាចជាអ្នកដេញថ្លៃមានសក្តានុពល អំពីគោលបំណងនៃគម្រោងលទ្ធកម្មសាធារណៈនោះទេ។[77]

ពាក់ព័ន្ធនឹងការរៀបចំថវិកា ដែលជាវដ្តមួយការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បន្ទាប់ពីសេចក្តីព្រាងច្បាប់ស្តីពីថវិកាត្រូវបានព្រាងរួច ប្រជាពលរដ្ឋទូទៅមិនត្រូវបានអញ្ជើញឱ្យផ្តល់មតិយោបល់លើសេចក្តីព្រាងច្បាប់នេះទេ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាគួរតែព្យាយាម ១) បញ្ចូលនូវសេចក្តីសង្ខេបនៃគម្រោងលទ្ធកម្មជាមួយនឹងឯកសារថវិកាប្រចាំឆ្នាំទៅសភាដើម្បីពិនិត្យ ២) ផ្សព្វផ្សាយរបាយការណ៍ប្រតិបត្តិនិងផែនការសង្ខេបនៃគម្រោងលទ្ធកម្ម ក៏ដូចជាគម្រោងលទ្ធកម្មសាធារណៈដែលមានសក្តានុពល និង ៣) អនុញ្ញាតឱ្យមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋឱ្យកាន់តែច្រើន នៅក្នុងនីតិវិធីលទ្ធកម្មសាធារណៈ ក៏ដូចជាដំណើរការរៀបចំថវិកាសម្រាប់ការចំណាយលើលទ្ធកម្មសាធារណៈ។

## ៧. ការបើកចំហ និងបរិយាបន្ន

### ៧.១. ជម្រើសនៃនីតិវិធី

សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ មិនបានផ្លាស់ប្តូរជម្រើសនៃនីតិវិធីដែលមានសម្រាប់លទ្ធកម្មសាធារណៈនោះទេ។ “វិធីសាស្ត្រលទ្ធកម្មសម្រាប់ជ្រើសរើស” អ្នកផ្គត់ផ្គង់ អ្នកទទួលការ ឬអ្នកផ្តល់សេវា គឺជាការដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ ដែលត្រូវបានកំណត់ថា ជាវិធីសាស្ត្រដែលមាន ***“តម្លាភាពខ្ពស់”***។ ការដេញថ្លៃដោយប្រកួតប្រជែងសាធារណៈ គឺបើកចំហសម្រាប់អ្នកដេញថ្លៃក្នុងស្រុកនិងអន្តរជាតិទាំងអស់ ក្រោមទម្រង់ជាការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក ឬការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ។ សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈមិនបានចែងថា នីតិបុគ្គលត្រូវតែបានបង្កើតឡើងក្រោមច្បាប់នៃប្រទេសកម្ពុជា ដើម្បីមានលក្ខណៈសម្បត្តិពេញលេញក្នុងការចូលរួមការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិនោះទេ។ ផ្ទុយទៅវិញ ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក អាចត្រូវបានយល់ថា ជាការផ្តល់សិទ្ធិដល់អ្នកទទួលការក្នុងស្រុកនិងអ្នកផលិតទំនិញឬផ្តល់សេវាកម្មក្នុងស្រុក ក្នុងនាមជានីតិបុគ្គលដែលធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជាត្រូវតែគោរពតាមក្របខណ្ឌច្បាប់ រួមទាំងលក្ខខណ្ឌតម្រូវផ្សេងៗក្នុងការចុះបញ្ជីក្នុងស្រុក។

[77] OECD, *OECD អនុសាសន៍របស់ក្រុមប្រឹក្សាលើលទ្ធកម្មសាធារណៈ*, ២០១៥, ទំព័រ៩, ផ្នែក៦

នីតិវិធីផ្សេងទៀត ត្រូវបានកំណត់ជាមួយនឹងកម្រិតនៃការបើកចំហខុសៗគ្នា ចាប់ពីវិធីសាស្ត្រប្រកួតប្រជែងដែលមានកម្រិត ដូចជាការដេញថ្លៃមានកម្រិត ឬការពិគ្រោះថ្លៃ ទៅដល់វិធីសាស្ត្រលទ្ធកម្មដោយឡែក ដែលអ្នកដេញថ្លៃត្រូវបានជ្រើសរើសដោយមិនឆ្លងកាត់ការដេញថ្លៃណាមួយឡើយ។ សម្រាប់ការអនុវត្តដ៏ល្អ វិធីសាស្ត្រលទ្ធកម្មដោយឡែក ត្រូវបានប្រើប្រាស់សម្រាប់ករណីពិសេស និងករណីលើកលែងតែប៉ុណ្ណោះ ហើយស្ថិតនៅក្រោមការត្រួតពិនិត្យមើលយ៉ាងខ្ពស់ ដែលជាកម្មវត្ថុនៃការផ្សព្វផ្សាយមួយចំនួន។ សេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ បានកំណត់អំពីពីហេតុផលដែលវិធីសាស្ត្រលទ្ធកម្មដោយឡែកដែលត្រូវបានប្រើប្រាស់ ក៏ប៉ុន្តែ សេចក្ដីព្រាងច្បាប់នេះមិនតម្រូវឱ្យនីតិវិធីនៃការដេញថ្លៃបែបនេះត្រូវបានបង្ហាញឱ្យដឹងនោះទេ។

លើសពីនេះទៅទៀត សេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ គួរតែកំណត់នូវបទប្បញ្ញត្តិ ដើម្បីធ្វើមោឃភាពលើកិច្ចព្រមព្រៀង ឬកិច្ចសន្យាសម្រាប់គម្រោងលទ្ធកម្មសាធារណៈដែលត្រូវបានអនុវត្ត ហើយដែលមិនបានឆ្លងកាត់នីតិវិធីលទ្ធកម្មសាធារណៈត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ការកំណត់នូវបញ្ញត្តិបែបនេះ នឹងជួយទប់ស្កាត់អ្នកដេញថ្លៃ និងអ្នកទទួលការងកជន ក្នុងការឃុបឃិតជាមួយមន្ត្រីសាធារណៈ ដើម្បីទទួលបានការចុះកិច្ចសន្យាដោយមិនឆ្លងកាត់នីតិវិធីនៃការដេញថ្លៃដ៏ត្រឹមត្រូវ។

## ៧.២ លក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃ

មាត្រា ២៧ នៃច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ ដែលប្រែក្លាយជាមាត្រា ២៨ នៃសេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈនេះ ចែងថា អ្នកដេញថ្លៃត្រូវតែចុះបញ្ជីជាមួយ **ក.ស.ហ.វ.** ដើម្បីទទួលបានលក្ខណៈសម្បត្តិ ចូលរួមក្នុងគម្រោងលទ្ធកម្មសាធារណៈណាមួយ។ បន្ទាប់ពីចុះបញ្ជីហើយ **ក.ស.ហ.វ.**ត្រូវបានផ្ដល់សិទ្ធិឱ្យធ្វើចំណាត់ប្រភេទ និងចំណាត់ថ្នាក់អ្នកដេញថ្លៃ តាមកម្រិតសមត្ថភាពរបស់អ្នកដេញថ្លៃ ដើម្បីធានាការអនុវត្តកិច្ចសន្យា។ ក៏ប៉ុន្តែ សេចក្ដីណែនាំរបស់ **ក.ស.ហ.វ.** ស្ដីពីនីតិវិធីសម្រាប់ធ្វើបុរេលក្ខណសម្បត្តិអ្នកដេញថ្លៃចែងថា មានតែសហគ្រាសដែលបានចុះបញ្ជីក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ ដែលអាចស្នើសុំបុរេលក្ខណសម្បត្តិទៅស្ថាប័នអនុវត្តលទ្ធកម្ម ដើម្បីពិចារណាសម្រាប់ការកំណត់បុរេលក្ខណសម្បត្តិអ្នកដេញថ្លៃ។[78] ដូច្នេះ ក្រុមហ៊ុនមួយអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការដាក់ឯកសារដេញថ្លៃទៅស្ថាប័នអនុវត្តលទ្ធកម្មសាធារណៈ ក្នុងករណីតែក្រុមហ៊ុននោះបានចុះបញ្ជីនៅក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ។ ទោះបីជាយ៉ាងណា សេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈមិនបានកំណត់អំពីលក្ខណៈវិនិច្ឆ័យរើសអើងណាមួយដោយផ្អែកលើសញ្ជាតិរបស់ម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុននោះទេ។

---

[78] សេចក្ដីណែនាំលេខ ០១៤ សហវ ស្ដីពី នីតិវិធីសម្រាប់ធ្វើបុរេលក្ខណៈសម្បត្តិអ្នកដេញថ្លៃ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩ ហើយឯកសារនេះមមាននៅ http://gdpp.gov.kh/storage/law/file/8eGabZQYawWrfOkfO8WhqTLFPBGUWlehifXsblvc.pdf

## ៧.៣ ភាសាដែលប្រើប្រាស់

ជាមួយការពិចារណាលើការចូលរួមរបស់អ្នកដេញថ្លៃពីបរទេស សេចក្ដីសម្រេចរបស់ **ក.ស.ហ.វ.** លេខ ០០២ សហវ. អលសា ស្ដីពីវិធីសាស្ត្រនិងនិតិវិធីលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ចែងថា សេចក្ដីប្រកាសស្ដីពីការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិត្រូវធ្វើជាភាសាខ្មែរនិងភាសាបរទេស។[79] ទោះជាយ៉ាងណាក៏ដោយ មានយន្តការតិចតួចដើម្បីសម្រួលដល់ការចូលរួមពីក្រុមហ៊ុនបរទេសឬវិនិយោគិន/សហគ្រិនបរទេសដែលប្រកបអាជីវកម្មនៅកម្ពុជា។ បន្ថែមពីលើលក្ខខណ្ឌនៃការចុះបញ្ជីខាងលើ រាល់ឯកសារដេញថ្លៃ ក៏តម្រូវឱ្យបកប្រែជាភាសាខ្មែរផងដែរ ប្រសិនបើរាល់ឯកសារទាំងអស់នោះត្រូវបានធ្វើឡើងជាភាសាបរទេស។[80]

សេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ មិនបានកែប្រែបទប្បញ្ញត្តិដែលតម្រូវឱ្យកិច្ចសន្យាលទ្ធកម្មត្រូវតែធ្វើឡើងជាភាសាខ្មែរនោះទេ ហើយកិច្ចសន្យាជាភាសាខ្មែរមានមានឧត្តមានុភាពលើភាសាដទៃទៀត។[81] នេះផ្ទុះបញ្ចាំងអំពីជម្រើសដែលផ្ដល់ដោយគម្រូច្បាប់ស្ដីពីលទ្ធកម្មសាធារណៈរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្ដីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ ដែលកំណត់ថា ភាសាចម្បងត្រូវតែជាភាសាផ្លូវការរបស់រដ្ឋនោះ ប៉ុន្តែស្របពេលជាមួយគ្នានេះដែរ គម្រូច្បាប់ស្ដីពីលទ្ធកម្មសាធារណៈរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្ដីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ ក៏បានអនុញ្ញាតឱ្យមានលទ្ធភាពជ្រើសរើស "ភាសាដែលជាទម្លាប់ ប្រើប្រាស់ក្នុងពាណិជ្ជកម្មអន្តរជាតិ"។[82] ច្បាប់និងសេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ មិនបានកម្រិតការប្រើប្រាស់ភាសាបន្ទាប់បន្សំទេ ដោយរក្សាទុកសេរីភាពដល់អ្នកដេញថ្លៃជ្រើសរើសភាសាបរទេសបរទេសបន្ទាប់បន្សំនោះ។

## ៧.៤ ជម្រើសរូបិយប័ណ្ណសម្រាប់ការទូទាត់

ជាទូទៅ រាល់ការទូទាត់ក្រោមកិច្ចសន្យាលទ្ធកម្ម ត្រូវតែធ្វើឡើងតាមរយៈរូបិយវត្ថុខ្មែរ លើកលែងតែកិច្ចសន្យាដែលត្រូវបានប្រគល់ឱ្យ តាមរយៈការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិនោះទេ ដែលការទូទាត់ប្រាក់ ត្រូវធ្វើឡើងជារូបិយប័ណ្ណបរទេសដូចមានចែងក្នុងនៅឯកសារដេញថ្លៃ។ ជាកម្មវត្ថុក្នុងការបញ្ជាក់បន្ថែមនៅក្នុងកិច្ចសន្យា អត្រាប្ដូរប្រាក់ត្រូវកំណត់ដោយផ្អែកលើ អត្រាប្ដូរប្រាក់ដែលកំណត់ដោយធនាគារកណ្ដាលនៃកម្ពុជាពោលគឺធនាគារជាតិនៃកម្ពុជា ដើម្បីចៀសវាងការបាត់បង់ ឬហានិភ័យនៃអត្រាប្ដូរប្រាក់។

---

[79] សេចក្ដីណែនាំលេខ០០២ សហវ.អលសា ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្ដីពីវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ទំព័រទី១០ ផ្នែក ៤.២.១.

[80] ច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ, មាត្រា ៥៤; សេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ, មាត្រា ៥៧

[81] ច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ, មាត្រា ៥៤; សេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ, មាត្រា ៥៧

[82] មាត្រា១៣ នៃគម្រូច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ របស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្ដីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ ឆ្នាំ២០១១

## ៧.៥ ចំនួនដេញថ្លៃអប្បបរមា

ទាក់ទងនឹងយន្តការដើម្បីធានាថា មានការដាក់សំណើឯកសារដេញថ្លៃពីសំណាក់អ្នកដេញថ្លៃដទៃទៀត ច្បាប់ស្តីពីលទ្ធកម្មសាធារណៈបានចែងអំពីចំនួនអ្នកដេញថ្លៃអប្បបរមា យ៉ាងហោចណាស់បី (០៣) នាក់។ ក្នុងករណីដែលមានសំណើដេញថ្លៃតិចជាង ០៣ ឯកសារដេញថ្លៃមិនត្រូវបានបើក ហើយនីតិវិធីដេញថ្លៃត្រូវចាប់ផ្តើមឡើងវិញ

## ៧.៦ សហគ្រាសធុនតូច និងមធ្យម

ទាំងច្បាប់និងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ មិនបានកំណត់អំពីរបបជាក់លាក់ណាមួយ ដែលជួយសម្រួលដល់ការចូលរួមរបស់សហគ្រាសធុនតូចនិងមធ្យមនោះទេ។ យោងតាមអង្គការសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការសេដ្ឋកិច្ច (“OECD”) សហគ្រាសធុនតូចនិងមធ្យម ("SMEs") ត្រូវបានចាត់ទុកថាជាគន្លឹះនៃកំណើននិងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសម។[83] ក៏ប៉ុន្តែសហគ្រាសធុនតូចនិងមធ្យមមានទំនោរទៅរកការទូទាត់ប្រាក់ដោយខុសច្បាប់ នៅពេលប្រឈមមុខនឹងលក្ខខណ្ឌតម្រូវនៃបន្ទុកពន្ធ។[84] អាស្រ័យហេតុនេះ គណៈកម្មការអឺរ៉ុបក៏ដូចជាប្រទេសមួយចំនួនដូចជា ប្រទេសចិននិងប្រទេសអេស្ប៉ាញបានអនុម័តវិធានការផ្សេងៗ ដើម្បីជំរុញឱ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់សហគ្រាសធុនតូចនិងមធ្យមក្នុងលទ្ធកម្មសាធារណៈ។[85]

## ៧.៧ សហគមន៍ក្នុងស្រុក

ទាំងច្បាប់និងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ បានកំណត់នីតិវិធីជាក់លាក់មួយដែលហៅថា *ការចុះកិច្ចសន្យាជាមួយនឹងសហគមន៍*ដែលជាវិធីសាស្ត្រលទ្ធកម្មដោយឡែក ជាយន្តការរួមបញ្ចូលដែលអាចត្រូវបានអនុម័តជាមួយការយល់ព្រមពី**ក.ស.ហ.វ.**។[86] ដូចបានកំណត់ដោយច្បាប់ ការចុះកិច្ចសន្យាជាមួយនឹងសហគមន៍ គឺជាវិធីសាស្ត្រលទ្ធកម្មដែលត្រូវប្រើសំដៅលើកទឹកចិត្តសហគមន៍ក្នុងស្រុកដើម្បីប្រើប្រាស់កម្លាំងពលកម្ម ចំណេះដឹង និងសម្ភារៈក្នុងស្រុក សម្រាប់ចូលរួមការអភិវឌ្ឍសហគមន៍។[87] ច្បាប់គម្រូស្តីពីលទ្ធកម្មសាធារណៈរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ មានចែងបញ្ញត្តិមួយចំនួន ដែលសំដៅលើក្រុមជាក់លាក់មួយជាមួយ

---

[83] OECD, *កម្រងឧត្តមានុវត្តន៍នៃការអនុវត្តលទ្ធកម្មសាធារណៈសម្រាប់សុចរិតភាព*, ទំព័រ ១២

[84] OECD, *កម្រងឧត្តមានុវត្តន៍នៃការអនុវត្តលទ្ធកម្មសាធារណៈសម្រាប់សុចរិតភាព*, ទំព័រ ១២

[85]. OECD, *កម្រងឧត្តមានុវត្តន៍នៃការអនុវត្តលទ្ធកម្មសាធារណៈសម្រាប់សុចរិតភាព*, ទំព័រ ១២ ដល់១៤

[86] ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ១៣; សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ១៣ (ឃ)

[87] ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ១៣; សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ, មាត្រា ១៣ (ឃ)

នឹងការពិចារណាដើម្បីជៀសវាងការរើសអើងមិនសមហេតុផលណាមួយ ដោយសារតែលទ្ធកម្មសាធារណៈ អាចជាឧបករណ៍មួយ សម្រាប់អនុវត្តគោលនយោបាយសេដ្ឋកិច្ចសង្គមរបស់រដ្ឋដែលពាក់ព័ន្ធ។[88]

## ៧.៨ លទ្ធកម្មប្រកបដោយចីរភាព

ទំនាក់ទំនង អាចត្រូវបានធ្វើឡើងរវាងការផ្សារភ្ជាប់គ្នា និងគោលនយោបាយសេដ្ឋកិច្ចសង្គម លទ្ធកម្មសាធារណៈ និងគោលគំនិតនៃ "លទ្ធកម្មប្រកបដោយចីរភាព" ដែលត្រូវបានកំណត់នៅក្នុងបញ្ញត្តិ នៃសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។

អនុលោមតាមសន្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ លទ្ធកម្មប្រកបដោយចីរភាព មានន័យថា *"នីតិវិធីលទ្ធកម្មដែលគិតពិចារណាលើ ការកាត់បន្ថយជាអតិបរមានៃផលប៉ះពាល់ដ៏មានសក្តានុពលលើបរិស្ថាន ប្រព័ន្ធអេកូឡូស៊ី និងនិរន្តរភាពនៃការអភិវឌ្ឍន៍សហគមន៍"*។

អនុលោមតាមសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (មាត្រា ៥៤ ថ្មី) ការអនុវត្តលទ្ធកម្មសាធារណៈ ត្រូវអនុលោមតាមបរិបទនៃលទ្ធកម្មប្រកបដោយចីរភាព ដើម្បីរួមចំណែកដល់ការរក្សាចីរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបរិស្ថាន។ ការកំណត់ពេលវេលា វិធាន និងនីតិវិធី សម្រាប់ការអនុវត្តលទ្ធកម្មប្រកបដោយចីរភាព ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក.ស.ហ.វ.។

*គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ* មិនបានប្រើពាក្យ "ចីរភាព" ឬ "លទ្ធកម្មប្រកបដោយចីរភាព" នោះទេ។ ក៏ប៉ុន្តែគណៈកម្មការនៃអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ (“UNCITRAL”) បានកត់សម្គាល់ថា ទោះបីជាមិនមានការឯកភាពគ្នាលើនិយមន័យនៃពាក្យ "លទ្ធកម្មប្រកបដោយចីរភាព" ក៏ដោយ វាត្រូវបានចាត់ទុកថា ជាវិធីសាស្ត្រដ៏យូរអង្វែងចំពោះគោលនយោបាយលទ្ធកម្ម ដែលបានឆ្លុះបញ្ចាំងក្នុងការគិតពិចារណាលើផលប៉ះពាល់ពេញលេញនៃលទ្ធកម្មលើសង្គម និងបរិស្ថាន ជាឧទាហរណ៍ តាមរយៈការលើកកម្ពស់ការគណនាចំណាយថ្លៃដើមតាមវិធីសាស្ត្រវដ្តជីវិត ការបង់ថ្លៃចំណាយលើការបញ្ចេញចោលនូវកាកសំណល់ និងផលប៉ះពាល់លើបរិស្ថាន។[89] មតិយោបល់លើគម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ បានចង្អុលបង្ហាញថា ច្បាប់នេះបានអនុញ្ញាតឱ្យមានការលើកកម្ពស់ចីរភាពតាមរយៈការធ្វើលទ្ធកម្ម តាមរយៈលក្ខណៈវិនិច្ឆ័យគុណវុឌ្ឍិ (ក្រោមមាត្រា ៩ ដែលអនុញ្ញាតឱ្យស្ថាប័នអនុវត្តលទ្ធកម្មកំណត់អំពីគុណវុឌ្ឍិបរិស្ថាន និងក្រមសីលធម៌ និងស្តង់ដាផ្សេងទៀត ដែលអាចរួមបញ្ចូលជាមួយលក្ខខណ្ឌតម្រូវនៃការធ្វើពាណិជ្ជកម្មដោយស្មើភាព)។ ពាក្យថាលទ្ធកម្មប្រកបដោយចីរភាព

---

[88] អង្គការសហប្រជាជាតិ, សេចក្តីណែនាំស្តីពីការអនុម័តគម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ឆ្នាំ២០១២, ទំព័រ៥២ ដល់ ៥៤ ឯកសារនេះមាននៅ https://uncitral.un.org/sites/uncitral.un.org/files/media-documents/uncitral/en/guide-enactment-model-law-public-procurement-e.pdf

[89] អង្គការសហប្រជាជាតិ, សេចក្តីណែនាំស្តីពីការអនុម័តគម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ឆ្នាំ២០១២, ទំព័រ៤ ដល់៥

ក៏អាចប្រើជាពាក្យដែលគ្របដណ្តប់ម្រាប់ការតាមដានគោលនយោបាយសង្គម សេដ្ឋកិច្ច និងបរិស្ថាន តាមរយៈលទ្ធកម្ម ដូចជា៖

- កត្តា "សង្គម"៖ លក្ខខណ្ឌការងារ បរិយាបន្នសង្គម ការប្រឆាំងរាល់អំពីរើសអើង

- កត្តា "សីលធម៌"៖ សិទ្ធិមនុស្ស ពលកម្មកុមារ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និង

- លទ្ធកម្មបរិស្ថាន/បៃតង។[90]

## ផ្នែកទី៣៖ អនុសាសន៍ណែនាំ

ផ្នែកនេះនឹងផ្តល់ជាអនុសាសន៍ណែនាំ ផ្អែកលើបញ្ហាដែលត្រូវបានរកឃើញខាងលើតាមលំដាប់លំដោយនៅក្នុងផ្នែកខាងលើ។

### ក. តម្លាភាព

១. ព័ត៌មានសាធារណៈ

ក. ការណ៍ដែលមិនបានបញ្ញត្តិដោយច្បាប់ពាក់ព័ន្ធនឹងការផ្សព្វផ្សាយជាសាធារណៈចំពោះនីតិវិធីចរចា និងកិច្ចលទ្ធកម្មមានប្រភពតែមួយ៖ សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈគួរតែកំណត់ឱ្យច្បាស់អំពីការផ្សព្វផ្សាយនីតិវិធីទាំងនេះ។

ខ. កង្វះនូវបញ្ញត្តិច្បាប់ចំពោះគោលការណ៍នៃពេលវេលាគ្រប់គ្រាន់៖ រាជរដ្ឋាភិបាលកម្ពុជាគួរតែអនុម័តច្បាប់ដើម្បីកំណត់ពេលវេលាជាក់លាក់សម្រាប់ ១) ការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ និង ២) ការផ្តល់ចម្លើយឬការប្រជុំដើម្បីធ្វើការស្រាយបំភ្លឺ។

២. ថ្នាលអនឡាញសម្រាប់លទ្ធកម្មសាធារណៈ

សំរាប់គោលបំណងនៃតម្លាភាព ក៏ដូចជាការផ្តល់លទ្ធភាពទទួលបានព័ត៌មានទាក់ទងនឹងលទ្ធកម្មសាធារណៈដល់ប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធ រាជរដ្ឋាភិបាលកម្ពុជាគួរតែបង្កើតថ្នាលអនឡាញមួយសម្រាប់ផ្សព្វផ្សាយព័ត៌មានមិនសម្ងាត់ទាំងអស់ពាក់ព័ន្ធនឹងនីតិវិធីលទ្ធកម្មសាធារណៈទាំងមូល។ ជាឧទាហរណ៍នៃព័ត៌មានដែលអាចត្រូវបានផ្សព្វផ្សាយរួមមាន សេចក្តីប្រកាសស្តីពីការដេញថ្លៃនិងការកែប្រែទានាពាក់ព័ន្ធនឹងសេចក្តីប្រកាសនោះ ផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលកម្ពុជា កិច្ចសន្យាដែលត្រូវបានប្រគល់ពីមុននិងកិច្ចសន្យាបច្ចុប្បន្ន និងអត្តសញ្ញាណរបស់អ្នកដេញថ្លៃឈ្នះ។ សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ក៏អាចចែងអំពីតម្រូវការរក្សាការសម្ងាត់សម្រាប់ព័ត៌មានផ្តល់ដោយអ្នកផ្គត់ផ្គង់ ឬ

[90] សូមមើលផងដែរគម្រូច្បាប់របស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ មាត្រា ២ (ទ)៖

(ទ) "គោលនយោបាយសង្គម និងសេដ្ឋកិច្ច" សំដៅលើគោលនយោបាយបរិស្ថាន សង្គម សេដ្ឋកិច្ច និងគោលនយោបាយផ្សេងទៀតនៃរដ្ឋ ដែលអនុញ្ញាតិឬតម្រូវដោយបទប្បញ្ញត្តិលទ្ធកម្ម ឬបញ្ញត្តិផ្សេងទៀតនៃច្បាប់របស់រដ្ឋដែលត្រូវយកមកអនុវត្តដោយស្ថាប័នអនុវត្តលទ្ធកម្មនៅក្នុងនីតិវិធីលទ្ធកម្ម។ [រដ្ឋដែលអនុវត្តអាចពង្រីកកថាខណ្ឌនេះដោយចែងពីបញ្ជីនៃគោលនយោបាយ។]

អ្នកទទួលការ ដូចដែលបានចែងនៅក្នុង មាត្រា ២៤(២) នៃ*គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ* ដែលបញ្ជាក់ថា "ស្ថាប័នអនុវត្តលទ្ធកម្មត្រូវត្រួតពិនិត្យសំណុំបែបបទសំរាប់បុរេលក្ខណៈសម្បត្តិឬបុរេជ្រើសរើស ព្រមទាំងបញ្ជូនសំណុំបែបបទនេះដោយប្រុងប្រយ័ត្នដើម្បីចៀសវាងការបែកធ្លាយព័ត៌មានទៅកាន់អ្នកផ្គត់ផ្គង់ឬអ្នកទទួលការដែលជាគូប្រកួតប្រជែង ឬបុគ្គលផ្សេងទៀតដែលមិនត្រូវបានអនុញ្ញាតិឱ្យដឹងពីព័ត៌មាននេះ”។ លើកលែងតែព័ត៌មានមួយចំនួន សេចក្តីជូនដំណឹងជាសាធារណៈស្តីពីការប្រគល់កិច្ចសន្យានិងការបើកឯកសារដេញថ្លៃ គឺព័ត៌មានចាំបាច់ដែលត្រូវផ្សព្វផ្សាយក្នុងកំណត់ត្រាឯកសារ។

៣. ការបកស្រាយពីសេចក្តីសម្រេចប្រគល់កិច្ចសន្យា៖ ដូចបានរៀបរាប់ខាងលើ លើកលែងតែព័ត៌មានសម្ងាត់ នីតិវិធីលទ្ធកម្មទាំងមូលត្រូវតែមានតម្លាភាព។ តម្លាភាពនេះក៏រួមបញ្ចូលផងដែរ នូវកិច្ចសន្យាដែលត្រូវបានចុះហត្ថលេខារវាងស្ថាប័នអនុវត្តលទ្ធកម្ម និងអ្នកដេញថ្លៃដែលកិច្ចសន្យាត្រូវបានប្រគល់ឱ្យ។

## ខ. ការគ្រប់គ្រងល្អ

១. បញ្ហាលើការគ្រប់គ្រងមូលនិធិសាធារណៈពាក់ព័ន្ធនឹងគម្រោងលទ្ធកម្មដែលកំពុងដំណើរការ៖ ច្បាប់ដែលបញ្ញត្តិលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាពិសេសទាក់ទងនឹងគម្រោងលទ្ធកម្ម គួរតែលើកឡើងអំពីការរៀបចំថវិកាសម្រាប់គម្រោងលទ្ធកម្មដែលកំពុងដំណើរការ។ ជាពិសេស ដូចដែលបានរៀបរាប់ខាងលើ បញ្ហានេះអាចត្រូវបានកែលម្អបន្ទាប់ពីការអនុម័តយ៉ាងពេញលេញលើ ១) ក្របខណ្ឌថវិការយៈពេលមធ្យម ២) ការធ្វើសមាហរណកម្មថវិកាមូលធននិងថវិកាចរន្ត និង ៣) ការធ្វើសមាហរណកម្មរវាងលទ្ធកម្មសាធារណៈ ជាមួយការរៀបចំថវិកា ការអនុវត្តថវិកា និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

២. ច្បាប់និងបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអាចពិចារណាលើ ១) ការជម្រុញការអនុវត្តក្របខណ្ឌចំណាយរយៈពេលមធ្យម សំរាប់គម្រោងលទ្ធកម្មសាធារណៈ ២) សេចក្តីតម្រូវឱ្យមានផែនការចំណាយសង្ខេប សម្រាប់គម្រោងលទ្ធកម្មសាធារណៈភ្ជាប់ជាមួយនឹងឯកសារថវិកាប្រចាំឆ្នាំ ដើម្បីឱ្យសភាពិនិត្យនិងផ្សព្វផ្សាយ និង ៣) ការបង្កើតឱ្យមានរបាយការណ៍អនុវត្តសង្ខេបសំរាប់គម្រោងលទ្ធកម្មសាធារណៈភ្ជាប់ជាមួយនឹងឯកសារថវិកាប្រចាំឆ្នាំដើម្បីឱ្យសភាពិនិត្យនិងផ្សព្វផ្សាយ។

៣. ហានិភ័យនៃឥទ្ធិពលមិនត្រឹមត្រូវលើគណៈកម្មាធិការលទ្ធកម្មដោយសារកង្វះខាតនៃយន្តការការពារ៖ រាជរដ្ឋាភិបាលកម្ពុជាគួរតែពិចារណាលើការអនុម័តច្បាប់ ការដាក់ចេញយន្តការជាក់លាក់មួយ ដើម្បីផ្តល់ការការពារដល់គណៈកម្មាធិការលទ្ធកម្ម និងបុគ្គលរាយការណ៍។ ឧទាហរណ៍ ជាផ្នែកមួយនៃ

កំណែទម្រង់លទ្ធកម្មសាធារណៈរបស់ខ្លួនក្នុងឆ្នាំ ២០០២ និងសម្រាប់គោលបំណងផ្តល់ការការពារដល់អាជ្ញាធរលទ្ធកម្ម ច្បាប់ស្តីពីលទ្ធកម្មសាធារណៈរបស់ប្រទេសតួកគី បានចែងថា អាជ្ញាធរលទ្ធកម្មត្រូវមានស្វ័យភាពផ្នែកហិរញ្ញវត្ថុ និងឯករាជ្យក្នុងការបំពេញភារកិច្ចរបស់ខ្លួន[91]។

## គ. គណនេយ្យភាព និងសុចរិតភាព

១. កំណត់ការដេញថ្លៃប្រកួតប្រជែងសាធារណៈជាវិធីសាស្ត្រចាប់ផ្តើមនៃលទ្ធកម្ម។

២. ផ្តល់លទ្ធភាពឱ្យស្ថាប័នអនុវត្តលទ្ធកម្មដើរតួជាអង្គភាពទិញទំនិញជាកញ្ចប់និងកំណត់ខ្សែសង្វាក់នៃការបញ្ជាទិញឱ្យបានច្បាស់លាស់។

៣. សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈគួរតែដាក់បញ្ចូលនូវកាតព្វកិច្ចដើម្បីឱ្យស្ថាប័នអនុវត្តលទ្ធកម្មផ្តល់សេចក្តីថ្លែងការណ៍ខ្លីមួយអំពីហេតុផល ក្នុងករណីមានការលុបចោលលទ្ធកម្ម ដែលវិធីសាស្ត្រក្នុងការផ្តល់សេចក្តីថ្លែងការណ៍នេះមានភាពគ្រប់គ្រាប់ដែលអាចឱ្យធ្វើការត្រួតពិនិត្យសេចក្តីសម្រេចឡើងវិញបាន នូវការសម្រេចចិត្តដ៏ត្រឹមត្រូវមួយ។

៤. ដាក់កាតព្វកិច្ចសម្រាប់ស្ថាប័នអនុត្តលទ្ធកម្ម ក្នុងការផ្សព្វផ្សាយភ្លាមៗនូវសេចក្តីជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យាលទ្ធកម្ម និងព័ត៌មានលម្អិតក្នុងអំឡុងពេលនៃនីតិវិធីលទ្ធកម្ម។

៥. សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ គួរតែដាក់បញ្ចូលនូវស្តង់ដារដើម្បីរក្សាទុកកំណត់ត្រាក្នុងគោលបំណងតាមដាននីតិវិធីនៃការធ្វើសម្រេចសេចក្តី ដែលធ្វើឡើងដោយស្ថាប័នអនុវត្តលទ្ធកម្ម។

៦. កង្វះខាតនៃទីភ្នាក់ងារឯករាជ្យ ទទួលបន្ទុកជាពិសេសលើលទ្ធកម្មសាធារណៈ៖ ដើម្បីផ្ទេរភារកិច្ចទៅអង្គភាពដាច់ដោយឡែកសម្រាប់ត្រួតពិនិត្យលទ្ធកម្មសាធារណៈ។[92] ក្នុងករណីដែលអនុសាសន៍នេះត្រូវបានយកមកពិចារណា នាំឱ្យមានភាពចាំបាច់ត្រូវធ្វើវិសោធនកម្មច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ព្រះរាជក្រមលេខនស/រកម/០១៩៦/១៨)[93] ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ និងអនុក្រឹត្យលេខ៧៥/អនក/បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីវិសោធនកម្មអនុក្រឹត្យលេខ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច

---

[91] ច្បាប់ស្តីពីលទ្ធកម្មសាធារណៈរបស់ប្រទេសតួកគី មាត្រា ៥៣ ឯកសារនេះមាននៅ: http://www2.ihale.gov.tr/english/4734_English.pdf

[92] សូមមើលជាឧទាហរណ៍ កំណែទម្រង់លទ្ធកម្មសាធារណៈឆ្នាំ២០០២របស់ប្រទេសតួកគី ដែលបង្កើតអាជ្ញាធរលទ្ធកម្មសាធារណៈ នៅក្នុងក្រុមការងារប្រឆាំងអំពើពុករលួយរបស់ក្រុមប្រទេសទាំង២០ (G20), OECD, *គម្រងឧត្តមានុវត្តន៍នៃការអនុវត្តលទ្ធកម្មសាធារណៈសម្រាប់សុចរិតភាព*, ឆ្នាំ២០១៤ ទំព័រ ១៧ ដល់១៨

[93] ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០) ឯកសារមាននៅ: https://gdia.mef.gov.kh/wp-content/uploads/2012/04/anukret04.pdf

និងហិរញ្ញវត្ថុ។ ដោយសារតួនាទីសំខាន់របស់ **ក.ស.ហ.វ.** ត្រូវបានចែងយ៉ាងច្បាស់ដោយលិខិតូបករណ៍ទាំងអស់នោះ ជាពិសេស "ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យលើប្រតិបត្តិការលទ្ធកម្មសាធារណៈរបស់ក្រសួង/ស្ថាប័ន ខេត្ត/ក្រុង និង គ្រឹះស្ថានរដ្ឋ ឬគ្រឹះស្ថានស្វយ័តសាធារណៈ"។

៧. រាជរដ្ឋាភិបាលកម្ពុជាអាចពិចារណាប្រើប្រាស់ពាក្យនៅក្នុងមាត្រា៣៤(៥)និង៣៥(៤)នៃ*ច្បាប់ស្តីពីលទ្ធកម្មសាធារណៈគម្រូរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ* ដើម្បីបញ្ជាក់ថា តើសេចក្តីជូនដំណឹងនឹងត្រូវផ្សព្វផ្សាយដែរឬយ៉ាងណា ប្រសិនបើវិធីសាស្ត្រដេញថ្លៃដោយមិនប្រកួតប្រជែងដោយត្រូវបានជ្រើសរើស ។

៨. ដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីលទ្ធកម្មសាធារណៈ ដើម្បីឱ្យសេចក្តីសម្រេចដែលធ្វើដោយស្ថាប័នអនុវត្តលទ្ធកម្មឬការឯកភាពជាមុនរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវតែមានភាពត្រឹមត្រូវ ដោយត្រូវមានកំណត់ត្រានៃនីតិវិធីលទ្ធកម្មដែលពាក់ព័ន្ធច្បាស់លាស់។

៩. ធ្វើការវិនិច្ឆ័យអំពីរបបគតិយុត្ត ដើម្បីរារាំងអំពើពុករលួយដោយប្រគល់ជូនស្ថាប័នដែលពាក់ព័ន្ធដូចជា អង្គភាពប្រឆាំងអំពើពុករលួយ ដើម្បីពិនិត្យនិងស៊ើបអង្កេតលើភាពមិនប្រក្រតីណាមួយក្នុងអំឡុងពេលវដ្តលទ្ធកម្មសាធារណៈ។[94] បទល្មើសពុករលួយនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយអាចត្រូវបានយកមកពិចារណាកែសម្រួលឱ្យមានសមាគតិភាព។

១០. សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈគួរចែងថា កិច្ចព្រមព្រៀងទាំងអស់ដែលធ្វើឡើងដោយមិនគោរពតាមច្បាប់ស្តីពីលទ្ធកម្មសាធារណៈត្រូវចាត់ទុកជាមោឃៈ ដើម្បីជៀសវាងការឃុបឃិតគ្នារវាងអ្នកដេញថ្លៃឯកជន និងមន្ត្រីសាធារណៈដែលទទួលខុសត្រូវលើលទ្ធកម្ម។

## ឃ. ការគ្រប់គ្រង និង ការត្រួតពិនិត្យ

១. កង្វះខាតនៃប្រកាសស្តីពីនីតិវិធីសម្រាប់ការប្រគល់និងទទួលទំនិញនិងសំណង់៖ **ក.ស.ហ.វ.** ចាំបាច់ត្រូវអនុម័តប្រកាសនេះ។

២. សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ត្រូវលើកឡើងអំពីយន្តការនៃកិច្ចការពារបរិស្ថាន សង្គម និងអភិបាលកិច្ច សម្រាប់អ្នកដេញថ្លៃអនុវត្តតាម។

[94] សូមមើលជាឧទាហរណ៍ តួនាទីរបស់មន្ត្រីប្រឆាំងអំពើពុករលួយនៅក្នុងលទ្ធកម្មសាធារណៈនៅក្នុងប្រទេសអាហ្សង់ទីន, ក្រុមការងារប្រឆាំងអំពើពុករលួយរបស់ក្រុមប្រទេសទាំង២០ (G20), OECD, កម្រងឧត្តមានុវត្តន៍នៃការអនុវត្តលទ្ធកម្មសាធារណៈសម្រាប់សុចរិតភាព, ឆ្នាំ២០១៤, ទំព័រ២៨ដល់២៩; មើលផងដែរ ច្បាប់ស្តីពីការផ្គត់ផ្គង់និងលទ្ធកម្មសាធារណៈរបស់ប្រទេសថៃ (ឆ្នាំ២០១៧), ផ្នែក IV ស្តីពីគណៈកម្មាធិការសហប្រតិបត្តិប្រឆាំងអំពើពុករលួយ

៣. កង្វះខាតនៃប្រកាសស្តីពីនីតិវិធីសម្រាប់ការបង្កើតគណៈកម្មាធិការសម្រាប់ការប្រគល់និងទទួលទំនិញនិងសំណង់៖ **ក.ស.ហ.វ.** ចាំបាច់ត្រូវអនុម័តប្រកាសនេះ។ គម្រោងលទ្ធកម្មសាធារណៈណាមួយដែលត្រូវបានបញ្ចប់ ត្រូវទទួលបានការពិនិត្យឡើងវិញ និងទទួលស្គាល់ការទទួលយកដោយអាជ្ញាធរមានសមត្ថកិច្ច នៅក្រោមច្បាប់ បទប្បញ្ញត្តិ និងកិច្ចសន្យាលទ្ធកម្មជាធរមាន។ បន្ថែមពីលើនេះទៀត លទ្ធផលនៃគម្រោងដែលបានបញ្ចប់ទាំងអស់នោះត្រូវចាត់ទុកជាទ្រព្យសម្បត្តិរបស់រដ្ឋដែលត្រូវចុះបញ្ជីឱ្យបានត្រឹមត្រូវក្នុងតារាងតុល្យការរបស់រដ្ឋ និងគ្រប់គ្រងដោយអាជ្ញាធរមានសមត្ថកិច្ចសម្រាប់ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

៤. កង្វះខាតនៃការវាយតម្លៃឱ្យបានទៀងទាត់នូវហានិភ័យ៖ រាជរដ្ឋាភិបាលកម្ពុជាត្រូវអនុម័តវិធីសាស្ត្រមួយ ដើម្បីតម្រូវឱ្យស្ថាប័នគ្រប់គ្រងលទ្ធកម្ម និងស្ថាប័នអនុវត្តលទ្ធកម្ម កំណត់អំពីហានិភ័យនៃភាពមិនប្រក្រតីនៃអំពើពុករលួយដែល អាចកើតមាននៅក្នុងលទ្ធកម្មសាធារណៈឱ្យបានទៀងទាត់។

៥. ការការពារផ្លូវច្បាប់ចំពោះបុគ្គលរាយការណ៍ ៖

- យន្តការនៃការរាយការណ៍ត្រូវបង្កើតឡើងសម្រាប់មន្ត្រីពាក់ព័ន្ធដើម្បីរាយការណ៍ពីភាពមិនប្រក្រតីណាមួយទាក់ទងនឹងគម្រោងលទ្ធកម្ម
- ប្រព័ន្ធការពារត្រូវតែបានអនុម័ត ដើម្បីផ្តល់ការការពារដល់មន្ត្រី និង
- មន្ត្រីត្រូវទទួលបានការបណ្តុះបណ្តាលអំពីសុចរិតភាព និងត្រូវបានលើកទឹកចិត្តឱ្យរាយការណ៍ពីភាពមិនប្រក្រតីណាមួយនៅក្នុងនីតិវិធីលទ្ធកម្ម។[95]

## ខ. សិទ្ធិតវ៉ានិងខ្លឹមសារ

១. សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈអាចបញ្ញត្តិអំពីការបង្កើតស្ថាប័នឯករាជ្យ ដើម្បីទទួលខុសត្រូវជាពិសេសលើនីតិវិធីនៃការតវ៉ាផ្នែករដ្ឋបាល។

២. កង្វះខាតនៃយន្តការសម្រាប់តតិយជនដែលមានផលប្រយោជន៍ក្នុងការប្តឹងតវ៉ាប្រឆាំងនឹងភាពមិនប្រក្រតីណាមួយនៅក្នុងនីតិវិធីលទ្ធកម្ម៖ រាជរដ្ឋាភិបាលកម្ពុជាអាចពិចារណាធ្វើការអភិវឌ្ឍយន្តការមួយដើម្បីដោះស្រាយនូវកង្វះខាតផ្នែករដ្ឋបាល និង/ឬដំណោះស្រាយតាមផ្លូវច្បាប់សម្រាប់តតិយជនដែលមានផលប្រយោជន៍តាមផ្លូវច្បាប់ដើម្បីធ្វើការតវ៉ាលើជម្រើសនៃនីតិវិធីដេញថ្លៃនេះ។

៣. កង្វះខាតនៃការកំណត់ពេលវេលាសម្រាប់ការដោះស្រាយពាក្យបណ្តឹង៖ ដើម្បីឱ្យមានភាពច្បាស់លាស់លើបញ្ហាផ្លូវច្បាប់ ការបញ្ជាក់ឱ្យច្បាស់អំពីពេលវេលាកំណត់ដើម្បីដោះស្រាយ“ពាក្យបណ្តឹង”ដែល

---

[95] សូមមើលជាឧទាហរណ៍ ការបណ្តុះបណ្តាលស្តីពីសុចរិតភាពនៅក្នុងប្រទេសអាល្លឺម៉ង់ នៅ OECD, កម្រងឧត្តមានុវត្តន៍នៃការអនុវត្តលទ្ធកម្មសាធារណៈសម្រាប់សុចរិតភាព ឆ្នាំ២០១៤ ទំព័រ ២៣

ប្តឹងដោយអ្នកដេញថ្លៃទៅរដ្ឋបាលនិងតុលាការ ហើយនឹងកម្មវិបាកឬអានុភាពនៃការតវ៉ានោះអាចត្រូវបានចែងឱ្យបានច្បាស់លាស់នៅក្នុងច្បាប់។[96] នៅពេលទទួលបានការតវ៉ា អង្គភាពលទ្ធកម្មអាចផ្សព្វផ្សាយការតវ៉ានេះតាមរយៈសេចក្តីជូនដំណឹងជាសាធារណៈ។

៤. រាជរដ្ឋាភិបាលកម្ពុជាគួរតែពិចារណាបង្កើតតុលាការ ដើម្បីដោះស្រាយរាល់បណ្តឹងទាក់ទងនឹងលទ្ធកម្មសាធារណៈ។[97]

៥. ការប្រើប្រាស់ពាក្យពេចន៍មិនច្បាស់លាស់នៅក្នុង មាត្រា ៥១ នៃសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ទាក់ទងនឹងការជំទាស់តវ៉ានឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការលើកិច្ចសន្យាដែលបានប្រគល់ ៖ រាជរដ្ឋាភិបាលកម្ពុជាអាចដាក់ចេញនូវរបបដែលផ្តល់ភាពងាយស្រួលក្នុងការយល់ពីផលប៉ះពាល់នៃការតវ៉ានេះ នៅក្នុងអំឡុងពេលបើកឱ្យមានការជំទាស់តវ៉ា។

៦. វិសាលភាពនៃស្វ័យភាពរបស់ភាគីពាក់ព័ន្ធនឹងជម្រើសនៃយន្តការដោះស្រាយវិវាទ៖ សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ចាំបាច់ត្រូវកំណត់វិសាលភាពនៃស្វ័យភាពរបស់គូភាគីនៃកិច្ចសន្យាលទ្ធកម្ម ទាក់ទងនឹងលទ្ធភាពជ្រើសរើសមជ្ឈត្តកម្ម ឬមធ្យោបាយផ្សេងទៀតសម្រាប់ការដោះស្រាយវិវាទ។

## ច. ការចូលរួមពីសាធារណៈជន

១. ការចូលរួមរបស់សាធារណជនក្នុងអំឡុងពេលនៃការធ្វើវិសោធនកម្មប្រព័ន្ធលទ្ធកម្មសាធារណៈ៖ រាជរដ្ឋាភិបាលកម្ពុជាគួរតែបន្តអញ្ជើញភាគីពាក់ព័ន្ធដើម្បីផ្តល់យោបល់លើសេចក្តីព្រាងច្បាប់និងបទប្បញ្ញត្តិទាក់ទងនឹងលទ្ធកម្មសាធារណៈ ដើម្បីធានាថាមតិដែលបានផ្តល់ត្រូវបានយកមកពិចារណា ហើយការធ្វើវិសោធនកម្មនេះត្រូវបានធ្វើឡើងដោយត្រឹមត្រូវ។

២. កង្វះខាតនៃការចូលរួមរបស់សាធារណជន និងភាគីពាក់ព័ន្ធនៅដំណាក់កាលមុនការដេញថ្លៃ៖ ក្នុងគោលបំណងដើម្បីឱ្យការចូលរួមដាក់ពាក្យប្រកួតប្រជែងដេញថ្លៃប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព រាជរដ្ឋាភិបាលកម្ពុជាគួរតែរៀបចំកិច្ចសន្ទនាប្រកបដោយតម្លាភាព និងយ៉ាងទៀងទាត់ជាមួយភាគីពាក់ព័ន្ធ។

៣. រាជរដ្ឋាភិបាលកម្ពុជាគួរតែព្យាយាម ១) បញ្ជូនសេចក្តីសង្ខេបនៃគម្រោងលទ្ធកម្មជាមួយនឹងឯកសារថវិកាប្រចាំឆ្នាំទៅសភាដើម្បីត្រួតពិនិត្យ ២) បោះពុម្ពផ្សាយរបាយការណ៍សង្ខេបនៃការប្រតិបត្តិ

---

[96] សូមមើលជាឧទាហរណ៍ ច្បាប់ស្តីពីលទ្ធកម្មសាធារណៈរបស់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ឆ្នាំ២០១៧ មាត្រា ៤៦ ដែលចែងពីរយៈពេលកំណត់ចំនួន១៥ថ្ងៃសម្រាប់ស្ថាប័នអនុវត្តលទ្ធកម្មដើម្បីដោះស្រាយបណ្តឹងមុននឹងបញ្ជូនបណ្តឹងនេះទៅស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ ខណៈដែលច្បាប់នេះមិនបានចែងឱ្យបានច្បាស់ពីរយៈពេលកំណត់សម្រាប់ការបញ្ជូនបណ្តឹងទៅប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ

[97] សូមមើលជាឧទាហរណ៍ ច្បាប់ស្តីពីលទ្ធកម្មរដ្ឋាភិបាលសឹង្ហបូរីឆ្នាំ១៩៩៧ ដែលបង្កើតតុលាការលទ្ធកម្មរដ្ឋាភិបាលសម្រាប់ទទួលបណ្តឹងពាក់ព័ន្ធនឹងការបំពានតួនាទីរបស់អាជ្ញាធរដែលចុះកិច្ចសន្យា ឯកសារមាននៅ: https://sso.agc.gov.sg/Act/GPA1997#:~:text=An%20Act%20to%20give%20effect,and%20for%20purposes%20connected%20therewith.

និងផែនការរបស់គម្រោងលទ្ធកម្ម ក៏ដូចជាគម្រោងលទ្ធកម្មដែលមានសក្តានុពល និង ៣) អនុញ្ញាតឱ្យការចូលរួមពីប្រជាពលរដ្ឋកាន់តែច្រើនក្នុងនីតិវិធីលទ្ធកម្ម ក៏ដូចជាដំណើរការថវិកាសម្រាប់ការចំណាយលើលទ្ធកម្មសាធារណៈ។

## ឆ. ការបើកចំហ និងបរិយាបន្ន

១. កង្វះខាតនៃយន្តការដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមពីអ្នកដេញថ្លៃអន្តរជាតិ៖ រាជរដ្ឋាភិបាលកម្ពុជាអាចពិចារណាដកចេញនូវលក្ខខណ្ឌនៃការចុះឈ្មោះជាមួយនឹង **ក.ស.ហ.វ.** ដើម្បីការបើកទូលាយឱ្យគ្រប់ក្រុមហ៊ុនមានសិទ្ធិចូលរួមក្នុងគម្រោងលទ្ធកម្មសាធារណៈសម្រាប់ការដេញថ្លៃប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ។

២. កិច្ចសន្យាលទ្ធកម្មសាធារណៈ ដែលត្រូវបានធ្វើឡើងដោយមិនបានឆ្លងកាត់នីតិវិធីលទ្ធកម្មប្រកប ដោយភាពត្រឹមត្រូវនៅក្រោមច្បាប់និងបទប្បញ្ញត្តិជាធរមាន នឹងត្រូវចាត់ទុកជាមោឃៈដោយសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។

៣. រាជរដ្ឋាភិបាលកម្ពុជាគួរតែពិចារណាដាក់ចេញនូវបទប្បញ្ញត្តិនានា ដើម្បីគាំទ្រដល់ការចូលរួមរបស់សហគ្រាសធុនតូចនិងមធ្យម[98]។

៤. រាជរដ្ឋាភិបាលកម្ពុជាគួរតែធ្វើឱ្យវដ្តនៃលទ្ធកម្មសាធារណៈមានភាពស្របគ្នាជាមួយនឹងគោលនយោបាយជាតិនៃសេដ្ឋកិច្ចនិងសង្គម។[99] ជាឧទាហរណ៍ មាត្រា ៥៤ នៃសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈគួរតែត្រូវបានកែតម្រូវតាមរបៀបនៃការបញ្ចូលគំនិតនិរន្តរភាពលទ្ធកម្មដោយបន្ថែមថា "បញ្ហាបរិស្ថាន" អាចត្រូវបានប្រើប្រាស់ដោយអង្គភាពលទ្ធកម្មជាលក្ខណៈវិនិច្ឆ័យជ្រើសរើសនៅក្នុងឯកសារដេញថ្លៃ។ ជម្រើសមួយទៀត បទប្បញ្ញត្តិដែលអនុវត្តអាចដាក់បញ្ចូលលក្ខណៈវិនិច្ឆ័យបែបនេះ ប៉ុន្តែវានឹងផ្តល់ប្រសិទ្ធភាពតិចជាងដោយសារវាជាដូចជាបញ្ញត្តិទូទៅនៅក្នុងច្បាប់។

៥. ដូចគ្នាផងដែរ សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ក៏គួរពិចារណាផងដែរអំពីវិមជ្ឈការនៃលទ្ធកម្មសាធារណៈលើកលែងតែលទ្ធកម្មណាមួយដែលតម្រូវឱ្យអ្នកមានសមត្ថភាពខ្ពស់ធ្វើការចរចា

---

[98] សូមមើលជាឧទាហរណ៍ បទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាលនៃប្រទេសឥណ្ឌូនេស៊ី លើលទ្ធកម្មរដ្ឋាភិបាល (២០១៨) មាត្រា២៩ ស្តីពីការបង់ប្រាក់ជាមុនសំរាប់អាជីវកម្មមានទំហំតូច; ជំពូកទី៩ ស្តីពីពាណិជ្ជកម្មមានទំហំតូច ផលិតផលក្នុងស្រុក និងនិរន្តរភាពនៃលទ្ធកម្មសាធាណៈ ឯកសារមាននៅ: https://jdih.lkpp.go.id/regulation/download/terjemahan-resmi-peraturan-presiden-nomor-16-tahun-2018/1

[99] សូមមើលជាឧទាហរណ៍ ច្បាប់ស្តីពីលទ្ធកម្មសាធារណៈរបស់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ឆ្នាំ២០១៧ ស្តីពីលទ្ធកម្មក្នុងស្រុក, ឯកសារមាននៅ: http://ppmd.mof.gov.la/storage/1632981237.Laos%20PDR%20Public%20Procurement%20Law_English[23].pdf

សម្រាប់ការទិញប្រកបដោយប្រសិទ្ធភាព។ ហេតុដូច្នេះ គណនេយ្យភាពសង្គមនៅរដ្ឋបាលមូលដ្ឋានអាចត្រូវបានអនុម័តសម្រាប់ការលើកកម្ពស់ការចូលរួមជាសាធារណៈក្នុងលទ្ធកម្ម។

## ផ្នែកទី៤៖ សេចក្តីសន្និដ្ឋាន

ក្នុងពេលបច្ចុប្បន្ននេះ កម្ពុជាកំពុងតែធ្វើសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈថ្មីមួយ។ ឆ្លៀតក្នុងឱកាសដែលសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈថ្មីមិនទាន់ត្រូវបានអនុម័ត ការសិក្សានេះត្រូវបានចាប់ផ្តើមធ្វើឡើងក្នុងគោលបំណងដើម្បីវាយតម្លៃក្របខណ្ឌច្បាប់នៃលទ្ធកម្មសាធារណៈនៅកម្ពុជា ក៏ដូចជាសេចក្តីព្រាងច្បាប់ថ្មី ដើម្បីកំណត់ពីភាពខ្វះខាតឬភាពចន្លោះប្រហោងក្នុងច្បាប់ ដែលអាចប៉ះពាល់ដល់គោលការណ៍តម្លាភាពលទ្ធកម្មសាធារណៈ ក៏ដូចជាអាចបង្កហានិភ័យនៃអំពើពុករលួយ។ ទាក់ទងនឹងវិធីសាស្ត្រ ការសិក្សានេះបានពិនិត្យលើច្បាប់ដែលមានជាសាធារណៈនៅក្នុងប្រទេសកម្ពុជាទាក់ទងនឹងលទ្ធកម្មសាធារណៈ ដោយធ្វើការប្រៀបធៀបជាមួយច្បាប់និងគោលការណ៍សំខាន់ៗផ្សេងទៀតនៃលទ្ធកម្មសាធារណៈ និងឧត្តមានុវត្តន៍អន្តរជាតិ។ តាមរយៈការវាយតម្លៃ ការសិក្សានេះបានរកឃើញនូវបញ្ហាដូចដែលបានពិភាក្សានៅក្នុងផ្នែកទី២ ខាងលើ និងផ្តល់នូវអនុសាសន៍ ដូចដែលបានរៀបរាប់នៅក្នុងផ្នែកទី៣។ អនុសាសន៍ដែលបានផ្តល់ឱ្យនៅក្នុងរបាយការណ៍នេះ គឺសម្រាប់ផ្តល់ជូនរាជរដ្ឋាភិបាលកម្ពុជា ដើម្បីយកទៅពិចារណាក្នុងអំឡុងពេលធ្វើសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងច្បាប់ពាក់ព័ន្ធផ្សេងទៀតក្នុងគោលបំណងកែលម្អប្រព័ន្ធលទ្ធកម្មសាធារណៈនៅកម្ពុជា។

វិមជ្ឈការនៃលទ្ធកម្មសាធារណៈមិនត្រូវបានលើកឡើងនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈនោះទេ។ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ លទ្ធកម្មសាធារណៈត្រូវបានគ្រប់គ្រងដោយលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។[100] ដោយមានសមត្ថកិច្ចរួមគ្នារវាងក្រសួងមហាផ្ទៃនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបញ្ហាពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈនៅរដ្ឋបាលរាជធានី ខេត្ត ស្រុក ខណ្ឌ ក្រសួងមហាផ្ទៃ នៅតែរក្សាសមត្ថកិច្ចរបស់ខ្លួននៅលើកិច្ចការរដ្ឋបាលនៅថ្នាក់ក្រោមជាតិ ខណៈពេលដែល **ក.ស.ហ.វ.** តាមរយៈមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត មានសមត្ថកិច្ចលើ៖ ១) ការពិនិត្យនិងអនុម័តផែនការលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និង ២) ការពិនិត្យនិងអនុម័តលើលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ **ក.ស.ហ.វ.**។ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តនូវយុទ្ធសាស្ត្រកំណែទម្រង់សម្រាប់លទ្ធកម្មសាធារណៈពីឆ្នាំ ២០១៩ ដល់ឆ្នាំ ២០១៥។ ក្រោមយុទ្ធសាស្ត្រកំណែទម្រង់ដែលបានអនុម័តនេះ រាជរដ្ឋាភិបាលកម្ពុជាមានគោលបំណងធ្វើវិមជ្ឈការនៃដំណើរការនិងនីតិវិធីលទ្ធកម្ម លើកលែងតែប្រភេទនៃលទ្ធកម្មមួយចំនួន ដែលទាមទារឱ្យធ្វើឡើងក្រោមក្របខណ្ឌមជ្ឈការដើម្បីកាត់បន្ថយការចំណាយ។ ក៏ប៉ុន្តែសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ មិនបានចង្អុលបង្ហាញឱ្យបានជាក់លាក់ណាមួយទេ ទាក់ទងនឹងដំណើរការវិមជ្ឈការបែបនេះទេ។

---

[100] សូមមើលអនុក្រឹត្យលេខ១៣ (ឆ្នាំ២០១៥) ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម; ប្រកាសអន្តរក្រសួងលេខ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគោលការណ៍ណែនាំផ្សេងទៀត

# ឯកសារយោង

| ល.រ | ច្បាប់ |
|---|---|
| ១. | សេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ (សេចក្ដីព្រាងលើកទី១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២) ផ្ដល់ដោយវិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ |
| ២. | ច្បាប់ស្ដីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ |
| ៣. | ច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ |
| ៤. | ច្បាប់ស្ដីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២១ |
| ៥. | ច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៨ |
| ៦. | ច្បាប់ស្ដីពីសម្បទាន ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៧ |
| ៧. | ច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ |
| **ល.រ** | **អនុក្រឹត្យ** |
| ១. | អនុក្រឹត្យស្ដីលេខ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្ដីពីលទ្ធកម្មសាធារណៈ |
| ២. | អនុក្រឹត្យស្ដីលេខ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្ដីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម |
| ៣. | អនុក្រឹត្យលេខ២១ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ ស្ដីពីបែបបទ និងនីតិវិធីនៃការប្ដឹង និងការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្ម |
| ៤. | អនុក្រឹត្យលេខ១៨១ អនក្រ.បក ស្ដីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសំរាប់ការគ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន |
| **ល.រ** | **ប្រកាស** |
| ១. | ប្រកាសលេខ០៤៥ សហវ.ប្រក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៥ ស្ដីពីការអនុវត្តវិសហមជ្ឈការកិច្ចលទ្ធកម្មសាធារណៈ |
| ២. | ប្រកាសអន្តរក្រសួងលេខ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ស្ដីពីនីតិវិធីនៃការបង្កើត រៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| ៣. | ប្រកាសលេខ១៨៤៤ សហវ.ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីការកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម |

| | |
|---|---|
| ៤. | ប្រកាសលេខ២៤៩ សហវ.ប្រក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្ដីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា |
| ៥. | ប្រកាសលេខ៩៨៦ សហវ.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ស្ដីពីប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា |
| ៦. | ប្រកាសលេខ៩៨៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ស្ដីពីក្រមសីលធម៌លទ្ធកម្ម |
| ៧. | ប្រកាសលេខ៩៨៨ សហវ.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ស្ដីពីការដាក់ឱ្យប្រើប្រាស់ណែនាំស្ដីពីការត្រួតពិនិត្យលទ្ធកម្មតាមក្រោយ |
| ៨. | ប្រកាសលេខ៨៥១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្ដីពីការរៀបចំផែនការលទ្ធកម្ម |
| ៩. | ប្រកាសលេខ១៦១៣ សហវ.ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ស្ដីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ |
| ១០. | ប្រកាសលេខ១៦១៤ សហវ.ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ស្ដីពីនីតិវិធីនៃការចុះជម្រះ និងការផ្សព្វផ្សាយបញ្ជីខ្មៅ |
| ១១. | ប្រកាសលេខ០១០ សហវ.ប្រក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ ស្ដីពីកម្រិតទឹកប្រាក់សិទ្ធិសម្រេចក្នុងកិច្ចលទ្ធកម្មសាធារណៈ |
| **ល.រ** | **សារាចរណែនាំ** |
| ១. | សារាចរណែនាំលេខ០០១ សហវ.អលសា ចុះថ្ងៃទី២៣ ខែកុម្ភៈឆ្នាំ២០១២ ស្ដីពីការអនុវត្តច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ |
| ២. | សារាចរណែនាំលេខ០០២ សហវ.អលសា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ស្ដីពីអនុវត្តលទ្ធកម្មសាធារណៈ |
| ៣. | សារាចរណែនាំលេខ០១៣ សហវ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្ដីពីការអនុវត្តកិច្ចលទ្ធកម្មសម្រាប់មុខទំនិញ និងសេវាកម្មចាំបាច់មួយចំនួនដែលត្រូវប្រើប្រាស់បន្ទាន់នៅដើមឆ្នាំថវិកា |
| ៤. | សារាចរណែនាំលេខ០០២ សហវ.អលសា ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្ដីពីវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរដ្ឋបាលក្រុង ស្រុក ខណ្ឌ |
| ៥. | សារាចរណែនាំលេខ០១៥ សហវ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្ដីពីការរឹបអូសប្រាក់កក់ក្នុងដំណើរការកិច្ចលទ្ធកម្មសាធារណៈនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ |
| ៦. | សារាចរណែនាំលេខ០១៣ សហវ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ ស្ដីពីនីតិវិធីនៃការធ្វើចំណាត់ថ្នាក់ប្រភេទ និងចំណាត់ថ្នាក់អ្នកទទួលការសាងសង់ |
| ៧. | សារាចរណែនាំលេខ០០១ សហវ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ ស្ដីពីការកក់ប្រាក់ធានាការដេញថ្លៃ និងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ |

| | |
|---|---|
| ៨. | សារាចរណែនាំលេខ០០៦ សហវ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ |
| ៩. | ចរណែនាំលេខ០០២ សហវ.អលសា ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ |
| **ល.រ** | **សេចក្តីណែនាំ** |
| ១. | សេចក្តីណែនាំលេខ០១៤ សហវ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩ ស្តីពីនីតិវិធីធ្វើបុរេលក្ខណសម្បត្តិអ្នកដេញថ្លៃ |
| **ល.រ** | **សៀវភៅនិងឯកសារ** |
| ១. | ធនាគារអភិវឌ្ឍន៍អាស៊ី គោលនយោបាយលទ្ធកម្មសាធារណៈរបស់ធនាគារអភិវឌ្ឍន៍អាស៊ីៈ ទំនិញ ការងារ និងសេវាពិគ្រោះឬមិនពិគ្រោះ ឆ្នាំ២០១៧ |
| ២. | អង្គការសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការសេដ្ឋកិច្ច, គោលការណ៍ណែនាំរបស់ក្រុមប្រឹក្សាលទ្ធកម្មសាធារណៈ ឆ្នាំ២០១៥ |
| ៣. | អង្គការសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការសេដ្ឋកិច្ច កម្រងឧត្តមានុវត្តន៍នៃការអនុវត្តលទ្ធកម្មសាធារណៈសម្រាប់សុចរិតភាពឆ្នាំ២០១៤ |
| ៤. | នីតិវិធីប្រតិបត្តិការស្តង់ដលើការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់គម្រោង/កម្មវិធីដែលបានទទួល ហិរញ្ញប្បទានពីខាងក្រៅនៅក្នុងប្រទេសកម្ពុជា ភាគ I ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២ |
| ៥. | នីតិវិធីប្រតិបត្តិការស្តង់ដលើការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់គម្រោង/កម្មវិធីដែលបានទទួល ហិរញ្ញប្បទានពីខាងក្រៅនៅក្នុងប្រទេសកម្ពុជា ភាគII ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២ |
| ៦. | អង្គការសហប្រជាជាតិ ការណែនាំស្តីពីការដាក់ឱ្យប្រើគម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈ របស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ ឆ្នាំ២០១២ |
| ៧. | ការិយាល័យប្រឆាំងឧក្រិដ្ឋកម្មនិងគ្រឿងញៀនរបស់អង្គការសហប្រជាជាតិ សៀវភៅណែនាំស្តីពីការប្រឆាំងអំពើពុករលួយនៅក្នុងលទ្ធកម្មសាធារណៈ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៖ ការអនុវត្តដ៏ល្អក្នុងការធានាអនុលោមភាពជាមួយមាត្រា៩នៃអនុសញ្ញាប្រឆាំងអំពើពុករលួយរបស់អង្គការសហប្រជាជាតិ ឆ្នាំ២០១៣ |

## ការរៀបរៀបលិខិតតូបករណ៍

## ក្រមខណ្ឌច្បាប់ជាតិនៃបណ្ដាប្រទេសសមាជិកអាស៊ាន

| ល.រ | ក្រមខណ្ឌច្បាប់ |
|---|---|
| ១. | ច្បាប់ស្ដីពីលទ្ធកម្មរដ្ឋាភិបាលឆ្នាំ១៩៩៧ របស់ប្រទេសសិង្ហបុរី |
| ២. | បទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាលនៃប្រទេសឥណ្ឌូនេស៊ី លើលទ្ធកម្មរដ្ឋាភិបាល ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ |
| ៣. | ច្បាប់ស្ដីពីលទ្ធកម្មសាធារណៈនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៧ |

## ក្រមខណ្ឌច្បាប់ជាតិ និងថ្នាក់តំបន់ផ្សេងៗ

| ល.រ | ក្រមខណ្ឌច្បាប់ |
|---|---|
| ១. | សេចក្ដីណែនាំ ២០០៧/៦៦/អឺរ៉ុប នៃសភា និងក្រុមប្រឹក្សាអឺរ៉ុប ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៧ កែសម្រួលសេចក្ដីណែនាំរបស់ក្រុមប្រឹក្សាលេខ ៨៩/៦៦៥/ក្រុមប្រឹក្សាអឺរ៉ុប និង លេខ ៩២/១៣/ក្រុមប្រឹក្សាអឺរ៉ុប ពាក់ព័ន្ធនឹងការបង្កើនប្រសិទ្ធភាព នៃនីតិវិធីត្រួតពិនិត្យការផ្ដល់កិច្ចសន្យាសាធារណៈ OJL ៣៣៥, ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២ |
| ២. | ច្បាប់ស្ដីពីលទ្ធកម្មសាធារណៈនៃប្រទេសតួកគី ចុះនៅខែមករា ឆ្នាំ២០១២ |

## លិខិតតូបករណ៍អន្តរជាតិ

| ល.រ | លិខិតតូបករណ៍ |
|---|---|
| ១. | អង្គការសហប្រជាជាតិ, គម្រូច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ របស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្ដីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ |

# បញ្ញត្តិដែលកំពុងត្រូវបានអនុវត្ត

| អនុក្រឹត្យ | | | |
|---|---|---|---|
| **ច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ** | **សេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ** | **បញ្ញត្តិ** | **មតិយោបល់** |
| មាត្រា ៨ | មាត្រា ៨ | **នីតិវិធីនៃការបង្កើតគណៈកម្មធិការលទ្ធកម្ម** ត្រូវកំណត់ដោយអនុក្រឹត្យ។ | អនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្ដីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មធិការលទ្ធកម្មនិងអង្គភាពលទ្ធកម្ម |
| មាត្រា ៩ | មាត្រា ៩ | **នីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពលទ្ធកម្ម** ត្រូវកំណត់ដោយអនុក្រឹត្យ។ | អនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្ដីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មធិការលទ្ធកម្មនិងអង្គភាពលទ្ធកម្ម |
| មាត្រា ៦២ | មាត្រា ៦៥ | បែបបទ និងនីតិវិធីនៃការប្ដឹង និងការដោះស្រាយបណ្ដឹងទៅស្ថាប័ន អនុវត្តលទ្ធកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់ដោយអនុក្រឹត្យ។ | អនុក្រឹត្យលេខ២១ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ ស្ដីពីបែបបទ និងនីតិវិធីនៃការប្ដឹង និងការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្ម |
| មាត្រា ៧៤ | មាត្រា ៨០ | អនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្ដីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តិ ពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈដែលជាធរមាននៅមានសុពលភាពរហូតដល់មានលិខិតបទដ្ឋានគតិយុត្តិថ្មីមកជំនួស ស្របតាមស្មារតីនៃច្បាប់នេះ។ | អនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្ដីពីលទ្ធកម្មសាធារណៈ |
| **ប្រកាស** | | | |
| គ្មាន | មាត្រា ៥ | **តួនាទី និងភារកិច្ច របស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ** ត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ | ១) ពិនិត្យមើលប្រកាសបច្ចុប្បន្នស្ដីពីអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ<br>២) បើមានទេ |

| | | | |
|---|---|---|---|
| | | | ថ្មី |
| មាត្រា ៩ | មើលខាងក្រោម | ក្នុងករណីដែលអង្គភាពថវិកាត្រូវបានទទួលសិទ្ធិជាអាណាប័កផ្ទេរសិទ្ធិ ពីអាណាប័កដើមខ្សែនៃក្រសួង ស្ថាប័ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសផ្ទេរសិទ្ធិអំណាចតាមការចាំបាច់ ទៅឱ្យអង្គភាពថវិកានៃក្រសួង ស្ថាប័ននោះ ដើម្បីអនុវត្តកិច្ចលទ្ធកម្ម | ប្រកាសលេខ ៥៥៧ សហវ.ប្រក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ស្ដីពីការបង្កើតគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម |
| | មាត្រា ៩ | លក្ខណៈវិនិច្ឆ័យ និងនីតិវិធីនៃការបង្កើតគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ | ថ្មី |
| មាត្រា ១០ | ដូចគ្នា | វិធីសាស្ត្រលទ្ធកម្មទំនិញ និងសំណង់ និងសេវាកម្ម ត្រូវធ្វើឡើង ដោយអនុលោមតាម មាត្រា ១១ មាត្រា១២ និងមាត្រា១៣ នៃច្បាប់នេះ។ លក្ខខណ្ឌ កម្រិតទឹកប្រាក់ និងនីតិវិធីសម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មនីមួយៗ ត្រូវកំណត់ដោយ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ | ប្រកាសលេខ១៨៤៤ សហវ.ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីការកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម |
| មាត្រា ២៥ | មាត្រា ២៦ | នីតិវិធីនៃការជ្រើសរើសទីប្រឹក្សា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ | មិនអាចកំណត់បាន |
| មាត្រា ២៧ | មាត្រា ២៨ | នីតិវិធីនៃការធ្វើចំណាត់ប្រភេទ និងចំណាត់ថ្នាក់អ្នកដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ | ប្រកាសលេខ១៦១៤ សហវ.ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ស្ដីពីនីតិវិធីនៃការជម្រុះ និងការផ្សព្វផ្សាយបញ្ជីខ្មៅ<br>សារាចរណែនាំលេខ០១៣ សហវ.ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ ស្ដីពីនីតិវិធីនៃការធ្វើចំណាត់ថ្នាក់ប្រភេទ និងចំណាត់ថ្នាក់អ្នកទទួលការសាងសង់ |
| មាត្រា ២៨ | មាត្រា ២៩ | នីតិវិធីសម្រាប់កំណត់បុរេលក្ខណសម្បត្តិអ្នកដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់ | ប្រកាសលេខ៨៥១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្ដីពីការរៀបចំផែនការលទ្ធកម្ម |

| | | | |
|---|---|---|---|
| | | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ | |
| មាត្រា ២៩ | មាត្រា ៣០ | នីតិវិធីសម្រាប់កំណត់លក្ខណសម្បត្តិតាមក្រោយរបស់អ្នកដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ | ប្រកាសលេខ៨៥១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំផែនការលទ្ធកម្ម |
| មាត្រា ៣០ | មាត្រា ៣១ | នីតិវិធីនៃការចុះ ការជម្រះ និងការផ្សព្វផ្សាបញ្ជីខ្មៅ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ | ប្រកាសលេខ១៦៦៤ សហវ.ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការជម្រុះ និងការផ្សព្វផ្សាយបញ្ជីខ្មៅ |
| មាត្រា ៣១ | មាត្រា ៣២ | នីតិវិធីនៃការរៀបចំផែនការលទ្ធកម្មត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ | ប្រកាសលេខ៨៥១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំផែនការលទ្ធកម្ម |
| មាត្រា ៣៩ | មាត្រា ៣៩ | គំរូឯកសារដេញថ្លៃត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រកាសលេខ៣២៥ សហវ.ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤ |
| មាត្រា ៤១ | មាត្រា ៤១ | បែបបទ និងការកំណត់ថ្លៃលក់ឯកសារដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ | មិនមានប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| មាត្រា ៤៣ | មាត្រា ៤០ | ប្រាក់កក់ធានាការដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ | ប្រកាសលេខ៩៨៦ សហវ.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ស្តីពីប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា |
| មាត្រា ៤៥ | មាត្រា ៤៧ | នីតិវិធីវាយតម្លៃលើសំណើដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ | ប្រកាសអន្តរក្រសួងលេខ ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការបង្កើតរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មធិកាលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| មាត្រា ៤៧ | គ្មាន | កិច្ចលទ្ធកម្មដែលត្រូវពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើកលែងតែកិច្ចលទ្ធកម្មដែល | ប្រកាសអន្តរក្រសួងលេខ ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការបង្កើតរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិកាលទ្ធកម្ម |

| | | | |
|---|---|---|---|
| | | អនុវត្តដោយរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ | និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| គ្មាន | មាត្រា ៥០ | គម្រោងទឹកប្រាក់ធំដែលមានចរិកជាយុទ្ធសាស្ត្រ និងមានលក្ខណៈបច្ចេកទេសដោយឡែក សម្រាប់ការគ្រប់គ្រង និងគម្រោងមានវេទយិតភាពខ្ពស់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ | ថ្មី |
| មាត្រា ៥១ | មាត្រា ៥៥ | នីតិវិធីនៃការអនុវត្តកិច្ចលទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ | ថ្មី៖ ប្រព័ន្ធលទ្ធកម្មអេឡិចត្រូនិចរដ្ឋាភិបាល |
| មាត្រា ៥៣ | មាត្រា ៥៦ | ការរៀបចំកិច្ចសន្យាលទ្ធកម្ម ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងស្របតាមលក្ខខណ្ឌដែលមានចែងក្នុងឯកសារដេញថ្លៃ ព្រមទាំងស្របតាមគំរូកិច្ចសន្យាដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ | នីតិវិធីប្រតិបត្តិការស្តង់ដារលទ្ធកម្មរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| គ្មាន | មាត្រា ៥៤ (ថ្មី) | ការកំណត់ពេលវេលា វិធាន និងនីតិវិធីសម្រាប់ការអនុវត្តលទ្ធកម្មប្រកបដោយចីរភាពត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ | ថ្មី |
| មាត្រា ៥៧ | មាត្រា ៦០ | កាលៈទេសៈពិសេស និងវិធីសាស្ត្រកែប្រែតម្លៃអំឡុងពេលអនុវត្តកិច្ចសន្យាកាលៈទេសៈពិសេស ដែលតម្លៃនៃកិច្ចសន្យាអាចកែប្រែបាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ | មិនអាចកំណត់បាន |
| មាត្រា ៥៨ | មាត្រា ៦១ | ចំនួនប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា | ប្រកាសលេខ ៩៨៦ សហវ/ប្រក ចុះថ្ងៃទី៣១ សីហា ២០១៦ ស្តីពីប្រាក់កក់ធានាការដេញថ្លៃនិង ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា |

| | | | |
|---|---|---|---|
| | | ចំនួនប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ | |
| មាត្រា ៥៩ | មាត្រា ៦២ | នីតិវិធីនៃការបង្កើតគណៈកម្មាធិការប្រគល់ទទួល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ | មិនអាចកំណត់បាន |
| មាត្រា ៦៤ | មាត្រា ៧០ | ក្រមសីលធម៌លទ្ធកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ | ប្រកាសលេខ ៩៨៧ សហវ/ប្រក ចុះថ្ងៃទី៣១ សីហា ២០១៦ ស្តីពីក្រមសីលធម៌លទ្ធកម្ម |
| គ្មាន | មាត្រា ៦៨ (ថ្មី) | នីតិវិធីនៃការត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ | ថ្មី |

# សំណើលើការអនុម័តបញ្ញត្តិថ្មី

| អនុក្រឹត្យ | | | |
|---|---|---|---|
| ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ | សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ | កម្មវត្ថុ | មតិយោបល់ |
| - | - | កាតព្វកិច្ចរក្សាការសម្ងាត់ និងនិយមន័យព័ត៌មានសម្ងាត់ | ដោយហេតុថា តម្លាភាព គឺជាគោលការណ៍គ្រឹះមួយក្នុងចំណោមគោលការណ៍ផ្សេង សម្រាប់ឱ្យលទ្ធកម្មសាធារណៈល្អប្រសើរ មានព័ត៌មានដែលចាត់ទុកថាជាព័ត៌មានសម្ងាត់ដែលមិនអាចបង្ហាញជាសាធារណៈបាន។ ក៏ប៉ុន្តែ និយមន័យព័ត៌មាន "សម្ងាត់" ត្រូវបាន ១) កំណត់បានច្បាស់នៅក្រោមសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ឬ ២) បញ្ជាក់បានច្បាស់នៅក្រោមច្បាប់ពិសេស ដូចជាច្បាប់ស្តីពីទិន្នន័យឯកជន ឬច្បាប់ស្តីពីព័ត៌មាន។ |
| - | - | គ្មានតម្លាភាពលើនីតិវិធីចរចា និងលទ្ធកម្មប្រភពតែមួយ | សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈគួរតម្រូវឱ្យនីតិវិធីចរចា និងលទ្ធកម្មប្រភពតែមួយត្រូវបានបោះពុម្ពផ្សាយជាសាធារណៈ។ |
| - | - | សេចក្តីព្រាងច្បាប់ ស្តីពីលទ្ធកម្មសាធារណៈ តម្រូវឱ្យមានការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីការដេញថ្លៃជាសាធារណៈ និងការបញ្ជាក់បន្ថែម។ ប៉ុន្តែសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ មិនបានកំណត់ពីការប្រកាសជាសាធារណៈនៃការអនុម័តគម្រោង។ | សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ គួរតែបង្កើតថ្នាលអនឡាញសម្រាប់ចែកចាយព័ត៌មានទាំងអស់ពាក់ព័ន្ធនឹងគម្រោងលទ្ធកម្មសាធារណៈ ចាប់តាំងពីដំណាក់កាលចាប់ផ្តើម រហូតដល់ដំណាក់កាលអនុម័ត និងដំណាក់កាលបញ្ចប់។ ដូចគ្នាផងដែរ ការកត់ត្រាទុកនូវរាល់នីតិវិធី គួរតែបោះពុម្ពផ្សាយជាគោលការណ៍នៅក្រោមសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ |

| | | | |
|---|---|---|---|
| - | - | សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ កំណត់អំពីអំណាច ឬសមត្ថកិច្ចទៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រង តាមដាន និងត្រួតពិនិត្យនីតិវិធីលទ្ធកម្ម។ ហេតុដូច្នេះ ទំនាស់ផលប្រយោជន៍ កើតឡើង ខណៈតុល្យភាពអំណាច គឺមិនបានកំណត់។ | សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ គួរតែកំណត់អំពីប្រតិភូកម្មអំណាចទៅអាជ្ញាធរឯករាជ្យក្រៅពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ការត្រួតពិនិត្យ ឬសវនកម្ម លើនីតិវិធីលទ្ធកម្មសាធារណៈ។ |
| - | - | សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ មិនបានកំណត់មូលហេតុគតិយុត្ត ឬបទប្បញ្ញត្តិ សម្រាប់ ១) លើកទឹកចិត្តសហគ្រាសធនតូច និងមធ្យម ឱ្យចូលរួមក្នុងលទ្ធកម្មសាធារណៈ ២) ដាក់ឱ្យលទ្ធកម្មសាធារណៈស្របតាមគោលនយោបាយសេដ្ឋកិច្ចសង្គម ៣) ធ្វើឱ្យវដ្តនៃលទ្ធកម្មសាធារណៈមានភាពស្របគ្នាជាមួយនឹងគោលនយោបាយជាតិនៃសេដ្ឋកិច្ចនិងសង្គម និង ៤) ធ្វើវិមជ្ឍការលទ្ធកម្មសាធារណៈដែលគ្រោងទុក។ | សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ គួរតែកំណត់ បទប្បញ្ញត្តិណាមួយដើម្បីអនុញ្ញាតសម្រាប់ ១) លើកទឹកចិត្តសហគ្រាសធនតូច និងមធ្យមឱ្យចូលរួមក្នុងលទ្ធកម្មសាធារណៈ ២) ដាក់ឱ្យលទ្ធកម្មសាធារណៈស្របតាមគោលនយោបាយ សេដ្ឋកិច្ចសង្គម ៣) ធ្វើឱ្យវដ្តនៃលទ្ធកម្មសាធារណៈមានភាពស្របគ្នាជាមួយនឹងគោលនយោបាយជាតិនៃសេដ្ឋកិច្ចនិងសង្គម និង ៤) វិមជ្ឍការលទ្ធកម្មសាធារណៈដែលគ្រោងទុក។ លើសពីនេះ សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ គួរពិចារណាអនុម័តលើយន្តការនៃការទទួលខុសត្រូវសង្គម នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីពង្រឹងការចូលរួមជាសាធារណៈនៅក្នុងនីតិវិធីលទ្ធកម្មសាធារណៈ។ |
| - | - | សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ មិនបានកំណត់អំពីការការពារផ្លូវច្បាប់សម្រាប់បុគ្គលរាយការណ៍នៃអំពើពុករលួយ ឬភាពមិនអនុលោមនៅក្នុងលទ្ធកម្មសាធារណៈ ក៏ដូចជា ក្របខណ្ឌវាយតម្លៃហានិភ័យ។ | សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ គួរតែកំណត់អំពីលក្ខខណ្ឌសម្រាប់ការវាយតម្លៃហានិភ័យ ក៏ដូចជាក្របខណ្ឌ សម្រាប់កំណត់នូវហានិភ័យខ្ពស់នៅនីតិវិធីលទ្ធកម្មសាធារណៈ។ ដូចគ្នាផងដែរ គួរតែមានគោលនយោបាយស្តីពីបុគ្គលរាយការណ៍ឱ្យបានសមរម្យ និងការការពារតាមផ្លូវច្បាប់សម្រាប់បុគ្គលរាយការណ៍។ |

| | | | |
|---|---|---|---|
| - | - | ពាក់ព័ន្ធនឹងសិទ្ធិក្នុងការដាក់ពាក្យបណ្ដឹង មានតែអ្នកដេញថ្លៃប៉ុណ្ណោះដែលទទួលបានសិទ្ធិនេះ។តតិយជនដែលមានផលប្រយោជន៍ មានដូចជាប្រជាពលរដ្ឋដែលអាចមានផលប៉ះពាល់ដោយការចុះហត្ថលេខាលើកិច្ចសន្យាលទ្ធកម្ម ឬមិនពេញចិត្តនឹងលទ្ធផលនៃគម្រោងលទ្ធកម្ម មិនទទួលបានសិទ្ធិនេះ នៅក្រោមច្បាប់ នឹងសេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈទេ។ | សេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈគួរតែអនុម័តបញ្ញត្តិនៅក្នុងផ្នែកនៃការទទួលពាក្យបណ្ដឹងដើម្បីអនុញ្ញាត្តិឱ្យតតិយជនដែលពាក់ព័ន្ធអាចដាក់ពាក្យបណ្ដឹងផងដែរ។ |
| - | - | សេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈមិនបានចែងអំពីមូលដ្ឋានគតិយុត្តិដើម្បីធ្វើមោឃភាពកិច្ចសន្យាលទ្ធកម្មសាធារណៈ ដែលត្រូវបានចុះហត្ថលេខាឡើងដោយមិនមានអនុលោមភាពជាមួយនឹងលក្ខខណ្ឌតម្រូវដោយច្បាប់។ ហេតុដូច្នេះ អ្នកដេញថ្លៃឯកជន ឬអ្នកវិនិយោគ អាចឃុបឃិតជាមួយមន្ត្រីរដ្ឋាភិបាលក្នុងការចុះហត្ថលេខាដោយមិនមានហានិភ័យគតិយុត្តិណាមួយ។ | សេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈគួរតែចែងពីបញ្ញត្តិដើម្បីធ្វើមោឃភាពកិច្ចសន្យាលទ្ធកម្មសាធារណៈណាមួយដែលត្រូវបានចុះហត្ថលេខាដោយមិនអនុលោមជាមួយនឹងលក្ខខណ្ឌតម្រូវដោយច្បាប់។ |
| - | - | សេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈចែងតែអំពីលក្ខខណ្ឌតម្រូវសំខាន់ៗ ដោយទុកនូវលក្ខខណ្ឌតម្រូវនៃនីតិវិធីឬលក្ខខណ្ឌតម្រូវលម្អិតជាសារធាតុផ្សេងទៀតឱ្យអាជ្ញាធរមានសមត្ថកិច្ចជាអ្នកចេញនូវបទប្បញ្ញត្តិ។ ហេតុដូច្នេះ ការអនុវត្តលើភាពអនុលោមណាមួយលើលក្ខខណ្ឌតម្រូវលម្អិតគឺជាការអនុវត្តតាមរយៈការពិន័យរដ្ឋបាលតែប៉ុណ្ណោះ ដែលមិនមែនជាការធ្វើបណ្ដឹង។ | សេចក្ដីព្រាងច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ គួរតែកំណត់លក្ខខណ្ឌតម្រូវអប្បបរមាមួយចំនួនដើម្បីណែនាំដល់អាជ្ញាធរមានសមត្ថកិច្ចក្នុងការកំណត់លក្ខខណ្ឌតម្រូវលម្អិតនៅក្នុងបទប្បញ្ញត្តិដូចជាលក្ខខណ្ឌតម្រូវសម្រាប់សេចក្ដីជូនដំណឹងស្ដីពីការដេញថ្លៃ (មានដូចជា មាតិកា និងអំឡុងពេល) លក្ខខណ្ឌតម្រូវសម្រាប់ការផ្សព្វផ្សាយព័ត៌មាន និងអំឡុងពេលដើម្បីដាក់ពាក្យបណ្ដឹង។ ជាមួយនឹងលក្ខខណ្ឌតម្រូវអប្បបរមានេះ ភាគីឯកជនក៏ដូចជាតតិយជនដែលមានផលប្រយោជន៍អាចដាក់ពាក្យបណ្ដឹងណាមួយពាក់ព័ន្ធនឹងភាពមិនអនុលោមទៅកាន់ |

| | | | |
|---|---|---|---|
| | | | តុលាការដើម្បីធ្វើការដោះស្រាយពាក់ព័ន្ធនឹងសំណងខូចខាត និងការស៊ើបអង្កេតព្រហ្មទណ្ឌ ក្រៅពីការអនុវត្តនីតិវិធីរដ្ឋបាល។ |
| ១១ | ១១ | សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ចែងពីវិធីសាស្រ្តដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ ជា *"វិធីសាស្រ្តលទ្ធកម្មសម្រាប់ជ្រើសរើស"* នៅក្នុងលទ្ធកម្មសាធារណៈ (មាត្រា ១១)។ គម្រូច្បាប់ស្តីពីលទ្ធកម្មសាធារណៈរបស់គណៈកម្មការនៃអង្គការសហប្រជាជាតិស្តីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិចែងថាការដេញថ្លៃជាសាធារណៈជាវិធីសាស្រ្តលទ្ធកម្មតម្រូវ។ *វិធីសាស្រ្តលទ្ធកម្មតម្រូវ* គឺជាវិធីសាស្រ្ត ដែលត្រូវយកមកអនុវត្តដោយគ្មានលក្ខខណ្ឌ ហើយត្រូវយកមកប្រើប្រាស់គ្រប់ពេលវេលា។ ហេតុដូច្នេះការប្រើប្រាស់វិធីសាស្រ្តលទ្ធកម្មផ្សេងពីនេះតម្រូវឱ្យមានការបញ្ជាក់ហេតុផលពិសេសច្បាស់លាស់។ | "វិធីសាស្រ្តដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ" គួរតែជាវិធីសាស្រ្តលទ្ធកម្មតម្រូវ។ |
| ២៧ | ២៨ | នៅក្នុងបញ្ញត្តិនេះ មានតែដេញថ្លៃដែលបានចុះបញ្ជីជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប៉ុណ្ណោះដែលមានសិទ្ធិចូលរួមក្នុងគម្រោងលទ្ធកម្មសាធារណៈ។ បញ្ញត្តិនេះអាចបង្កជាផលវិបាកដល់អ្នកដេញថ្លៃបរទេសដែលមានសក្កានុពលដើម្បីចូលរួមក្នុងនីតិវិធីដេញថ្លៃ។ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរតែជជែកពិភាក្សាជាមួយក្រសួងពាណិជ្ជកម្មថាតើលក្ខខណ្ឌណាមួយខ្លះគួរផ្តល់ឱ្យអ្នកដេញថ្លៃបរទេស។ ឧទាហរណ៍ ការតម្រូវឱ្យពួកគាត់ធ្វើការចុះបញ្ជី ប្រសិនបើពួកគាត់ត្រូវបានកំណត់ថាអ្នកដេញថ្លៃឈ្នះ។ |
| ៤៧ | ៥០ | ច្បាប់និងសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ មិនបានចែងពីលក្ខខណ្ឌតម្រូវណាមួយដើម្បីផ្សព្វផ្សាយសេចក្តីជូន | គួរមានបទប្បញ្ញត្តិចែងពីបញ្ហាទាំងពីរនេះ។ |

| | | | |
|---|---|---|---|
| | | ដំណឹងស្តីពីការចូលជាធរមានរបស់កិច្ចសន្យាលទ្ធកម្មឡើយ។ ដូចគ្នាផងដែរ មិនមានបញ្ញត្តិដែលតម្រូវឱ្យស្ថាប័នអនុវត្តលទ្ធកម្មផ្តល់នូវហេតុផលជាក់លាក់ដល់អ្នកដេញថ្លៃចាញ់ឡើយ។ | |
| - | - | សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈចែងពីសិទ្ធិតវ៉ានិងឧបាស្រ័យ។ ក៏ប៉ុន្តែច្បាប់នេះមិនបានចែងឱ្យច្បាស់ពី ១) ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មានដូចជា អាជ្ញាកណ្តាល ២) អាជ្ញាយុកាលនៃពាក្យបណ្តឹងទៅតុលាការ និង៣) សិទ្ធិរបស់តតិយជនដែលមានផលប្រយោជន៍ក្នុងការប្តឹងតវ៉ា។ | សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈគួរចែងពី១) ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មានដូចជា អាជ្ញាកណ្តាល ២) អាជ្ញាយុកាលនៃពាក្យបណ្តឹងទៅតុលាការ និង៣) សិទ្ធិរបស់តតិយជនដែលមានផលប្រយោជន៍ក្នុងការប្តឹងតវ៉ា។ |